វិចារណកថា
EDITORIAL

# ពង្រឹងការអនុវត្តច្បាប់ រក្សាប្រក្រតីភាពនៃជីវភាពសង្គមលើគ្រប់ផ្នែក

# Strengthen Rule of Law and Maintain Regular Social Life

*អស់រយៈពេលជាង៥ខែកន្លងមកនេះ តាំងពីក្រោយការបោះឆ្នោតមក គណបក្សប្រឆាំងពុំបានគោរពនូវឆន្ទៈរបស់ប្រជាជនឡើយ ផ្ទុយទៅវិញ បានជំរុញសកម្មភាពប្រឆាំងយ៉ាងខ្លាំងតាមច្រើនរូបភាព មានលក្ខណៈប្រទូសរ៉ាយដែលជះឥទ្ធិពលមិនល្អដល់ស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម ដំណើរការសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជនទូទៅ ។ ក្រោមលេសបម្រើឆន្ទៈរបស់ប្រជាជនជាម្ចាស់ឆ្នោត ពួកមេដឹកនាំនៃគណបក្សប្រឆាំងបានកេណ្ឌប្រមូលអ្នកគាំទ្រខ្លួនឱ្យចូលរួមធ្វើបាតុកម្មឥតឈប់ឈរ ដោយមិនគោរពច្បាប់ មិនគោរពដល់សិទ្ធិរបស់អ្នកដទៃ មិនស្តាប់ការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច និងមិនគិតពីការខាតបង់របស់ជាតិ និងប្រជាជនឡើយ សំដៅគាំទ្រដល់ការទាមទារនានារបស់ពួកគេដែលគ្មានភាពត្រឹមត្រូវ និងគ្មានមូលដ្ឋានច្បាប់ រហូតដល់ទាមទារឱ្យសម្តេចតេជោ* ***ហ៊ុន សែន*** *ចុះចេញពីតំណែងជានាយករដ្ឋមន្ត្រី និងទាមទារឱ្យមានការបោះឆ្នោតជាថ្មីឡើងវិញថែមទៀត ។ សកម្មភាពបាតុកម្មរបស់ពួកគេបានដើរហួសយ៉ាងឆ្ងាយពីក្របខណ្ឌច្បាប់ ក្លាយជាកុប្បកម្មដោយហិង្សាបិទផ្លូវធ្វើដំណើររបស់ប្រជាជន បំផ្លាញទ្រព្យសម្បត្តិសាធារណៈ ទ្រព្យសម្បត្តិឯកជន និងប្រជាជនរារាំងការងាររបស់មន្ត្រីសាធារណៈ ដែលធ្វើឱ្យកម្លាំងមានសមត្ថកិច្ចត្រូវបង្ខំចិត្តអនុវត្តច្បាប់ ដើម្បីពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ឡើងវិញ ។ គោលបំណងចុងក្រោយរបស់ពួកគេ គឺផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ដែល ដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ហើយឡើងកាន់អំណាចតាមរយៈរបស់ដែលគេហៅថា "អំណាចប្រជាជន" ។ សភាពការណ៍នេះបានបង្ហាញយ៉ាងច្បាស់ថា មេដឹកនាំគណបក្សប្រឆាំងបាននាំអ្នកគាំទ្ររបស់ខ្លួនឱ្យដើរផ្ទុយពីរដ្ឋធម្មនុញ្ញ ពីច្បាប់ជាធរមាន និងគោលការណ៍នៃលទ្ធប្រជាធិបតេយ្យហើយ ។*

*នៅក្នុងបរិការណ៍នេះ គណបក្សប្រជាជនកម្ពុជា ដែលប្រជាជនភាគច្រើនលើសលប់បានបោះឆ្នោតគាំទ្រឱ្យបន្តដឹកនាំប្រទេស បាននិងកំពុងធ្វើអ្វីៗគ្រប់យ៉ាងដើម្បីការពាររដ្ឋធម្មនុញ្ញ ការពាររបបប្រជាធិបតេយ្យ សេរីពហុបក្ស ការពាររដ្ឋសភា ការពាររាជរដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោត ដោយមិនអនុញ្ញាតឱ្យកម្លាំងប្រតិកិរិយាណាមកចាប់យកប្រទេសជាតិនិងប្រជាជនទៅធ្វើជាចំណាប់ខ្មាំងរបស់ខ្លួនបានឡើយ ។មកដល់ពេលនេះ ទោះបីជាគណបក្សប្រឆាំងនៅតែពុំព្រមចូលប្រជុំរដ្ឋសភា ហើយដំណើរការចរចារវាងគណបក្សទាំងពីរដែលមាន អាសនៈក្នុងសភាក៏ពុំទាន់ទទួលបានផ្លែផ្កាជាដុំកំភួនក្តី ក៏ពុំមានភាពជាប់គាំងខាងនយោបាយឡើយនៅកម្ពុជា ព្រោះថា ស្ថាប័នព្រះមហាក្សត្រ ស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ គ្រប់ក្រសួង មន្ទីរនិងអាជ្ញាធរ គ្រប់ថ្នាក់កំពុងដំណើរការជាធម្មតា មិនមានការរាំងស្ទះនៅផ្នែកណាមួយទេ ។ ឯជីវភាពប្រចាំថ្ងៃរបស់ប្រជាជនក៏មានប្រក្រតីភាព មានន័យថា សង្គមកម្ពុជាកំពុងតែបន្តនិរន្តរភាពរបស់ខ្លួនដ៏រស់រវើក ។*

*មានភាសិតមួយឃ្លាថា "ហ្វូងឆ្កែចេះតែព្រុស ឯមនុស្សចេះតែបររទេះទៅ" ។ ពិតណាស់ថា សំឡេងឆ្កែ ព្រុសមិនអាចបង្អាក់ដំណើររបស់មនុស្ស*

It is more than five months now, after the general elections, that the opposition party paid no heed to the people's will but drove controversial actions in various forms that ignited negative influence over stability, security, social order, economic process and livelihood of the people in general. Disguised under the pretext of serving their voters, leaders of the opposition party have mobilized supporters to stage endless protests in disrespect of law, rights of others, in ignorance of instruction of concerned authorities and in disregard to national and people's loss, while demanding Samdech Techo to step down from the post of Prime Minister and for re-election.

Those protests have far exceeded the rule of law framework. They turned out to be violent, blocking roads, destroying public and private property, while preventing officials from carrying out their works and duties, leading to a point that competent authority had to reinforce the law to strengthen security and public order. Their utmost aim was to topple the legal Royal Government led by the Cambodian People's Party and to take power through what they called the "people's power". The state situation and fact have clearly demonstrated that leaders of the opposition party have led their supporters on the path that is contradictory to the Constitution, existing laws and democratic principles.

In this context, the Cambodian People's Party, voted in by overwhelming majority to continue to lead the country, has been doing everything possible to safeguard the Constitution, the liberal and pluralistic democratic system, the National Assembly and the Royal Government established according to the elections, while allowing no reactionary forces to hold the country and people hostages. As of now, though the opposition party continues to boycott the National Assembly's sessions and negotiations between the two elected parties have reached no fruitful results, there has not been any political impasse in Cambodia. The monarchy, the legislative, the executive and the judicial institutions, ministries and authorities of all levels are functioning in normalcy. People are pursuing their daily life in regularity. Cambodia continues its active sustainability.

There is a saying that goes "dogs are barking and men are driving their carts, though." It is true that barking dogs would not be able to stop men from making their journey.

In the meantime, the Royal Government has numerous works of priority to fulfill in accordance with the demand for national development and people's aspiration. Under whatever situation or circumstance, the Royal Government must absolutely maintain political stability, security and social order through enforcing law strictly and actively participating with conscience from people aimed at guaranteeing continued socio-economic development. It is only by strengthening respect for and enforcement of rule of law, we will be able to guarantee that our nation continue to advance successfully, while preventing reactionary circles from destroying our country. If laws are not respected and/or implemented, what could be the foundation for guaranteeing political and social stability? It is true that the society would fall into anarchy; the development process would stop; national unity would damage; and the whole people of Cambodia, whatever political tendency they may belong to, would suffer immeasurable catastrophe.

Another urgent priority is to maintain macroeconomic stability, while preventing inflation and continuing to achieve economic growth. It is important to make every effort to collect revenue for national budget, both fiscal and non-fiscal ones,

បានឡើយ ។

ពេលនេះរាជរដ្ឋាភិបាលមានកិច្ចការជាអាទិភាពជាច្រើនដែលត្រូវអនុវត្តដើម្បីបំពេញតាមសំណូមពរនៃការអភិវឌ្ឍប្រទេសជាតិ និងបំណងប្រាថ្នារបស់ប្រជាជន ។ ទោះក្នុងស្ថានភាព និងកាលៈទេសៈណាក៏ដោយ រាជរដ្ឋាភិបាលត្រូវតែរក្សាឱ្យបានដាច់ខាតនូវស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម តាមរយៈការអនុវត្តច្បាប់ ឱ្យបានម៉ឺងម៉ាត់ និងការចូលរួមដ៏សកម្មប្រកបដោយការភ្ញាក់រឭកពីសំណាក់ប្រជាជន ដើម្បីធានាដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាបន្តទៀត ។ មានតែពង្រឹងការគោរព និងអនុវត្តច្បាប់ទេ ទើបធានាឱ្យសង្គមជាតិយើងបន្តឈានទៅមុខប្រកបដោយជោគជ័យ ព្រមទាំងរាំងស្កាត់មិនឱ្យមជ្ឈដ្ឋានប្រតិកិរិយាណាមកបំផ្លាញប្រទេសជាតិបាន ។ ប្រសិនបើច្បាប់មិនត្រូវបានគោរព និងអនុវត្ត តើមានអ្វីជាមូលដ្ឋានគ្រឹះសម្រាប់ធានាស្ថិរភាពនយោបាយ និងសង្គមនោះ ? ពិតប្រាកដណាស់ថាសង្គមនឹងធ្លាក់ទៅក្នុងភាពអនាធិបតេយ្យ ដំណើរការអភិវឌ្ឍន៍នឹងត្រូវបញ្ឈប់ ឯកភាពជាតិនឹងត្រូវបំផ្លាញ ហើយប្រជាជាតិទាំងមូល មិនថាអ្នកមាននិន្នាការនយោបាយណាឡើយនឹងទទួលរងនូវមហន្តរាយដែលពុំអាចប៉ាន់ប្រមាណបាន ។

កិច្ចការជាអាទិភាពមួយទៀតគឺការរក្សាឱ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់អតិផរណា និងបន្តជំរុញ កំណើនសេដ្ឋកិច្ច ។ ត្រូវខិតខំប្រមូលចំណូលចូលថវិកាជាតិ ទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ និងចាត់ចែងការចំណាយឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ។ គួរកត់សម្គាល់ថា ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ចំណូលពីផ្នែកពន្ធដារ និងផ្នែកគយមានការកើនឡើងយ៉ាងច្រើនដែលជាលទ្ធផលដ៏ល្អប្រសើរនៃដំណើរការកែទម្រង់ដ៏ដាច់ខាតរបស់រាជរដ្ឋាភិបាល ។ បណ្ដាមជ្ឈដ្ឋានប្រតិកិរិយាកំពុងតែសង្ឃឹមថាឧបាយកលរបស់ខ្លួននឹងទទួលបានជោគជ័យតាមរយៈការបង្កឱ្យមានអស្ថិរភាពនយោបាយ និងការធ្លាក់ចុះដោយគំហុកនៃវិស័យសេដ្ឋកិច្ច ដែលនឹងផ្ដល់ឱកាសដល់ពួកគេសម្រាប់ការផ្ដួលរំលំរាជរដ្ឋាភិបាល ។ ប៉ុន្តែឧបាយកលនេះនឹងមិនមានឱកាសបានសម្រេចឡើយ ពីព្រោះថា ដំណើរការសេដ្ឋកិច្ចនៅកម្ពុជាកំពុងបន្តរីកចម្រើន អ្នកវិនិយោគនៅតែបន្តដាក់ទុនរកស៊ីនៅកម្ពុជា ផលិតកម្មគ្រប់ផ្នែក និងសកម្មភាពធុរកិច្ចនានានៅតែមានដំណើរការជាធម្មតា ។ គួរកត់សម្គាល់ថា សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០១៣ មានកំណើន ៧,៦% ហើយសម្រាប់ឆ្នាំ ២០១៤ បណ្ដាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិសុទ្ធតែបានព្យាករណ៍ថា សេដ្ឋកិច្ចកម្ពុជានឹងនៅតែសម្រេចបានកំណើនជាង ៧% បន្តទៀត ។

ជាមួយនឹងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ត្រូវធ្វើប្រក្រតីកម្មជីវភាពរស់នៅរបស់ប្រជាជនដែលមានចំណូលតិចតួច ជាពិសេសអ្នករស់នៅក្នុងតំបន់ជួបប្រទះនូវគ្រោះធម្មជាតិដូចជាទឹកជំនន់ជាដើមដោយបង្កលក្ខណៈជូនប្រជាជនឱ្យមានលទ្ធភាពអាចស្តារផលិតកម្មវិញបានតាមរយៈការស្តារហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយទឹកជំនន់កាលពីរដូវវស្សា ការផ្ដល់ពូជស្រូវ និងជួយទំនុកបម្រុងដោះស្រាយកង្វះខាតស្បៀងជាដើម ។ ខិតខំកែលម្អការបើកបៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឱ្យបានទាន់ពេលវេលា និងមានតម្លាភាព ។ បន្តគិតគូរដោះស្រាយបញ្ហាបៀវត្សជូនកម្មករ និយោជិតតាមរោងចក្រសហគ្រាសឱ្យបានកាន់តែប្រសើរឡើងថែមទៀត ។ ព្រមជាមួយនេះត្រូវខិតខំជំរុញការកែទម្រង់នានាឱ្យកាន់តែសកម្ម ស៊ីជម្រៅ និងមានប្រសិទ្ធភាពពិតប្រាកដ តាមគោលនយោបាយដែលរាជរដ្ឋាភិបាលបានកំណត់រួចហើយ និងលុបបំបាត់នូវបាតុភាពអសកម្មនានាដែលធ្វើឱ្យប្រជាជនមានការថ្នាំងថ្នាក់ បាត់ជំនឿលើការដឹកនាំ ។ កិច្ចការដ៏សំខាន់មួយទៀត គឺការពង្រឹងវេទិកាសាធារណៈទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងលើគ្រប់វិស័យទាំងអស់ ដើម្បីស្ដាប់មតិ យោបល់ កង្វល់ ការថ្នាំងថ្នាក់ និងសំណូមពរផ្សេងៗរបស់ប្រជាជន កម្មករ កសិករ អាជីវករ យុវជន មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ដើម្បីបន្តដោះស្រាយ និងកែលម្អឱ្យបានជាក់ស្តែង ។ មន្ត្រីគ្រប់រូបគប្បីយល់ឱ្យបានច្បាស់ថា វេទិកាសាធារណៈ គឺប្រៀបដូចជាកញ្ចក់សម្រាប់ឆ្លុះឱ្យឃើញនូវចំណុចល្អ និងមិនល្អក្នុងការអនុវត្តនូវតួនាទី និងភារកិច្ចរបស់ផ្នែកនីមួយៗ និងថ្នាក់នីមួយៗ ដើម្បីកែលម្អឱ្យបានទាន់ពេលវេលា ហើយតាមរយៈវេទិកាសាធារណៈនេះនឹងពង្រឹងពង្រីកបាននូវការផ្សារភ្ជាប់រវាងមន្ត្រី និងប្រជាជននៅគ្រប់ស្រទាប់ គ្រប់មូលដ្ឋានឱ្យកាន់តែជិតស្និទ្ធថែមទៀត ។

លើមូលដ្ឋានប្រឹងប្រែងអនុវត្តឱ្យបានល្អនូវកិច្ចការជាអាទិភាពទាំងនេះ យើងពិតជារាំងស្កាត់បាននូវមហិច្ឆតាដ៏គ្រោះថ្នាក់របស់ក្រុមប្រឆាំង និងមជ្ឈដ្ឋានប្រតិកិរិយានានាដែលនឹងនៅតែបន្តរកគ្រប់វិធី ដើម្បីសម្រេចបំណងនៃការផ្លាស់ប្ដូររបស់ពួកគេ ។ ដូច្នេះយើងត្រូវរួមគ្នាអស់ពីកម្លាំងកាយ កម្លាំងចិត្ត ប្ដេជ្ញាការពាររាល់សមិទ្ធផលដ៏ធំធេងរបស់ជាតិដែលបានសម្រេចតាំងពីថ្ងៃរំដោះ៧មករា មកនិងខិតខំសម្រេចឱ្យបាននូវសមិទ្ធផលថ្មីៗទៀតក្នុងឆ្នាំ ២០១៤នេះ ក៏ដូចក្នុងនីតិកាលទី ៥ ទាំងមូល ។ នេះគឺជាការឆ្លើយតបពិតប្រាកដទៅនឹងឆន្ទៈរបស់ប្រជាជនកម្ពុជាភាគច្រើនលើសលប់ដែលបានសម្ដែងឡើងច្បាស់តាមរយៈសន្លឹកឆ្នោតនៅក្នុងការបោះឆ្នោតកន្លងមកនេះ ។/

**ទស្សនាវដ្ដីប្រជាជន**

while managing effective and efficient expenses with transparency and accountability. It is worth noting that over the past recent months, revenue generated from tax and excise has increased markedly proving a positive effort for absolute reform by the Royal Government.

Reactionary circles nurtured hope that their tricks would yield them a victory through stirring up political instability and sudden downturn of the economic sector, which would give them chance to bring down the Royal Government. The scheme did not work in their favor because the economic process in Cambodia continues to attain progress and investors continue to do businesses in Cambodia, while the Cambodian economy grew 7.6% in 2013, major international financial institutions predict that Cambodia's growth in 2014 would be 7%.

To maintain macro-economic stability, it is important to normalize the living condition of the people with minor income sources - especially those living in regions encountered with natural disasters - like flood for instance. Effort must be made to provide them with ability to restore their production, rehabilitating infrastructures damaged by the flood last year, and giving them rice seed and food in time of shortage, etc. The same should also be carried out so that the government officials and members of the armed forces would receive their salary in a timely manner and with transparency. Similar effort should be invested in solving salary problem for employees in factories and enterprises.

Continued to 10

# ទំនាក់ទំនងទ្វេភាគី កម្ពុជា_ឡាវ កាន់តែត្រូវបានពង្រឹង



*សម្ដេចតេជោ **ហ៊ុន សែន** ជួបពិភាក្សាការងារជាមួយ ឯកឧត្ដម **ថង ស៊ីញថាំម៉ាវង្ស** នាយករដ្ឋមន្ត្រីឡាវ*

ពីថ្ងៃទី ៦ ដល់ថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៤ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលជាទស្សនកិច្ចលើកទី ៥ របស់សម្ដេចនៅបរទេសបន្ទាប់ពីរាជរដ្ឋាភិបាលសម្រាប់រដ្ឋសភានីតិកាលទី ៥ ត្រូវបានបង្កើតឡើង ។

ក្នុងដំណើរទស្សនកិច្ចនោះ សម្ដេចតេជោ **ហ៊ុន សែន** បានជួបពិភាក្សាការងារជាមួយឯកឧត្ដម **ថង ស៊ីញថាំម៉ាវង្ស** នាយករដ្ឋមន្ត្រីឡាវ ។ ក្នុងជំនួបពិភាក្សាដ៏មានអត្ថន័យនោះ ឯកឧត្ដម **ថងស៊ីញ ថាំម៉ាវង្ស** នាយករដ្ឋមន្ត្រីឡាវមានប្រសាសន៍ថា ដំណើរទស្សនកិច្ចផ្លូវការរបស់សម្ដេចតេជោនាយករដ្ឋមន្ត្រីកម្ពុជាមកកាន់ប្រទេសឡាវនៅពេលនេះ គឺជាការបន្ដធ្វើវិភាគទានក្នុងការអភិវឌ្ឍ និងការពង្រឹងថែមទៀតនូវទំនាក់ទំនងទ្វេភាគីនៃប្រទេសទាំងពីរឡាវ-កម្ពុជា ។ នៅក្នុងជំនួបចរចាទ្វេភាគី ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរបានសម្ដែងនូវការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរកាលពីពេលកន្លងមក ។ ជាមួយគ្នានេះ ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរបានវាយតម្លៃខ្ពស់ចំពោះការតភ្ជាប់នូវខ្សែកាប្លឹ អុបទិក នៃប្រទេសទាំងពីរ ដែលនោះគឺជាការរួមចំណែកដល់ការពង្រីកទំនាក់ទំនង និងការតភ្ជាប់ប្រកបដោយភាពជិតស្និទ្ធរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋនៃប្រទេសទាំងពីរ ។

ទាក់ទងនឹងការជំរុញឱ្យមានការពង្រីកការហោះហើរត្រង់នៃប្រទេសទាំងពីរឱ្យមានចំនួនទ្វេដង សម្ដេចតេជោ បានស្នើឱ្យមានការបង្កើតឡើងនូវគណៈកម្មាធិការចម្រុះនៃប្រទេសទាំងពីរ ក្នុងការកសាងស្ពានឆ្លងកាត់ប្រទេសទាំងពីរក្នុងភូមិសាស្ត្រខេត្តព្រះវិហារកម្ពុជា ជាមួយខេត្តចំប៉ាសាក់របស់ប្រទេសឡាវ ដែលកិច្ចការដ៏មាន សារៈសំខាន់នេះ ថ្នាក់ដឹកនាំទាំងពីរបានប្រគល់ភារកិច្ចឱ្យរដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរធ្វើការពិភាក្សាគ្នាបន្ដ ។ សម្ដេចនាយករដ្ឋមន្ត្រីក៏បានស្នើដល់សមភាគីឡាវធ្វើយ៉ាងណាជំរុញឱ្យមានការដឹកជញ្ជូនតាមផ្លូវគោកឱ្យកាន់តែមានចំនួនច្រើនជាងមុនក្នុងន័យជំរុញកំណើននៃវិស័យទេសចរណ៍ និងការដឹកជញ្ជូនពាណិជ្ជកម្ម ។ សម្ដេចតេជោបានស្វាគមន៍នូវសេចក្ដីសម្រេចរបស់ប្រទេសឡាវក្នុងការបង្កើតការិយាល័យអគ្គកុងស៊ុលរបស់ប្រទេសឡាវក្នុងខេត្តសៀមរាប ។ ក្នុងជំនួបនោះ ប្រមុខថ្នាក់ដឹកនាំទាំងពីរបានពិភាក្សាគ្នាផងដែរពីការជំរុញឱ្យគណៈកម្មការព្រំដែននៃប្រទេសទាំងពីរធ្វើការបោះបង្គោលព្រំដែននៃប្រទេសទាំងពីរឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន។ សម្ដេចតេជោក៏បានស្នើដល់សមភាគីឡាវធ្វើយ៉ាងណាជំរុញទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរឱ្យមានការកើនឡើងទ្វេដង ពោលគឺទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរដែលមានត្រឹមតែប្រមាណ ១០ លានដុល្លារក្នុងឆ្នាំ ២000 ឱ្យកើនដល់ ២០ លានដុល្លារនៅឆ្នាំ ២០១៤ ឬឆ្នាំ ២០១៥ ខាងមុខនេះ។

ក្នុងជំនួបពិភាក្សាដ៏មានសារៈសំខាន់នោះ ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរក៏បានពិភាក្សាគ្នាយ៉ាងស៊ីជម្រៅទាក់ទិនទៅនឹងការជំរុញកិច្ចសហប្រតិបត្តិការទប់ស្កាត់ការជួញដូរគ្រឿងញៀន និងការកាប់ឈើខុសច្បាប់នៅតាមព្រំដែននៃប្រទេសទាំងពីរ តាមរយៈការជំរុញឱ្យមានការបង្កើនកិច្ចសហប្រតិបត្តិការនៃអាជ្ញាធរខេត្តតាមព្រំដែន ពិសេសការឯកភាពគ្នាក្នុងការបង្កើតឡើងនូវសម្ព័ន្ធមេត្រីភាពរវាងទីក្រុង និងទីក្រុង ខេត្ត និងខេត្ត ។ ជាមួយគ្នានេះប្រមុខរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរក៏បានធ្វើការពិភាក្សាគ្នាផងដែរ ទាក់ទិនទៅនឹងការជំរុញ កិច្ចសហប្រតិបត្តិការនៃតំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម តំបន់ត្រីកោណមរកតកម្ពុជា-ឡាវ-ថៃ កិច្ចសហប្រតិបត្តិការនៃប្រទេសអេកម៉ិក-មេគង្គ និងបញ្ហាដទៃទៀតដែលមានផលប្រយោជន៍សម្រាប់ប្រជាជាតិនៃប្រទេសទាំងពីរ ។

ក្នុងជំនួបពិភាក្សានោះ ឯកឧត្ដមនាយករដ្ឋមន្ត្រីឡាវមានប្រសាសន៍ថា ប្រទេសឡាវនឹងបន្ដសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយភាគីកម្ពុជា ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងពាណិជ្ជកម្មនៃប្រទេសទាំងពីរ ដែលតាមរយៈនេះភាគីឡាវនឹងជំរុញឱ្យការនាំចូលប្រភពថាមពលអគ្គិសនីពីឡាវមកកាន់ប្រទេសកម្ពុជាឱ្យមានការកើនឡើងពី ១១៥ គីឡូវ៉ុល ដល់ ១៣០ គីឡូវ៉ុល រួមទាំងការកសាងបណ្ដាញបញ្ជូនអគ្គិសនីឱ្យកាន់តែទូលំទូលាយថែមទៀត។ ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរក៏បានពិភាក្សាលើបញ្ហាសង្គម វប្បធម៌ សិល្បៈ សុខាភិបាល និងការបណ្ដុះបណ្ដាលធនធានមនុស្សតាមរយៈការជំរុញឱ្យមានការផ្លាស់ប្ដូរនិស្សិតអាហារូបករណ៍នៃប្រទេសទាំងពីរ។

ឯកសារ និងកិច្ចព្រមព្រៀងសំខាន់ៗចំនួន ៧ ត្រូវបានចុះហត្ថលេខាក្រោមអធិបតីភាពសម្ដេចតេជោ **ហ៊ុន សែន** និងឯកឧត្ដម **ថងស៊ីញ ថាំម៉ាវង្ស** រួមមាន ទី ១ អនុស្សរណៈនៃការយោគយល់គ្នាស្ដីពីការបង្កើតអគ្គកុងស៊ុលរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ទី ២ កិច្ចព្រមព្រៀង ស្ដីពីវិស័យអប់រំសម្រាប់ឆ្នាំ ២០១៤-២០១៨ ទី ៣ កិច្ចព្រមព្រៀងស្ដីពីការបង្កើតចំណងសម្ព័ន្ធមេត្រីភាពរវាងរាជធានីភ្នំពេញ និងរដ្ឋធានីវៀងចន្ទន៍ ទី ៤ អនុស្សរណៈនៃការ

យោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់ និងយុត្តិធម ទី ៥ អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌ និងសិល្បៈសម្រាប់ឆ្នាំ ២០១៤-២០១៧ ទី ៦ អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិអភិវឌ្ឍន៍វិស័យសុខាភិបាល និងទី ៧ ផែនការកិច្ចសហប្រតិបត្តិការសម្រាប់ឆ្នាំ ២០១៤ រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខនៃសាធារណរដ្ឋប្រជាធិប-តេយ្យប្រជាមានិតឡាវ ។

ក្នុងឱកាសនៃការបំពេញទស្សនកិច្ចផ្លូវការនៅទីក្រុងវៀងចន្ទន៍នេះដែរ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម **ជុំម៉ាលី សាយ៉ាសន** អគ្គលេខាមជ្ឈិមបក្សប្រជាជនបដិវត្តឡាវ និងជាប្រមុខរដ្ឋនៃសាធារណ-រដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅវិមានរដ្ឋ ។ ឯកឧត្តម **ជុំម៉ាលី សាយ៉ាសន** បានសម្តែងការអបអរសាទរជូនចំពោះគណបក្សប្រជាជនកម្ពុជាដែលទទួលបានជោគជ័យដ៏ត្រចះត្រចង់ពីការបោះឆ្នោតសកលកាលពីពេលថ្មីៗកន្លងទៅ ពិសេសឯកឧត្តមសូមចូលរួមអបអរសាទរចំពោះសម្តេចតេជោនាយករដ្ឋមន្ត្រីដែលត្រូវបានតែងតាំងជាថ្មីជានាយករដ្ឋមន្ត្រីក្នុងការដឹកនាំរាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភាពីឆ្នាំ ២០១៣ ដល់ ២០១៨ ។ ឯកឧត្តមប្រធានរដ្ឋបានចូលរួមអបអរ សាទរចំពោះជោគជ័យនៃកិច្ចពិភាក្សា ដែលប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរបានធ្វើការពិភាក្សាយ៉ាងស្មោះអស់ពីចិត្ត ក្នុងដំណើរទស្សនកិច្ចរបស់សម្តេចតេជោមកកាន់ប្រទេសឡាវនាឱកាសនេះ ។ ឯកឧត្តមបានសម្តែងនូវជំនឿជាក់ថា តាមរយៈដំណើរទស្សនកិច្ចរបស់សម្តេចមកកាន់ប្រទេសឡាវនៅពេលនេះ នឹងពិតជារួមចំណែកពង្រឹងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនទៅឡើងថែមទៀត ។

សម្តេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា ការចុះហត្ថលេខាលើឯកសារសំខាន់ៗចំនួន ៧ ក្នុងដំណើរទស្សនកិច្ចរបស់សម្តេចមកកាន់ប្រទេសឡាវនៅពេលនេះនឹងជំរុញទំនាក់ទំនងប្រទេសទាំងពីរឱ្យកាន់តែមានភាពរីកចម្រើនទៅឡើងថែមទៀត ពិសេសនៅក្នុងឆ្នាំ ២០១៤ នេះ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរនឹងធ្វើកិច្ចការ ជាមួយគ្នាលើកិច្ចការជាច្រើនក្នុងកម្រិតរដ្ឋមន្ត្រីការបរទេស ក្នុងនោះរួមទាំងការប្រជុំរបស់គណៈកម្មការព្រំដែននៃប្រទេសទាំងពីរផងដែរ ។ ក្នុងជំនួបនោះដែរ សម្តេចតេជោនាយករដ្ឋ-មន្ត្រីក្នុងព្រះបរមនាមព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចសូមគោរពអញ្ជើញឯកឧត្តមប្រធានរដ្ឋឡាវមកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅប្រទេសកម្ពុជា សំដៅធ្វើយ៉ាងណាជំរុញទំនាក់ទំនងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឈានដល់ចំណុចខ្ពស់ថ្មីមួយទៀតសម្រាប់ប្រជាជាតិនៃប្រទេសទាំងពីរកម្ពុជា-ឡាវ ។

ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកជំទាវ **ផានី យ៉ាថូរ** សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្ស និងជាប្រធានសភាជាតិឡាវនៅវិមានសភាឡាវ សម្តេចតេជោបានពាំនាំនូវការជូនពរពីសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ជូនចំពោះលោកជំទាវប្រធានសភាឡាវ និងថ្លែងនូវអំណរគុណចំពោះថ្នាក់ដឹកនាំ



*សម្តេចតេជោ **ហ៊ុន សែន** ជួបពិភាក្សាការងារជាមួយ លោកជំទាវ **ផានី យ៉ាថូរ***

សភាឡាវ ដែលបានគាំទ្រចំពោះគម្រោងនានារបស់រដ្ឋាភិបាលឡាវ ដែលជំរុញឱ្យមានការចុះហត្ថលេខាលើឯកសារសំខាន់ៗចំនួន ៧ ក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់សម្តេចមកកាន់ប្រទេសឡាវនៅពេលនេះ ។សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានជម្រាបជូនលោកជំទាវប្រធានសភាពីគម្រោងនៃការតភ្ជាប់ស្ពានឆ្លងកាត់ប្រទេសទាំងពីរដែលនោះ គឺជាចំណុចចាប់ផ្តើមថ្មីមួយទៀតដែលមិនធ្លាប់មានពីមុនសម្រាប់ប្រទេសទាំងពីរ ។ ដោយសារតែប្រទេសឡាវគឺជាធុងអាគុយនៃប្រទេសអាស៊ាននោះ សម្តេចតេជោមានប្រសាសន៍ពីគោលបំណងនៃការទិញថាមពលអគ្គិសនីពីប្រទេសឡាវបន្ថែមទៀត ដើម្បីបម្រើដល់ការអភិវឌ្ឍក្នុងខេត្តស្ទឹងត្រែង និងខេត្តព្រះវិហាររបស់ប្រទេសកម្ពុជាឱ្យកាន់តែមាននិរន្តរភាពទៀត ។

លោកជំទាវប្រធានសភាឡាវ បានវាយតម្លៃខ្ពស់បំផុតចំពោះដំណើរទស្សនកិច្ចរបស់សម្តេចមកកាន់ប្រទេសឡាវនៅពេលនេះ ។ លោកជំទាវមានប្រសាសន៍បន្តថា ក្នុងនាមសភា និងប្រជាជនឡាវ លោកជំទាវសូមសម្តែងនូវការគាំទ្រ និងចូលរួមអបអរសាទរជូនចំពោះសម្តេចតេជោដែលត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីនឹងទទួលបាននូវការអភិវឌ្ឍរីកចម្រើនខ្ពង់ខ្ពស់ថែមទៀត ។ ជាមួយគ្នានេះតាមរយៈដំណើរទស្សនកិច្ចរបស់សម្តេចតេជោនៅលើទឹកដីឡាវនាពេលនេះនឹងធ្វើឱ្យទំនាក់ទំនងនៃប្រទេសទាំងពីរឈានឆ្ពោះទៅកាន់កម្រិតថ្មីមួយទៀត ។

ក្នុងពេលនិវត្តមកដល់មាតុប្រទេស ឯកឧត្តម **កៅ គីមហួន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីបានមានប្រសាសន៍អំពីជោគជ័យនៃដំណើរទស្សនកិច្ចរបស់សម្តេចតេជោ **ហ៊ុន សែន** នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។ ឯកឧត្តមបានមានប្រសាសន៍ទៀតថា គណៈកម្មការសម្របសម្រួលព្រំដែនកម្ពុជា-ឡាវ គ្រោងធ្វើការប្រជុំនៅថ្ងៃទី ២១ និង ២២ ខែកុម្ភៈ ឆ្នាំ ២០១៤ នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើយ៉ាងណាឱ្យការបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរដែលមានប្រវែង ៥៤០ គីឡូ-ម៉ែត្របានបញ្ចប់នៅពេលខាងមុខនេះ ។ ឯកឧត្តមបានបញ្ជាក់ថា មកដល់ពេលនេះប្រទេសទាំងពីរបានធ្វើការបោះបង្គោលព្រំដែនបានចំនួន ១២១ កន្លែងរួចហើយ ។/

# សម្តេចតេជោ : ភាពជិតស្និទ្ធរវាងប្រជាពលរដ្ឋ និងអ្នកបម្រើប្រជាពលរដ្ឋ គឺកើតមានឡើងតាមរយៈការដែលយើងដាក់ខ្លួនជាខ្ញុំបម្រើពិតប្រាកដរបស់គាត់



*សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញជាអធិបតីក្នុងពិធីចែកសញ្ញាប័ត្រ ជូនដល់និស្សិត ជ័យលាភីថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង*

*នាខែកុម្ភៈឆ្នាំ ២០១៤ កន្លងទៅនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីសំខាន់ៗមួយចំនួនដែលទាក់ទងទៅនឹងវិស័យបណ្តុះបណ្តាលធនធានមនុស្ស និងអាជ្ញាធរដែនដី ។ នៅក្នុងជំនួបជាមួយសិស្ស និស្សិត និងមន្ត្រីរាជការទាំងឡាយ សម្តេចបានលើកឡើងអំពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាល និងអនុសាសន៍មួយចំនួនដើម្បីជំរុញប្រព័ន្ធការងារនៃវិស័យនីមួយៗ ។*

-ព្រឹកថ្ងៃទី ១០ ខែកុម្ភៈ សម្តេចតេជោ **ហ៊ុន សែន** បានអញ្ជើញជាអធិបតីភាពក្នុងពិធីចែកសញ្ញាប័ត្រជូន ដល់និស្សិតជ័យលាភីថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ចំនួន ៤ ១០១ នាក់ ដែលប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលសន្និបាតកោះពេជ្រ ។ នាទីនោះសម្តេចបានជំរុញឱ្យមានការលើកកម្ពស់គុណភាពសិក្សានៅឧត្តមសិក្សាដើម្បីបង្កើននូវធនធានមនុស្សរបស់ប្រទេសសម្រាប់ការឈានចូលប្រកួតប្រជែងនៅពេលកម្ពុជាធ្វើសមាហរណកម្មក្នុងសហគមន៍អាស៊ានដែលនឹងកើតឡើងក្នុងរយៈពេល ២ ឆ្នាំខាងមុខ ។

សម្តេចតេជោបានមានប្រសាសន៍ថា ការបណ្តុះបណ្តាលនិស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនគឺជានយោបាយបើកទូលាយរបស់រាជរដ្ឋាភិបាលដើម្បីឆ្លើយតបទៅនឹងកំណើនសិស្ស ។ កម្ពុជាមិនអាចអនុវត្តនូវនយោបាយកំណត់ចំនួនសម្រាប់និស្សិតនៅឧត្តមសិក្សាដូចនៅប្រទេសផ្សេងបានទេដោយសារថា ចំនួនសិស្សប្រឡងបាក់ឌុបក្នុងមួយឆ្នាំៗមានជាងដប់ម៉ឺននាក់ ។ បើកំណត់យកត្រឹមមួយឆ្នាំបីពាន់នាក់ តើដប់ម៉ឺននាក់ទៀតទៅរៀននៅទីណា? ។ ដូចនេះរាជរដ្ឋាភិបាលមានតែប្រកាន់យកនយោបាយបើកទូលាយចំពោះវិស័យឧត្តមសិក្សា ។ តែបញ្ហាសំខាន់នៅទីនេះគឺការលើកកម្ពស់គុណភាពអប់រំនៅឧត្តមសិក្សា ។ សម្តេចបន្តថា ជាការពិតបរិមាណវា ដើរទន្ទឹមគ្នានឹងគុណភាព ។ មុននឹងឈានទៅរកគុណភាពបានចាំបាច់ត្រូវមានបរិមាណជាមុន" ។ ការងារបណ្តុះបណ្តាលគឺនៅមានការងារជាច្រើនទៀតដែលក្រសួងត្រូវខិតខំប្រឹងប្រែង ជាពិសេសអំពីគុណភាពអប់រំគុណភាពនៃការបណ្តុះបណ្តាល ហើយការងារនេះក៏មិនអាចកាត់ផ្តាច់ពីការចូលរួមរបស់វិស័យឯកជនបានដែរ ។

សម្តេចក៏បានរំលឹកអំពីអតីតកាលខ្លះរបស់កម្ពុជា ក្នុងវិស័យអប់រំផងដែរដោយមានប្រសាសន៍ថា សិស្ស និស្សិត យើងសព្វថ្ងៃនេះមានឱកាសច្រើនក្នុងការសិក្សារៀនសូត្រ បើប្រៀបធៀបទៅនឹងកាលពីអតីតកាលជាពិសេសក្នុងរបបខ្មែរក្រហមនិងក្នុងអំឡុងឆ្នាំ១៩៧៩-១៩៩៨ ។នាពេលនោះសិស្សនិស្សិតពុំមានឱកាសគ្រប់គ្រាន់ក្នុងការសិក្សារៀនសូត្រឡើយព្រោះពេលនោះយុវជនយើងនៅតំបន់ខ្លះដែលដៃរបស់ពួកគេគួរត្រូវបានកាន់ប៊ិច ដីស សៀវភៅ ដើម្បីសិក្សារៀនសូត្រ ប៉ុន្តែបែរជាកាន់កាំភ្លើងទៅវិញ ។ ទើបតែនៅ ឆ្នាំ ១៩៩៨ បន្ទាប់ពីនយោបាយឈ្នះឈ្នះបានជោគជ័យដែលធ្វើឱ្យអង្គការចាត់តាំងនយោបាយ និងយោធារបស់ប៉ុលពតបានដួលរលំទាំងស្រុង ហើយប្រទេសជាតិបានទទួលសន្តិភាពពេញលេញទើបយុវជនយើងមានឱកាសពេញលេញបានសិក្សារៀនសូត្រដល់សព្វថ្ងៃនេះ ។

ក្នុងពិធីនេះសម្តេចនាយករដ្ឋមន្ត្រីក៏បានបង្ហាញពីកំណែទម្រង់ក្នុងវិស័យឧត្តមសិក្សា ដោយបានផ្តល់នូវការទទួលខុសត្រូវចំពោះគុណភាពអប់រំនៅតាមឧត្តមសិក្សាទៅឱ្យសាកលវិទ្យាធិការនៃសាកលវិទ្យាល័យនីមួយៗ ទាំងរដ្ឋ និងឯកជន ចំពោះសញ្ញាបត្រដែលខ្លួនបានចេញឱ្យនិស្សិតនៅពេលបញ្ចប់ការសិក្សា គឺមិនចាំបាច់មានការចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងអប់រំអមជាមួយទៀតទេ ។ សម្តេចបានលើកឡើងថា កន្លងមកសញ្ញាបត្ររបស់និស្សិតដែលបានបញ្ចប់ការសិក្សារួច គឺមានហត្ថលេខារបស់សាកលវិទ្យាធិការផង និងរបស់រដ្ឋមន្ត្រីអមជាមួយផង ដែលនេះជាការទម្លាក់ការទទួលខុសត្រូវនេះទៅលើរដ្ឋមន្ត្រីក្រសួងអប់រំ និងរាជរដ្ឋាភិបាលក្នុងការទទួលខុសត្រូវលើគុណភាពអប់រំដែលបានបណ្តុះបណ្តាល ។ តែចាប់ពីពេលនេះតទៅគឺលែងឱ្យមានទៀតហើយ ។

បើតាមការបញ្ជាក់របស់បណ្ឌិត **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ



*និស្សិតជ័យលាភីថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង*

យុវជន និងកីឡាបានឱ្យដឹងថា បច្ចុប្បន្នកម្ពុជាមានគ្រឹះស្ថានឧត្តមសិក្សាសរុបចំនួន ១០៤ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋមានចំនួន ៣៩ និងឯកជនចំនួន ៦៥ និងមាននិស្សិតថ្នាក់បរិញ្ញាបត្ររង ដល់បណ្ឌិត មានចំនួន ២២២ ១៦៤ នាក់ ។ ជាមួយគ្នានេះ ក៏មានអន្តេវាសិកដ្ឋានចំនួន ៧ ខ្នង នៅរាជធានីភ្នំពេញ និងមាននិស្សិតកំពុងស្នាក់នៅប្រមាណ ៨០៤ នាក់ ក្នុងនោះ ស្រី ៥៧៣ នាក់ និងមាននិស្សិតបរទេស ១៤០ នាក់ ។

-ព្រឹកថ្ងៃទី១៧ ខែកុម្ភៈ សម្ដេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** បានអញ្ជើញចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់កំណែទម្រង់រដ្ឋ សិស្សមន្ត្រីក្រមការជំនាន់ភក្ដីភាព និងវិញ្ញាបនបត្រដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ មន្ត្រីមធ្យមឆ្នាំ២០១៣ និងបើកវគ្គបណ្ដុះបណ្ដាល និងវិក្រិតការឆ្នាំ ២០១៤ នៃសាលាភូមិន្ទរដ្ឋបាល ។ ពិធីនេះបានប្រារព្ធធ្វើនៅវិទ្យាស្ថានជាតិអប់រំ ។ នៅទីនោះសម្ដេចបានលើកឡើងនូវបញ្ហាសំខាន់ៗចំនួន ៦ ដែលត្រូវយកចិត្តទុកដាក់ ។

សម្ដេចបានមានប្រសាសន៍ថាបញ្ហាសំខាន់ទី ១ គឺ បន្តដំណើរការជាធម្មតានៃស្ថាប័នរដ្ឋ ទាំងផ្នែកនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ។ សម្ដេចបញ្ជាក់ថាចង់អ្នកណានិយាយអ្វីក៏និយាយទៅ យើងមិនខ្វល់ទេ បញ្ហាសំខាន់របស់យើងគឺដំណើរការជាធម្មតានៃស្ថាប័នរដ្ឋទាំងអស់ ។ បញ្ហាសំខាន់ទី ២ គឺត្រូវរក្សាឱ្យបាននូវស្ថិរភាពនយោបាយ សន្តិសុខ សណ្ដាប់ធ្នាប់សង្គម ដែលត្រូវមានការអនុវត្តច្បាប់ និងការចូលរួមរបស់ប្រជាជនផង ។ ប្រជាជនត្រូវការសប្បាយរីករាយ និងប្រកបរបរចិញ្ចឹមជីវិតដោយសុខសាន្ត ។ មិនមែនត្រូវការភាពចលាចលនោះទេ ។ ដូចនេះត្រូវធានាសន្តិសុខ សណ្ដាប់ធ្នាប់ជូនប្រជាពលរដ្ឋឱ្យបានល្អ ។ អ្នកណាបំផ្លាញសន្តិសុខ សណ្ដាប់ធ្នាប់សង្គម ត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ ។ បញ្ហាសំខាន់ទី ៣ ត្រូវរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយត្រូវរក្សានូវកំណើនសេដ្ឋកិច្ច និងទប់ស្កាត់អតិផរណា ។ ស្ថាប័នរូបិយវត្ថុអន្តរជាតិ មានធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការរូបិយវត្ថុអន្តរជាតិ សុទ្ធតែបានវាយតម្លៃថាសេដ្ឋកិច្ចរបស់កម្ពុជាមានកំណើនលើស ៧% ។ យោងតាមលទ្ធផលនៃការបង្កបង្កើនផលបានបង្ហាញថាដំណាំស្រូវសម្រេចបាន ១១១% ។ នេះជាការចូលរួមជំរុញកំណើនសេដ្ឋកិច្ច ។ ជាមួយនេះយើងក៏ត្រូវជំរុញបង្កើនប្រាក់ចំណូល និងធ្វើវិចារណកម្មលើការចំណាយ ។ ការរក្សាម៉ាក្រូសេដ្ឋកិច្ចឱ្យមានស្ថិរភាពគឺសំខាន់ណាស់ ។ ដូចនេះរាល់ការចំណាយ និងចំណូលត្រូវតែមានទំហំប៉ុនគ្នា តែបើរក្សាបានអតិរេកនោះ វាកាន់តែល្អថែមទៀត ។

គួរបញ្ជាក់ថាពាក់ព័ន្ធនឹងចំណូល ចំណាយនេះ សម្ដេចបានលើកឡើងថាបញ្ហានេះក៏ពាក់ព័ន្ធផងដែរទៅដល់ការដំឡើងប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ។ រាជរដ្ឋាភិបាលចង់ដំឡើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការឱ្យបានច្រើនក៏ប៉ុន្តែយើងមិនអាចដំឡើងលើសពីសមត្ថភាពបានទេ ។ សម្ដេចបានបញ្ជាក់ថាលើពិភពលោកនេះគ្មានប្រទេសណាមួយខ្ចីប្រាក់ពីបរទេសមកបើកប្រាក់ខែនោះទេ ហើយក៏មិនមានអ្នកណាផ្ដល់ជំនួយសម្រាប់បើកប្រាក់ខែដែរ ។ ដូចនេះមានតែជម្រើសពីរដែលអាចធ្វើទៅបានគឺកាត់បន្ថយបុគ្គលិកចំនួនពាក់កណ្ដាល ឬមួយភាគបីចេញ ។ តែបើកាត់បន្ថយមន្ត្រីរាជការវានាំទៅដល់សម្ពាធនៃការគ្មានការងារធ្វើ ។ ជម្រើសមួយទៀតគឺបោះពុម្ពសាច់ប្រាក់បន្ថែម ។ តែបញ្ហានេះកាន់តែគ្រោះថ្នាក់ថែមទៀត ។ ដូចនេះ វាទាមទារឱ្យមានការផ្ទៀងផ្ទាត់ចំណូល និងចំណាយ រាប់ទាំងការគ្រប់គ្រងសាច់ប្រាក់នៅលើទីផ្សារផងដែរ ដើម្បីកុំឱ្យមានអតិផរណាខ្ពស់ហើយក៏ត្រូវគ្រប់គ្រងតម្លៃប្រាក់រៀលកុំឱ្យថ្លៃពេក តែក៏មិនត្រូវឱ្យថោកពេកដែរ ។ រាជរដ្ឋាភិបាលចង់ឱ្យប្រាក់រៀលស្ថិតក្នុងតម្លៃ ៤ ០៥០ រៀល ក្នុង ១ ដុល្លារអាមេរិក ។

ជាមួយគ្នានេះ សម្ដេចក៏បានជំរុញឱ្យមានការបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការឱ្យបានទាន់ពេលវេលា ។ សម្ដេចបានលើកឡើងថាប្រាក់ខែតិចហើយត្រូវបើកឱ្យទាន់ពេលវេលា ។ កុំឱ្យប្រាក់ខែតិចហើយបើកយឺតទៀតនោះវាជាបញ្ហា ព្រោះមន្ត្រីរាជការត្រូវការចាយវាយប្រចាំខែបង់ថ្លៃទឹកថ្លៃភ្លើង ។ ការបើកប្រាក់បៀវត្សរ៍នៅក្នុងអាណត្តិថ្មីនេះក៏ជាកំណែទម្រង់ដ៏ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលផងដែរ ។

សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៤ បានចេញសារាចរណែនាំមួយ ជំរុញឱ្យក្រសួងពាក់ព័ន្ធផ្លាស់ប្ដូរស្ថានភាពរដ្ឋបាល និងគ្រួសារមន្ត្រីរាជការក្នុងតារាងទូទាត់បៀវត្សរ៍ប្រចាំខែនីមួយៗ ផ្ដល់តារាងទូទាត់បៀវត្សរ៍ប្រចាំខែនិងតារាងកាត់ពន្ធលើបៀវត្សរ៍ប្រចាំខែដល់ក្រសួងស្ថាប័នសាលារាជធានីភ្នំពេញ ខេត្ត មន្ទីរ និងអង្គភាពចំណុះ រៀបចំអាណត្តិបើកប្រាក់បៀវត្សរ៍ប្រចាំខែ ការពិនិត្យ និងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សរ៍ប្រចាំខែ គណនេយ្យភាព និងការទទួលខុសត្រូវ ។

សម្ដេចបានបន្តថា បញ្ហាទី ៤ គឺត្រូវធ្វើឱ្យមានប្រក្រតីកម្មជីវភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជន ។ ក្រោយការវាយប្រហារដោយទឹកជំនន់ដ៏ធំនៅឆ្នាំ ២០១៣ កន្លងទៅ បានបង្កឱ្យមានការលំបាកយ៉ាងច្រើនចំពោះរាជរដ្ឋាភិបាល ដែលត្រូវខិតខំស្ដារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធមានផ្លូវថ្នល់ ប្រឡាយទឹក និងផ្ទះសម្បែងប្រជាជន ។ សម្ដេចបញ្ជាក់ថា បញ្ហាសំខាន់មួយទៀតគឺត្រូវជួយប្រជាជននៅតំបន់ដែលរងគ្រោះដោយសារទឹកជំនន់ ក្នុងការបង្កបង្កើនផលឡើងវិញឱ្យបានទាន់រដូវកាល ។ បញ្ហាទី ៥ ត្រូវយកចិត្តទុកដាក់ចំពោះជីវភាពមន្ត្រីរាជការ កងកម្លាំង ប្រដាប់អាវុធ និងកម្មករ កម្មការិនី ដែលត្រូវគិតគូរដំឡើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការឱ្យសមស្របទៅនឹងទំហំថវិកាជាតិដែលមាន ។ ការឡើងប្រាក់ខែមិនអាចធ្វើលើសពីលទ្ធភាពថវិកាជាតិបានទេទោះអ្នកណាចង់ធ្វើប្រជាភិថុតិបែបណាវាគ្រាន់តែជាការសន្យាខ្យល់ប៉ុណ្ណោះ ។ រាជរដ្ឋាភិបាលចង់ឱ្យមន្ត្រីរាជការរបស់ខ្លួនមានប្រាក់ខែច្រើន ក៏ប៉ុន្តែវាអាស្រ័យលើលទ្ធភាព ។ ពាក់ព័ន្ធកម្មករក៏ដូច្នេះដែរ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មការមួយដើម្បីពិនិត្យមើលការដំឡើងប្រាក់ខែឱ្យដល់កម្មករ ដោយមានឧបនាយករដ្ឋមន្ត្រីប្រចាំការមួយរូបជាអ្នកពិនិត្យវាយតម្លៃ ។ បញ្ហាទី ៦ ជំរុញឱ្យមានការកែទម្រង់លើគ្រប់វិស័យឱ្យបានស៊ីជម្រៅបំផុត ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ សម្រេចបានជោគជ័យ ។

ពាក់ព័ន្ធនឹងបញ្ហាទី ៦ នេះដែរ សម្ដេចបានបញ្ជាក់ថា រាជរដ្ឋាភិបាលកំពុងតែជួបបញ្ហាវិបត្តិមន្ត្រីបន្តវេន ដែលនៅពេលខាងមុខនេះ មន្ត្រីជា




*សម្តេចតេជោនាយករដ្ឋមន្ត្រីផ្តល់អនុសាសន៍ក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា២០១៤-២០១៨*

ច្រើននឹងត្រូវដល់អាយុចូលនិវត្តន៍ ពិសេសអភិបាលខេត្តជាច្រើននឹងត្រូវធ្វើការផ្លាស់ប្តូរនាពេលខាងមុខដោយសារតែដល់អាយុចូលនិវត្តន៍ ។ហេតុដូចនេះហើយទើបរាជរដ្ឋាភិបាលអាណត្តិទី ៥ នេះបានបញ្ចូលមន្ត្រីវ័យក្មេងទៅក្នុងជួររាជរដ្ឋាភិបាលមានរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ។ប៉ុន្តែសម្តេចបានពន្យល់ថា យើងមិនដាក់តែមន្ត្រីវ័យក្មេង ដោយគ្មានមន្ត្រីវ័យចំណាស់នោះទេ ។ ត្រូវតែមានការបញ្ចូលគ្នា ដោយការធ្វើសុខដុមបនីយកម្មបីជំនាន់បញ្ចូលគ្នា គឺមានមន្ត្រីវ័យចំណាស់ មន្ត្រីវ័យមធ្យម និងមន្ត្រីវ័យក្មេង ដើម្បីឱ្យការងារដំណើរការទៅមុខដោយរលូន និងប្រកបដោយប្រសិទ្ធភាព ។

-ព្រឹកថ្ងៃទី ១៧ ខែកុម្ភៈ សម្តេចតេជោនាយករដ្ឋមន្ត្រីបានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា២០១៤-២០១៨ ដែលប្រារព្ធធ្វើនៅវិមានសន្តិភាព ។ នាពេលនោះសម្តេចប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ថា កម្ពុជាត្រូវបន្តដំណើរទៅមុខយ៉ាងស្វាហាប់ឆ្ពោះទៅរកវឌ្ឍនភាពរុងរឿងប្រកបដោយភាពប្រាកដនិយម ។ ឈរលើមូលដ្ឋាននេះកម្ពុជាត្រូវធ្វើសមាហរណកម្មដើម្បីឱ្យកម្ពុជាមានមូលដ្ឋានកំណើនជាប្រព័ន្ធមានលក្ខណៈប្រទាក់ក្រឡាគ្នា ស៊ីសង្វាក់គ្នា និងទូលំទូលាយជាងមុន ។យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មរបស់កម្ពុជា ២០១៤-២០១៨ នឹងក្លាយជាផែនទីបង្ហាញផ្លូវចំពោះរាល់ សកម្មភាពពាក់ព័ន្ធវិស័យពាណិជ្ជកម្ម និងកិច្ចការគាំទ្រមួយចំនួនផ្សេងៗទៀត ។

សម្តេចបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាកំពុងប្តេជ្ញាចិត្តពង្រីកមូលដ្ឋានកំណើនរបស់ខ្លួនជាបន្តទៀត ។ ក្នុងនោះរាជរដ្ឋាភិបាលកំពុងបន្តពង្រឹងអភិបាលកិច្ចល្អ បង្កើនខ្សែសង្វាក់តម្លៃរបស់ខ្លួនចូលរួមនៅក្នុងខ្សែសង្វាក់តម្លៃថ្នាក់តំបន់ និងបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់វិស័យឯកជនដើម្បីទាក់ទាញការវិនិយោគ និងធានាភាពប្រកួតប្រជែងរបស់ខ្លួន ។ យុទ្ធសាស្ត្រសមាហរណកម្មនេះ បានកំណត់ពីអាទិភាពជាក់លាក់នានា សម្រាប់ធ្វើអន្តរាគមន៍ជាបន្ទាន់ហើយក៏បានកំណត់អាទិភាព និងដំណាក់កាលអនុវត្តន៍នានា ដែលនឹងក្លាយទៅជាផែនការលម្អិតសម្រាប់ការអភិវឌ្ឍវិស័យពាណិជ្ជកម្មកម្ពុជាក្នុងរយៈពេល ៥ ឆ្នាំបន្ទាប់ទៀត ។ ជារួម យុទ្ធសាស្ត្រសមាហរណកម្មនេះបានកំណត់ពីវិធានការ គោលដៅ និងអាទិភាពច្បាស់លាស់ដែលអាចធ្វើឱ្យមានភាពប្រាកដប្រជា និងជាការវិភាគដែលមានប្រសិទ្ធភាពទាំងផ្នែកធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងស្ថាប័ន ។ដូច្នេះពេលនេះជាងពេលណាៗទាំងអស់ដែលយើងត្រូវប្រើប្រាស់ផែនទីបង្ហាញផ្លូវនៃយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម គឺដោយសារតែឯកសារនេះបានផ្តល់នូវសូចនាករ និងគោលរង្វាស់ច្បាស់លាស់មួយទាំងសម្រាប់ឆ្នាំ ២០១៦ និង ២០១៨ ខាងមុខ ។ សម្តេចបន្តថា យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មបែបវិភាគ ២០១៤-២០១៨ នេះ គឺជាយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មតែមួយគត់ដែលត្រូវបានទទួលយករួមគ្នាដោយរាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ព្រមទាំងនឹងត្រូវបានអនុវត្តដោយភាគីពាក់ព័ន្ធទាំងអស់តាមរយៈអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ។

តាមរយៈយុទ្ធសាស្ត្រនេះសម្តេចនាយករដ្ឋមន្ត្រីមានជំនឿយ៉ាងមុតមាំថា កម្ពុជាពិតជាអាចបន្តបោះជំហានទៅមុខយ៉ាងស្វាហាប់ ហើយឈានទៅសម្រេចបាននូវចក្ខុវិស័យវែងឆ្ងាយរបស់ខ្លួនពោលគឺប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ហើយឈានឡើងទៅជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ ២០៥០ ។

គួរបញ្ជាក់ថា យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មរបស់កម្ពុជា ២០១៤-២០១៨ នេះធ្វើឡើង ដោយឈរលើមូលដ្ឋាននៃកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា ។

ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មមានប្រសាសន៍ថា យុទ្ធសាស្ត្រថ្មីនេះគឺជាយុទ្ធសាស្ត្រលើកទី ៣ ដែលបានរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម (EIF) និងអតីតកម្មវិធីក្របខណ្ឌសមាហរណកម្ម(IF) ព្រមទាំងដៃគូអភិវឌ្ឍន៍ ។យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាដែលបានធ្វើបច្ចុប្បន្នភាពថ្មីនេះនឹងផ្តល់ដល់រាជរដ្ឋាភិបាលនូវមូលដ្ឋាន និងគំនិតដ៏មានសារប្រយោជន៍អំពីវិធីធ្វើដំណើរទៅមុខទៀតនៅក្នុងការអនុវត្តកំណែទម្រង់នានាជាពិសេសនៅក្នុងវិស័យពាណិជ្ជ

កម្មក្នុងបណ្ដាឆ្នាំខាងមុខ។ យុទ្ធសាស្ត្រនេះនឹងជួយកម្ពុជាក្នុងការកៀរគរធនធានជំនួយថ្មីៗបន្ថែមទៀត ដើម្បីដោះស្រាយតម្រូវការកំណែទម្រង់ថ្មីៗនានាដែលយើងត្រូវអនុវត្ត ហើយដែលយើងបានប្ដេជ្ញាចិត្តរួចហើយនោះ។ យុទ្ធសាស្ត្រថ្មីនេះនឹងជួយពង្រឹងបន្ថែមទៀតនូវការប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្មកម្ពុជាឱ្យកាន់តែប្រសើរ ដើម្បីចូលរួមចំណែកក្នុងការបង្កើតការងារថ្មីនិងប្រសើរជាងមុន បង្កើនចំណូល និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

លោកបណ្ឌិត **រតនាករ អាឌីការី** (Ratnakar Adhikari) នាយកប្រតិបត្តិនៃកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម (EIF) ដែលចូលរួមក្នុងពិធីនេះដែរបានកត់សម្គាល់ថា ការប្រកាសជាផ្លូវការនៃយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (២០១៤-២០១៨) គឺជានិមិត្តរូបនៃវឌ្ឍនភាពដ៏ធំធេងដែលកម្ពុជាសម្រេចបាននៅក្នុងការអភិវឌ្ឍនិងសមាហរណកម្មពាណិជ្ជកម្ម ។ វឌ្ឍនភាពនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំការធ្វើបច្ចុប្បន្នភាព DTIS ។

គួរបញ្ជាក់ថា ក្នុងឆ្នាំ ២00១ កម្ពុជាបានអនុម័តយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មទីមួយរបស់ខ្លួន (DTIS)។ យុទ្ធសាស្ត្រទីមួយនេះ ត្រូវបានរៀបចំឡើងដោយមានការគាំទ្រផ្នែកថវិកាពីកម្មវិធីក្របខណ្ឌសមាហរកម្ម(IF) និងបានជួយយ៉ាងច្រើននៅក្នុងការកៀងគរការគាំទ្រពីដៃគូអភិវឌ្ឍន៍នៅក្នុងវិស័យនានា ដូចជា កំណែទម្រង់ច្បាប់ដែលទាក់ទងនឹងពាណិជ្ជកម្ម ខណៈដែលកម្ពុជាបានចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក និងនៅពេលដែលកម្ពុជាបានចាប់ផ្ដើមអនុវត្តការសន្យាជាមួយអង្គការពាណិជ្ជកម្មពិភពលោក។ យុទ្ធសាស្ត្រនេះបានផ្ដល់មូលដ្ឋានមួយសម្រាប់ជួយនៅផ្នែកកំណែទម្រង់វិនិយោគ និងកំណែទម្រង់កិច្ចសម្រួលពាណិជ្ជកម្មដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាច្រើនក្នុងការធ្វើទំនើបកម្មប្រតិបត្តិការគយ។

-រសៀលថ្ងៃទី ២0 ខែកុម្ភៈ សម្ដេចតេជោនាយករដ្ឋមន្ត្រីបានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារក្រសួងមហាផ្ទៃ។ នាពេលនោះសម្ដេចបានផ្ដល់នូវអនុសាសន៍មួយចំនួនទាក់ទងទៅនឹងការជំរុញការបម្រើសេវាសាធារណៈជូនប្រជាជនឱ្យបានកាន់តែប្រសើរថែមទៀត។

សម្ដេចមានប្រសាសន៍ថា ការផ្ដល់សេវាសាធារណៈជូនប្រជាជន មិនមានអ្វីជាការលំបាកនោះទេ បើសិនជាយើងមានការស្មោះត្រង់ពិតប្រាកដចង់បម្រើប្រជាជនពិតប្រាកដ ជួយដោះស្រាយបញ្ហាពិតប្រាកដ។ សម្ដេចបានសង្កត់ធ្ងន់ថា "រឿងសេវាសាធារណៈនេះវាអត់ត្រូវការឱ្យឯកឧត្ដម លោកជំទាវ ចេញដើមទុនយកទ្រព្យសម្បត្តិពីផ្ទះទៅឱ្យប្រជាជនទេ។ វាទាមទារត្រឹមតែសេចក្ដីស្មោះត្រង់ប៉ុណ្ណោះ" ។ សម្ដេចបន្តថា សមិទ្ធផលដែលរាជរដ្ឋាភិបាលបានធ្វើមានច្រើនណាស់នៅពេញផ្ទៃប្រទេស ប៉ុន្តែការឆកល្វែងនៃសេវាសាធារណៈពិតមែនតែ វាជាភាពតូចតាច ប៉ុន្តែរឿងទាំងអស់នេះពេលវាប្រមូលផ្ដុំគ្នាទៅគឺវាដូចជាកម្ទេចភ្លើងដែលអាចក្លាយទៅជាអគ្គិភ័យបាន ។

សម្ដេចបន្តថា "ខ្ញុំសូមអំពាវនាវចំពោះឯកឧត្ដម លោកជំទាវ មេត្តា



*សម្ដេចតេជោ **ហ៊ុន សែន** កាត់ខ្សែបូសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការរោងចក្រអគ្គិសនីដុតធ្យូងថ្ម ក្នុងឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ*

ផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានល្អព្រោះវាមិនតម្រូវឱ្យមានការបង់ថ្លៃនោះទេ ប៉ុន្តែទាមទារធ្វើឱ្យត្រឹមត្រូវតាមការកំណត់នៃច្បាប់ ហើយការផ្លាស់ប្ដូរឥរិយាបថនៅទីនេះគឺពិតជាសំខាន់ណាស់ដែលខ្ញុំសង្កត់ធ្ងន់ទៅលើប្រសិទ្ធភាពនៃសេវាសាធារណៈ ហើយធ្វើដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ហើយត្រូវចាំថា យុទ្ធសាស្ត្រចតុកោណ មានតែ ៤ ទេ គឺ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព" ។

សម្ដេចបានពន្យល់ថា ដើម្បីលើកកម្ពស់តម្លាភាពនិងគណនេយ្យភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដ៏ដូចជា នគរបាលជាតិត្រូវរៀបចំឱ្យមានយន្តការច្រកចេញចូលតែមួយក្នុងការផ្ដល់សេវារដ្ឋបាល និងត្រូវរៀបចំឱ្យមានប្រព័ន្ធតាមដានត្រួតពិនិត្យវាយតម្លៃ ការទទួលព័ត៌មានត្រឡប់ និងពាក្យបណ្ដឹងនានាពីអ្នកទទួលសេវា ព្រមទាំងរៀបចំយន្តការដោះស្រាយបណ្ដឹង និងព័ត៌មានទាំងនោះប្រកបដោយតម្លាភាព គណនេយ្យភាព និងមានប្រសិទ្ធភាព។

ជាផ្នែកមួយនៃសេវាសាធារណៈចំពោះប្រជាពលរដ្ឋដែលត្រូវបានលើកដោយប្រមុខរាជរដ្ឋាភិបាលនោះ មានដូចជា បញ្ហាអត្រានុកូលដ្ឋាន បញ្ហាសៀវភៅគ្រួសារ បញ្ហាធ្វើអត្តសញ្ញាណប័ណ្ណជាដើម។ សម្ដេចថ្លែងថា បញ្ហាទាំងអស់នេះពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ថ្លៃនោះទេ ព្រោះរដ្ឋជាអ្នកចេញថ្លៃ ប៉ុន្តែបើតម្រូវឱ្យមានការបង់ថ្លៃសេវាសាធារណៈសូមយកត្រឹមតែការកំណត់ទៅបានហើយ។ ឥឡូវនេះដំណើរការកែទម្រង់បែបវិមជ្ឈការថ្នាក់ក្រោមជាតិ អនុវត្តការផ្ទេរអំណាចទៅមូលដ្ឋានកាន់តែច្រើន ហើយការធ្វើច្បាប់នៅថ្នាក់កណ្ដាលក៏ត្រូវមានសង្គតិភាពជាមួយច្បាប់រៀបចំមូលដ្ឋានដែរ។

សម្ដេចបានអំពាវនាវថា "សូមឯកឧត្ដម លោកជំទាវ ធ្វើតាមតែមុខងារទៅ ព្រោះប្រជាជនក៏សប្បាយ យើងក៏សប្បាយ ដែលទីចុងបំផុតភាពជិតស្និទ្ធរវាងប្រជាពលរដ្ឋ និងអ្នកបម្រើប្រជាពលរដ្ឋ គឺបានកើតមានឡើងតាមរយៈការដែលយើងដាក់ខ្លួនជាខ្ញុំបម្រើពិតប្រាកដរបស់ពួកគាត់" ។

-ព្រឹកថ្ងៃទី ២៥ ខែកុម្ភៈ សម្ដេចតេជោ **ហ៊ុន សែន** បានអញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវរោងចក្រអគ្គិសនីដុតធ្យូងថ្មមានអនុភាព ១00 មេហ្គាវ៉ាត់ និងខ្សែបញ្ជូនអគ្គិសនី ២៣0 គីឡូវ៉ុល ភ្នំពេញ-

តទៅទំព័រទី ១៣

# ពិធីប្រកាសបង្កើតគណៈកម្មាធិការគណបក្សខេត្តត្បូងឃ្មុំ



*ឯកឧត្តម **សាយ ឈុំ** ផ្តល់ការណែនាំក្នុងពិធីប្រកាសបង្កើតគណៈ-កម្មាធិការគណបក្សខេត្តត្បូងឃ្មុំ និងប្រកាសតែងតាំងប្រធាន អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្តាលចុះជួយខេត្តត្បូងឃ្មុំ*

ឯកឧត្តម **សាយ ឈុំ** ប្រធានគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសបង្កើតគណៈកម្មាធិការគណបក្សខេត្តត្បូងឃ្មុំ និងប្រកាសតែង-តាំងប្រធាន អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្តាលចុះជួយខេត្តត្បូងឃ្មុំ ដែលជាខេត្តទើបតែនឹងត្រូវបានបង្កើតថ្មី ដោយកាត់ចេញមួយផ្នែកពីខេត្តកំពង់ចាម ។ ពិធីនេះបានប្រព្រឹត្តទៅនៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៤ នៅទីស្នាក់ការគណបក្សស្រុកពញាក្រែក ។

បន្ទាប់ពីការប្រកាស និងប្រគល់សេចក្តីសម្រេចរបស់គណៈអចិ-ន្ត្រៃយ៍គណៈកម្មាធិការកណ្តាលស្តីពីការបង្កើតគណៈកម្មាធិការគណ-បក្សខេត្តត្បូងឃ្មុំ ប្រកាសប្រធាន អនុប្រធានគណៈកម្មាធិការគណបក្សខេត្តត្បូងឃ្មុំ និងប្រកាសប្រធាន អនុប្រធានក្រុមការងារគណបក្សប្រជា-ជនកម្ពុជាថ្នាក់កណ្តាលចុះជួយខេត្តត្បូងឃ្មុំរួចមក ឯកឧត្តម **ប្រាជ្ញ ចន្ទ** សមាជិកគណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សខេត្ត



*សមាជិក សមាជិកា ចូលរួមក្នុងពិធីប្រកាសបង្កើតគណៈកម្មាធិការគណបក្សខេត្តត្បូងឃ្មុំ និងប្រកាសតែងតាំងប្រធាន អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្តាលចុះជួយខេត្តត្បូងឃ្មុំ*

ត្បូងឃ្មុំ និងជាអភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ បានថ្លែងនូវចំណាប់អារម្មណ៍និងការប្តេជ្ញាចិត្តក្នុងការដឹកនាំគណបក្សខេត្តដើម្បីអនុវត្តកម្មវិធីនយោបាយ លក្ខន្តិកៈ គោលការណ៍ គោលនយោបាយ និងរាល់សេចក្តីសម្រេចរបស់គណបក្សឱ្យទទួលបានលទ្ធផលល្អប្រសើរ ឆ្លើយតបទៅនឹងជំនឿទុកចិត្តរបស់គណៈអចិន្ត្រៃយ៍មកលើរូបឯកឧត្តម ក៏ដូចជាគណៈកម្មាធិការគណបក្សខេត្តត្បូងឃ្មុំទាំងមូល ។

មានប្រសាសន៍សំណេះសំណាលនៅក្នុងអង្គពិធីនាឱកាសនោះ ឯក-ឧត្តម **សាយ ឈុំ** បាននាំនាំនូវពាក្យផ្តាំផ្ញើសួរសុខទុក្ខ និងសព្ទសាធុការពរពីសំណាក់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានគណបក្សសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អនុ ប្រធានគណបក្ស និងសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានកិត្តិយសគណបក្ស ជូនដល់អង្គពិធីទាំងមូល ។ ឯកឧត្តមបានគូសបញ្ជាក់ថា ពិធីនេះប្រព្រឹត្តទៅស្របពេលដែលកម្ពុជាយើងបានដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ ប្រកបដោយជោគជ័យ ដែលក្នុងនោះ គណបក្សប្រជា-ជនកម្ពុជាយើងទទួលបាន ៦៨ អាសនៈ លើ ១២៣ អាសនៈ ដែលជាសំឡេងភាគច្រើនដាច់ខាតដែលធានាដល់កិច្ចដំណើរការនៃរដ្ឋសភានីតិ-កាលថ្មី និងបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើសមាសភាពរាជរដ្ឋាភិបាលថ្មីបានស្របតាមការកំណត់នៃរដ្ឋធម្មនុញ្ញ ។

ទាក់ទងទៅនឹងសភាពការណ៍បច្ចុប្បន្ន និងការងារសំខាន់ៗដែល ត្រូវអនុវត្តនៅពេលទៅមុខទៀតនេះ ឯកឧត្តម **សាយ ឈុំ** បានលើកឡើងអំពីសកម្មភាពប្រទូសរ៉ាយនានារបស់គណបក្សប្រឆាំងក្រោយការបោះឆ្នោត ដើម្បីសម្រេចនូវគោលដៅនៃការផ្លាស់ប្តូររបស់ពួកគេ ជាពិសេសការកេណ្ឌប្រមូលអ្នកគាំទ្ររបស់ខ្លួនឱ្យចូលរួមក្នុងចលនាបាតុកម្មឥតឈប់ឈរប្រកបដោយភាពអនាធិបតេយ្យ មិនគោរពច្បាប់និងមិនស្តាប់ការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ។ សកម្មភាពបាតុកម្មនេះបានទៅហួសក្របខ័ណ្ឌច្បាប់ ប្រែក្លាយជាកុប្បកម្មដោយហិង្សា ដែលបានបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ទ្រព្យសម្បត្តិឯកជន និងប្រជាជន បិទផ្លូវធ្វើដំណើរ ហើយប្រព្រឹត្តអំពើហិង្សាមកលើសមត្ថកិច្ច ។ ក្នុងស្ថានភាពនេះ កម្លាំងមានសមត្ថកិច្ចត្រូវបង្ខំចិត្តអនុវត្តច្បាប់ ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមឱ្យមានប្រក្រតីភាពឡើងវិញ ។ ឆ្លងតាមសភាពការណ៍នេះបានបង្ហាញច្បាស់ថា គណបក្សប្រឆាំងបាននាំអ្នកគាំទ្ររបស់ខ្លួនឱ្យដើរផ្ទុយពីលទ្ធិប្រជាធិបតេយ្យ មិនគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមានឡើយ ។

ឯកឧត្តមបានបន្តថា ក្នុងការប្រឹងប្រែងស្វែងរកដំណោះស្រាយបញ្ហាក្រោយពេលបោះឆ្នោតគណបក្សប្រជាជនកម្ពុជាបានប្រកាន់ខ្ជាប់ជានិច្ចនូវសុឆន្ទៈនិងភាពស្មោះត្រង់ក្នុងការចរចាជាមួយគណបក្សប្រឆាំង ប៉ុន្តែគណបក្សប្រឆាំងមិនបានទទួលយកបំណងល្អរបស់គណបក្សប្រជាជនកម្ពុជា



*ឯកឧត្តម **សាយ ឈុំ** ប្រគល់ត្រា និងលិខិតតែងតាំង ជូនឯកឧត្តម **ធ្រាង ចន្ទ** ជាប្រធានគណៈកម្មាធិការគណបក្សខេត្តត្បូងឃ្មុំ*

ឡើយ ព្រោះថាអ្វីដែលគេចង់បាននោះគឺអំណាច ។ ទោះបីយ៉ាងនេះក្តី ក៏គណបក្សប្រជាជនកម្ពុជានៅតែបើកទ្វារចំហជានិច្ចសម្រាប់ការចរចា ។

នៅក្នុងឱកាសនោះ ឯកឧត្តម **សាយ ឈុំ** បានផ្តល់អនុសាសន៍ដល់គណៈកម្មាធិការគណបក្សខេត្តត្បូងឃ្មុំនិងក្រុមការងារចុះខេត្តត្បូងឃ្មុំ អំពីទិសដៅការងារសំខាន់ៗមួយចំនួន សម្រាប់រយៈពេលទៅមុខទៀត ដែលត្រូវតែខំអនុវត្តឱ្យបានល្អ គឺ :

-ក្តាប់ជាប់លក្ខន្តិកៈ កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចទាំងឡាយដែលគណៈអចិន្ត្រៃយ៍បានដាក់ចុះមក ។ ទន្ទឹមនេះត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានត្រឹមត្រូវនូវតួនាទី ភារកិច្ច សិទ្ធិ អំណាច និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សនៃថ្នាក់នីមួយៗ ។ ក្នុងនោះឯកឧត្តមបានរំឭកដល់ប្រធានគណៈកម្មាធិការគណបក្សខេត្តគប្បីអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវលក្ខការណ៍ដឹកនាំរបស់គណបក្សគឺ :

-សមូហភាពដឹកនាំម្នាក់ៗទទួលខុសត្រូវ ភាគតិចគោរពភាគច្រើន

-ដឹកនាំ ត្រូវរឹងមាំទាំងខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង

-ដឹកនាំ ត្រូវមានសាមគ្គីភាព ឯកភាពផ្ទៃក្នុងរឹងមាំ ។

-ចំពោះក្រុមការងារចុះជួយខេត្ត ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវភារកិច្ចទាំងបីគឺ :

-ជួយគណបក្សខេត្តក្នុងការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងមូលដ្ឋានខេត្ត ។

-ជួយគណបក្សខេត្តក្នុងការដោះស្រាយបញ្ហាដែលទាក់ទងដល់ ការរៀបចំការបោះឆ្នោតនៅគ្រប់កម្រិត ទាំងសកល និងអសកល ។

-ជួយគណបក្សខេត្តក្នុងការពង្រឹងការងារគណបក្សនៅគ្រប់ថ្នាក់ក្នុងខេត្ត ទាំងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ។

-ព្រមជាមួយនោះ ឯកឧត្តមក៏បានរំឭកឱ្យយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តវេទិកាសាធារណៈដែលត្រូវធ្វើឱ្យទៀងទាត់គ្រប់មូលដ្ឋាន ដោយមានខ្លឹមសារស្របតាមសភាពការណ៍ជាក់ស្តែងនៃដំណាក់កាលនីមួយៗនិងត្រូវចូលរួមអនុវត្តនយោបាយកែទម្រង់របស់រាជរដ្ឋាភិបាលឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពពិតប្រាកដ ។

ចុងបញ្ចប់ឯកឧត្តមបានសម្តែងសេចក្តីសង្ឃឹមជឿជាក់ថាគណៈកម្មាធិការគណបក្សខេត្ត និងក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្ត ពិតជាប្រឹងប្រែងអនុវត្តភារកិច្ចដែលគណបក្សប្រគល់ឱ្យបានសម្រេចជោគជ័យ ។

គួរបញ្ជាក់ថា ខេត្តត្បូងឃ្មុំ ត្រូវបានប្រកាសដោយព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៣ ដោយកាត់ចេញពីទឹកដីផ្នែកខាងកើតទន្លេមេគង្គនៃខេត្តកំពង់ចាម ។ ខេត្តនេះមានព្រំប្រទល់ខាងជើងទល់នឹងខេត្តក្រចេះ ខាងត្បូងទល់នឹងខេត្ត ព្រៃវែង និងប្រទេសវៀតណាម ខាងកើតទល់នឹងប្រទេសវៀតណាម ខាងលិចទល់នឹងទន្លេមេគង្គ ដែលជាខ្សែព្រំប្រទល់ខេត្តកំពង់ចាម ។ ខេត្តត្បូងឃ្មុំមាន ៧ ក្រុង ស្រុក រួមមាន ស្រុកអូរាំងឪ ស្រុកត្បូងឃ្មុំ ស្រុកក្រូចឆ្មារ ស្រុកតំបែរ ស្រុកពញាក្រែក ស្រុកមេមត់ និងក្រុងសួង ។ ក្រុង ស្រុកទាំង ៧ គ្របដណ្តប់លើឃុំចំនួន ៦២ និង ២ សង្កាត់ មាន ៨៦៥ ភូមិ ។ ផ្ទៃដីសរុបចំនួន ៥២៥០,៥១ គ.ម២ ក្នុងនោះដីលំនៅស្ថាន ៧៥ ៧៦៦ ហ.ត ដីដំណាំកសិកម្ម និងកសិឧស្សាហកម្ម ២០០ ០៧៦ ហ.ត ដីទន្លេ បឹង ស្ទឹង ព្រៃក អូរ និងដីផ្សេងៗ ២៤៩ ២០៤ ហ.ត ។ ប្រជាពលរដ្ឋសរុប ១៧៩ ៨៣៣ គ្រួសារ ស្មើនឹងប្រជាជន សរុប ៨២១ ០៤៣ នាក់ ស្ត្រីភេទ ៤២០ ៦៨០ នាក់ ស្មើនឹង ៥១,២៣% នៃប្រជាជនសរុប និងមានដង់ស៊ីតេ ១៥៣នាក់/គ.ម២ ។ ជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើង សរុប ៤៩៥ ៦៧០ នាក់ ក្នុងនោះ ស្ត្រី ២៥៦ ៧៣៦ នាក់ ។ ប្រជាជនមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតចុងក្រោយចំនួន ៤៨៩ ១៤៩ នាក់ ។/

Continued from 2

It is also prime to make effort to speed up active, radical and truly effective reforms in conformity with the policy defined by the Royal Government and put an end to negative phenomena that causes discontent and losing of confidence among people in the leadership. A major work to carry through is the strengthening of public referendum at national and sub-national level and in all fields to gather opinions, concerns, discontents and demands from the people, workers, farmers, businessmen, youth, government officials and the armed forces to resolve problem and improve situation accordingly. Every official should clearly understand that the public referendum is like a mirror to reflect good and bad actions in implementing the role and t ask of each respected sector and level for the sake of adjustment in a timely manner. The public referendum also will strengthen and expand the close connectedness between officials and people of all strata and in every locality.

Based on these efforts to implement tasks of priority, we will be able to thwart off the dangerous ambitions nurtured by the opposition and reactionary forces who continue to seek every means to assuage their aspiration for change. It is on this note that we must unite physically and spiritually to protect tremendous national achievements scored since the liberation day of January 7 (1979) and make more efforts to score new achievements in 2014 in particular and in the fifth legislative term of the National Assembly as a whole. That would be a true response to the will of the overwhelming majority of the Cambodian people expressed through their votes in the recent general elections./.

THE PRACHEACHUN MAGAZINE

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស




ថ្ងៃទី ០៥ ទី១១ និងទី ១៩ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកឧត្តមបណ្ឌិត **ខួន ញឿល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាអនុប្រធានទី១រដ្ឋសភា ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សប្រជាជនកម្ពុជាខេត្តកំពង់ធំ និងក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្ត ដែលកិច្ចប្រជុំបានផ្តោតជាសំខាន់លើការធ្វើបច្ចុប្បន្នភាពបញ្ជីបេក្ខជនក្រុមប្រឹក្សាខេត្ត ការកែសម្រួលក្រុមការងាររបស់គណៈកម្មាធិការកណ្តាលចុះជួយយខេត្តនិងការត្រៀមថវិកាសម្រាប់ប្រើប្រាស់ក្នុងពេលបោះឆ្នោតក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នាពេលខាងមុខ ។ ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **ខួន ញឿល** បានឧបត្ថម្ភថវិកាសម្រាប់ប្រើប្រាស់ការបោះឆ្នោតខាងលើ និងសម្រាប់ដោះស្រាយការងារផ្សេងៗក្នុងមូលដ្ឋានសារុបចំនួន ២២.៣០០ ដុល្លារអាមេរិក ។



*ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៤ នៅទីស្តីការក្រសួង លោកជំទាវបណ្ឌិត **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជា-ជនកម្ពុជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានទទួលជួបសំណេះសំណាល ព្រមទាំងផ្តល់អំណោយដល់ក្រុមតន្ត្រីសំឡេងជនពិការនៃសមាគមជនពិការចំនួន ៣០ នាក់ ដែលក្នុងម្នាក់ៗទទួលបានថវិកា ១០ ម៉ឺនរៀល មី ៥ កញ្ចប់ ទឹកក្រូច ២ កំប៉ុង ទឹកដោះគោ ២ កំប៉ុង ត្រីខ ២ កំប៉ុង ទឹក សុទ្ធ ២ ដប នំប៉័ងបាក់យ៉ុង ២ ដើម និងសារុង ១ ។ ផ្តល់ជូនសមាគមជនពិការនូវថវិកាចំនួន ២ លានរៀល និង ៥០០ ដុល្លារអាមេរិក ។*



ថ្ងៃទី ១៧ ខែកុម្ភៈ ឯកឧត្តម **កែ គឹមយ៉ាន** សមាជិកគណៈអចិ-ន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយក-រដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងមន្ត្រីអាជ្ញាធរខេត្តបន្ទាយមានជ័យបានចុះពិនិត្យស្ថានភាពស្រូវ ប្រាំងចំណុចស្ពានព្រែកជីក ស្ទឹងមង្គលបូរី ក្នុងឃុំឬស្សីក្រោក និងឃុំបត់ត្រង់ ទ្វារទឹកពោធិ ២ ដើម ឃុំរហាត់ទឹក និងឃុំតាឡំ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដែលកំពុងខ្វះទឹក ។



*ថ្ងៃទី ១៧ ខែកុម្ភ ឯកឧត្តម **ម៉ម ប៊ុនហេង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជារដ្ឋមន្ត្រីក្រសួងសុខាភិ-បាលបានអញ្ជើញចូលរួមសម្ពោធអគារមណ្ឌលសុខភាពវីរៈជ័យ ស្រុកវ៉ឺនសៃ ខេត្តរតនគិរី ។អគារមណ្ឌលសុខភាពនេះត្រូវបានសាងសង់ និងបំពាក់សម្ភារៈដោយថវិកាគម្រោង កម្ពុជា-ថៃ ក្នុងការប្រយុទ្ធនឹងជំងឺគ្រុនចាញ់-គ្រុនឈាម ដែលទ្រទ្រង់ដោយព្រះអង្គម្ចាស់ក្សត្រីមហាចក្រី **សិរិនថន** នៃព្រះរាជាណាចក្រថៃ ។*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



*ថ្ងៃទី ១៤ ខែកុម្ភៈឯកឧត្តម **ត្រាំ អ៊ីវតឹក** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងប្រតិភូ បានអញ្ជើញពិនិត្យបណ្តាញផ្លូវថ្នល់ និងដំណើរការស្តាបនាជួសជុលលើផ្លូវជាតិ ផ្លូវព្រំដែនពីខេត្តសៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ។*



ថ្ងៃទី ៦ ខែកុម្ភៈឯកឧត្តម **វង សូត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអញ្ជើញសម្ពោធអគារការិយាល័យមួយ ខ្នងទំហំ៦,៥ម៉ែត្រ គុណនឹង២៨ម៉ែត្រ ធ្វើពីបេតុងប្រក់ក្បឿង ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជូនវរៈសេនាតូចស៊ើបការណ៍យោធភូមិភាគទី ១ ស្ថិតនៅក្រុងស្ទឹងត្រែងខេត្តស្ទឹងត្រែង ។អគារនេះមានបួនបន្ទប់ចំណាយថវិកាសាងសង់សរុបចំនួន ២៦.៧៨០ ដុល្លារអាមេរិក ។



*ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១៤ ឯកឧត្តម **អូស្មាន ហាស្សាន់** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា និងលោកជំទាវ រួមដំណើរដោយឯកឧត្តម **ហ្សា ការីយ៉ា អាដាម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងលោកជំទាវ ឯកឧត្តមអភិបាលរងខេត្តកំពង់ចាម និងលោកជំទាវ តំណាងសប្បុរសជនគុយវ៉ែត ម៉ាឡេស៊ី ចិន បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានសាងសង់អគារនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលចំណេះដឹង ទូទៅ និងវិជ្ជាជីវៈនៅភូមិពោធិឥន្ទ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម ដែលអគារនេះគ្រោងចំណាយការសាងសង់ចំនួន ៤ លាន ១ សែនដុល្លារអាមេរិក ជាអំណោយរបស់សមាគមសម្របសម្រួលសង្គមនៃរដ្ឋគុយវ៉ែតប្រចាំកម្ពុជា សហការជាមួយសមាគមសប្បុរសធម៌ ដើម្បីអភិវឌ្ឍន៍កម្ពុជា ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលនេះចែកចេញជាអគារសាលារៀន អគារ អន្តេវាសិកដ្ឋាន អគារបុគ្គលិក សាលប្រជុំ អគារការិយាល័យ អគារមណ្ឌលសុខភាព និងវិហារឥស្លាម ។ ចំពោះការបណ្តុះបណ្តាល ផ្តោតជាសំខាន់លើមុខជំនាញចំនួន ៥ គឺ ផ្សារដែក កញ្ចក់ អាលុយមីញ៉ូម ផលិតទ្វារបង្អួច ម៉ាស៊ីនត្រជាក់ និងតបណ្តាញអគ្គិសនី ។*

*-ថ្ងៃដដែលនោះ គណៈប្រតិភូបានអញ្ជើញពិនិត្យការដ្ឋានសាងសង់វិហារឥស្លាមនៅភូមិបេងថ្មី ឃុំសេដា ស្រុក តំបែរ ខេត្តកំពង់ចាម ដែលចំណាយថវិកាសាងសង់ចំនួន ១៦ ម៉ឺនដុល្លារអាមេរិក ជាអំណោយរបស់សប្បុរសជន ម៉ាឡេស៊ី សហការជាមួយអង្គការមូលនិធិអភិវឌ្ឍន៍មូស្លីមកម្ពុជា និងបន្តដំណើរអញ្ជើញពិនិត្យការបញ្ចប់ការសាងសង់វិហារឥស្លាមនៅភូមិជរកែង ឃុំសេដា ស្រុកតំបែរ ដែលចំណាយថវិការសាងសង់ចំនួន ៥ ម៉ឺនដុល្លារអាមេរិក ជាអំណោយសប្បុរសជនអារាប់អេមីរ៉ាត តាមរយៈអង្គការមូលនិធិអភិវឌ្ឍន៍មូស្លីមកម្ពុជា និងអញ្ជើញពិនិត្យការដ្ឋានសាងសង់វិហារឥស្លាមនៅភូមិឈើទាលភ្លោះ ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ ដែលចំណាយថវិកាសាងសង់ចំនួន ១៨ ម៉ឺន ៥ ពាន់ដុល្លារអាមេរិក ជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងសប្បុរសជនជាច្រើនទៀត ។ នៅក្នុងភូមិខាងលើដដែល គណៈប្រតិភូបានអញ្ជើញពិនិត្យស៊ូរ៉ាវ មានកម្ពស់ ២ ជាន់ ដែលទើបសាងសង់រួច ជាអំណោយរបស់សមាគមសុខុមាលភាពឥស្លាមម៉ាឡេស៊ី ក្នុងថវិកា ២ ម៉ឺន ៥ ពាន់ដុល្លារអា មេរិក សរុបទាំងអស់វិហារនេះចំណាយថវិកាចំនួន២២៥០០០ដុល្លារអាមេរិក ។ក្នុងថ្ងៃដដែលនេះដែរ គណៈប្រតិភូបានបន្តដំណើរជួបសំណេះសំណាលសួរសុខទុក្ខនិងផ្តល់អំណោយដល់ប្រជាពលរដ្ឋចំនួន ១០៥ គ្រួសារ នៅភូមិត្រពាំងបេង ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ ដែលក្នុង ១ គ្រួសារៗទទួលបាន អង្ករ ២០ គ.ក្រ និងសម្លៀកបំពាក់សម្រាប់ថ្វាយបង្គំធម៌ក្នុងឥស្លាម ១ កំប្លេ ជាអំណោយរបស់សមាគមឥស្លាមនៅប្រទេសចិន និងអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងផ្តល់អំណោយជូនប្រជាពលរដ្ឋចំនួន ១០៨ គ្រួសារ នៅភូមិថ្មី ឃុំ ស្រុកដដែល ដោយក្នុង ១ គ្រួសារៗ ទទួលបាន អង្ករ ២០ គ.ក្រ ជាអំណោយរបស់សមាគមឥស្លាមនៅប្រទេសចិន ។ គណៈប្រតិភូបានបន្តដំណើរពិនិត្យការដ្ឋានសាងសង់វិហារឥស្លាមនៅភូមិអំពិលឃុំប៉ុស ២ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដែលវិហារនេះសាងសង់ឡើងក្រោមថវិកាបដិភាគរបស់ភូមិ រួមជាមួយនឹងសប្បុរសជនម៉ាឡេស៊ី ក្នុងគម្រោងថវិកាចំនួន ៣៥ ម៉ឺន-ដុល្លារអាមេរិក ព្រមទាំងបន្តដំណើរជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយជាអង្ករ និងថវិកាមួយចំនួនផ្តល់ជូនប្រជាពលរដ្ឋចំនួន ៤៥០ គ្រួសារនៅភូមិស្វាយឃ្លាំង ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដែលនៅទីនោះ ឯកឧត្តម **អូស្មាន ហាស្សាន់** សម្រេចប្រកាសប្រគល់ជូនវិហារឥស្លាម ១ ខ្នង ជាជំនួយរបស់សប្បុរសជនប្រទេសអារ៉ាប់រួមអេមីរ៉ាត់ ដែលគ្រោងចំណាយថវិកាចំនួន ១៤ ម៉ឺនដុល្លារអាមេរិក ។/*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ព្រឹកថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៤ ឯកឧត្តម **ឃឹម ប៊ុនសុង** ប្រធានគណៈកម្មាធិការគណបក្សខេត្ត អភិបាលនៃគណៈអភិបាលខេត្តសៀមរាប បានអញ្ជើញបើកការដ្ឋានស្ថាបនាផ្លូវបេតុងក្រាលកៅស៊ូបេទីមីណឺមួយខ្សែប្រើប្រាស់ថវិកាខេត្ត នៅភូមិមណ្ឌលមួយ ក្រុងសៀមរាប ខេត្ត សៀមរាប ។





*ថ្ងៃទី ៦ ខែកុម្ភៈ ឯកឧត្តម **គោស៊ុំ សារឿត** អនុប្រធានគណៈកម្មាធិការគណបក្សខេត្ត អភិបាលនៃគណៈអភិបាលខេត្ត បន្ទាយមានជ័យ បានអញ្ជើញផ្តល់កម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋមានដីនៅឃុំជប់វារីឃុំទានកាំ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យចំនួន ១.០២៣ គ្រួសារ។ ខណៈនោះ ឯកឧត្តមបានរំលឹកឱ្យម្ចាស់កម្មសិទ្ធិថែរក្សា និងទុកដាក់ប័ណ្ណនេះឱ្យបានល្អ និងប្រើប្រាស់បានចំទិសដៅ។*



ថ្ងៃទី៦ខែកុម្ភៈឯកឧត្តម**ចំន្ទ សុផល**អនុប្រធានគណៈកម្មាធិការគណបក្សខេត្ត អភិបាលគណៈនៃអភិបាលខេត្តបាត់ដំបង និងមន្ត្រីជំនាញបានអញ្ជើញចុះពិនិត្យផ្លូវក្នុងខេត្តចំនួនប្រាំខ្សែមានប្រវែងជិត ៥០ គីឡូម៉ែត្រ ដែលស្ថាបនាដោយមន្ទីរសារ-ធារណការ និងដឹកជញ្ជូនខេត្ត ដោយក្រាលកៅស៊ូ និងក្រាលក្រួសក្រហម។

តមកពីទំព័រទី ៨

កំពង់ចាម នៅខេត្តព្រះសីហនុ ។ នៅទីនោះសម្តេចបានលើកឡើងអំពីសិទ្ធិដូចគ្នារវាងអ្នកគាំទ្ររាជរដ្ឋាភិបាល និងអ្នកដែលគាំទ្រគណបក្សប្រឆាំង។

សម្តេចបានលើកឡើងថា សាលារាជធានីភ្នំពេញគួរតែត្រៀមឱ្យហើយទៅនូវការចែកជាទីនៃទីលានប្រជាធិបតេយ្យ។ គឺសម្រាប់អ្នកសុំច្បាប់ធ្វើបាតុកម្មគាំទ្រ និងអ្នកប្រឆាំងដែលអាចកើតឡើងនាពេលខាងមុខនោះ។ ឥឡូវនេះបាតុកម្មមានពីរ អ្នកគាំទ្រក៏មានសិទ្ធិ អ្នកប្រឆាំងក៏មានសិទ្ធិ ។ គឺមានសិទ្ធិដូចគ្នា ។ សិទ្ធិទល់នឹងសិទ្ធ។ ឆន្ទៈទល់នឹងឆន្ទៈ។

គេអាចយល់បានថា ការថ្លែងនេះសំដៅទៅរកមេដឹកនាំគណបក្សប្រឆាំង ដែលជារឿយៗពួកគេតែងតែនិយាយដដែលៗថា ពួកគេធ្វើតាមឆន្ទៈរាស្ត្រ។

សម្តេចបានបញ្ជាក់ថា "ស្អីឡើងឆន្ទៈរាស្ត្រ! បើអីចឹងខាងណេះក៏មានឆន្ទៈរាស្ត្រដែរ។ បើអ្នកប្រឆាំងមានសិទ្ធិជួបជុំ ដូចនេះអ្នកគាំទ្រក៏មានសិទ្ធជួបជុំដែរ ហើយសម្តេចត្រូវធានាសុវត្ថិភាពឱ្យទាំងអស់គ្នា។ ឧទាហរណ៍ថា បើត្រូវទៅធ្វើនៅទីលានប្រជាធិបតេយ្យ បើសិនទាំងសងខាងសុំទីលានប្រជាធិបតេយ្យ សាលាក្រុងភ្នំពេញត្រូវត្រៀមចែកជាពីរឱ្យហើយទៅ។ ម្ខាងអ្នកគាំទ្រ និងម្ខាងអ្នកប្រឆាំង" ។

សម្តេចបានបញ្ជាក់ដូច្នេះឱ្យអាជ្ញាធរគ្រប់ទីកន្លែងបានដឹង ហើយក៏ឱ្យអ្នកនយោបាយមួយចំនួនភ្លឺភ្នែកដែរ កុំឱ្យចេះប្រើសិទ្ធិអីតែឯង ។

ទាក់ទងទៅនឹងវិស័យអគ្គិសនី សម្តេចបានមានប្រសាសន៍ថា នេះជារោងចក្រអគ្គិសនីដុតធ្យូងថ្មលើកទីមួយ ដែលត្រូវបានដាក់ឱ្យដំណើរការនៅកម្ពុជា ស្របពេលដែលតម្រូវការប្រើប្រាស់ថាមពលអគ្គិសនីរបស់កម្ពុជាកាន់តែកើនឡើងយ៉ាងខ្លាំង។ រាជរដ្ឋាភិបាលមានទិសដៅខិតខំទាក់ទាញការវិនិយោគដើម្បីផលិតថាមពលអគ្គិសនីបន្ថែមទៀត ទាំងវារីអគ្គិសនី អគ្គិសនីដើរដោយធ្យូងថ្ម អគ្គិសនីបានមកពីថាមពលកកើតឡើង ដូចជាថាមពលបានពីព្រះអាទិត្យ ខ្យល់ ជាដើម។ សម្តេចបានរំឭកទៅដល់ប្រទេសខ្លះដែលកំពុងធ្វើការទិតៀនកម្ពុជាក្នុងការកសាងវារីអគ្គិសនី ដែលធ្វើឱ្យមានការប៉ះពាល់ដល់ព្រៃឈើ ត្រី និងដីតិចតួច។ សម្តេចបញ្ជាក់ថា ការអភិវឌ្ឍវាជៀសមិនផុតពីការប៉ះពាល់ខ្លះនោះទេ ។ ប៉ុន្តែប្រទេសដែលកំពុងទិតៀនកម្ពុជានោះបែរជាខ្លួនឯងកំពុងប្រើប្រាស់ថាមពលនុយក្លេអ៊ែរ ដើម្បីផលិតថាមពលអគ្គិសនី ដែលនៅពេលវាផ្ទុះធ្លាយម្តងៗបានសម្លាប់ជីវិតមនុស្សយ៉ាងច្រើនរាប់ទាំងបំផ្លាញពិភពលោកផងដែរ។

សម្តេចបានជំរុញឱ្យក្រសួងរ៉ែ និងថាមពល ខិតខំតបណ្តាញចែកចាយឱ្យបានទៅដល់គ្រប់ខេត្តទូទាំងប្រទេស។ ជាមួយនេះក៏ត្រូវខិតខំតភ្ជាប់ពីបណ្តាញមេទៅកាន់បណ្តាញរងស្ថិតនៅតាមភូមិ ឃុំ ដើម្បីជំនួសឱ្យអគ្គិសនីឯកជន។ បណ្តាញបញ្ជូនចរន្តនេះត្រូវចំណាយក្នុងមួយឆ្នាំប្រមាណ ២០ លានដុល្លារអាមេរិក ដើម្បីឱ្យអគ្គិសនីរបស់ជាតិចូលទៅជំនួសអគ្គិសនីឯកជន ដែលធ្វើឱ្យតម្លៃភ្លើងមានការថយចុះ។ ជាមួយការតភ្ជាប់បណ្តាញក្នុងប្រទេស សម្តេចក៏បានណែនាំឱ្យយកចិត្តទុកដាក់លើការតភ្ជាប់បណ្តាញជាមួយប្រទេសជិតខាងកម្ពុជា ដូចជា ប្រទេស វៀតណាម ប្រទេសឡាវ និងប្រទេសថៃ ដើម្បីទិញថាមពលអគ្គិសនីមកផ្គត់ផ្គង់បណ្តាខេត្តជាប់ព្រំដែន ។/

# ព្រឹត្តិការណ៍សំខាន់ៗក្នុងខែ កុម្ភៈ

➲ ថ្ងៃទី១ខែកុម្ភៈ ថ្លែងនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្នុងឱកាសអញ្ជើញវិលត្រឡប់ពីការពារបាយការណ៍យូភីអ័រ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ឯកឧត្តម **ម៉ក់ សម្បត្តិ** អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបានឱ្យដឹងថា របាយការណ៍UPR ជុំទី ២ ឬហៅថារបាយការណ៍ជាតិតាមពេលកំណត់ជុំទី ២ ដែលបាននិយាយពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា ត្រូវបានអង្គការសហប្រជាជាតិអនុម័តទទួលយកបន្ទាប់ពីកម្ពុជាបានធ្វើបទបង្ហាញ និងការពាររបាយការណ៍ UPRនេះ ជូនដល់បណ្ដាប្រទេសចំនួន ១៩៣ បានយល់ជ្រាបរួចមក ។

➲ ថ្ងៃទី ៤ ខែកុម្ភៈ នៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្ដីពីការអនុវត្តគម្រោងកសាងសមត្ថភាពសម្រាប់ការគ្រប់គ្រងទីក្រុង-ទីប្រជុំជន ឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានមានប្រសាសន៍ថា គម្រោងកសាងសមត្ថភាពនេះក៏មានការបញ្ចូលនូវក្របខណ្ឌមូលដ្ឋានឬគ្រោងឆ្អឹងឯកសារគោលសម្រាប់ការកសាងយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍទីក្រុងផងដែរ ។

➲ ថ្ងៃទី៥ កុម្ភៈ នៅទីស្ដីការក្រសួង នៅក្នុងជំនួបពិភាក្សាការងារមួយជាមួយឯក-ឧត្ដមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តមScot Marciel ឧបការីរងជាន់ខ្ពស់រដ្ឋមន្ត្រីការបរទេសអាមេរិក ទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិកមានប្រសាសន៍ថា អាមេរិកមានបំណងពង្រឹងពង្រីកទំនាក់ទំនងជាមួយនិងប្រទេសនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលក្នុងនោះមានប្រទេសកម្ពុជាផងដែរ ។

➲ ថ្ងៃទី ៧ កុម្ភៈ សម្ដេចតេជោ **ហ៊ុន សែន** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់វិលត្រលប់មកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញវិញប្រកបដោយសុវត្ថិភាពនិងជោគជ័យ បន្ទាប់ពីបំពេញទស្សនកិច្ចផ្លូវការរយៈពេល ២ ថ្ងៃនៅប្រទេសឡាវ ។ ក្នុងដំណើរទស្សន-កិច្ចនោះ កិច្ចសហប្រតិបត្តិការចំនួន ៧ ត្រូវបានចុះហត្ថលេខា ។ ប្រមុខរដ្ឋាភិបាលទាំងពីរក៏បានសន្យារួមគ្នាក្នុងការជំរុញទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរឱ្យមានការកើនឡើងទ្វេដង ពោលឱ្យកើនដល់ ២០ លានដុល្លារនៅឆ្នាំ ២០១៤ ឬឆ្នាំ ២០១៥ ខាងមុខ ។

➲ ថ្ងៃទី ៧ កុម្ភៈ រថយន្តថ្មីៗចំនួន ២៦ គ្រឿង និងឯកសណ្ឋានយោធា ចំនួន ៣០ ០០០ សម្រាប់ ដែលជាជំនួយឥតសំណងរបស់កងទ័ពរំដោះប្រជាជនចិន ត្រូវបានផ្ដល់ជូនដល់កងយោធពលខេមរភូមិន្ទ ។ ធ្វើពិធីផ្ទេរ និងប្រគល់ជាផ្លូវការបានប្រព្រឹត្តទៅនៅមូល-ដ្ឋានកងពលតូចដឹកជញ្ជូនលេខ ៩៩ ដែលស្ថិតនៅក្បែរព្រលានយន្តហោះយោធា ក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ឹង សំផន** រដ្ឋលេខាធិ-ការក្រសួងការពារជាតិ និងលោកជំទាវ **ពូ ជៀនគ័រ** (Bu Jianguo) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំនៅកម្ពុជា ។

➲ ថ្ងៃទី ១០ កុម្ភៈ នៅក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ សម្ដេចតេជោ **ហ៊ុន សែន** មានប្រសាសន៍ថា បច្ចុប្បន្ននេះប្រទេសកម្ពុជាមានប្រក្រតីជាធម្មតាលើគ្រប់វិស័យទាំងអស់ ហើយដែលរាជរដ្ឋាភិបាលនឹងរក្សានូវសុខសន្តិភាព ស្ថិរភាព នយោបាយ មិនអាចមានអ្នកណាមកបង្កអស្ថិរភាពដល់សង្គមជាតិបានឡើយ ។

➲ ថ្ងៃទី ១១ កុម្ភៈ ក្នុងសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃការអង្កេតស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឯកឧត្ដម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន នឹងរួមចំណែកនៅក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនិងអភិបាលកិច្ចល្អសំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

➲ ថ្ងៃទី ១១ កុម្ភៈ ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ធនាគារពាណិជ្ជ ព្រមទាំងវិស័យឯកជនដែលជាប្រតិបត្តិករផ្ទាល់ក្នុងវិស័យស្រូវ-អង្ករ បានជួបប្រជុំពិភាក្សាគ្នាបន្តដោះស្រាយបញ្ហាកង្វះឥណទានសម្រាប់ប្រមូលទិញ និងកែច្នៃស្រូវ និងឥណទានសម្រាប់ពាណិជ្ជកម្មក្នុងវិស័យស្រូវ-អង្ករ ក្រោមអធិបតីភាពឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅទីស្ដីការក្រសួង ។

➲ ថ្ងៃទី ១២ កុម្ភៈ នៅក្នុងឱកាសអញ្ជើញវិលត្រឡប់ពីចូលរួមទស្សនាការតាំងពិព័រណ៍បច្ចេកទេសយន្តហោះ និងសព្វាវុធទំនើប នៅប្រទេសសិង្ហបុរី ឯកឧត្តមនាយឧត្តមសេនីយ៍ **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ បានមានប្រសាសន៍ប្រាប់អ្នកសារព័ត៌មានដោយច្រានចោលទាំងស្រុងចំពោះការចោទប្រកាន់របស់មន្ត្រីជាន់ខ្ពស់ថៃដែលបានចោទប្រកាន់ថា មានទាហានកម្ពុជាចូលរួមធ្វើសកម្មភាពនៅក្នុងប្រទេសថៃកាលពីពេលកន្លងមក ។

➲ ថ្ងៃទី ១៧ កុម្ភៈ ក្នុងពិធីប្រគល់សញ្ញាប័ត្រដល់សិស្សមន្ត្រីជាន់ខ្ពស់ និងមធ្យមនៅវិទ្យាស្ថានជាតិអប់រំសម្ដេចតេជោ **ហ៊ុន សែន** បានរំលឹកថា ធ្វើជាមន្ត្រីគឺជាអ្នកបម្រើប្រជាជន ជាអ្នកផ្ដល់សេវាជូនប្រជាជន មិនមែនទៅធ្វើចៅហ្វាយប្រជាជននោះទេ ត្រូវរួមសុខរួមទុក្ខជាមួយប្រជាជន មិនត្រូវរត់ចោលប្រជាជននៅពេលមានទុក្ខនោះទេ ហើយធ្វើជាមន្ត្រីត្រូវចេះទទួលខុសត្រូវ មិនត្រូវទទួលតែ ( ត្រូវ ) ហើយ ( ខុស ) បែរជាទម្លាក់ទៅឱ្យគេនោះទេ ។

➲ ថ្ងៃទី ១៨ កុម្ភៈ នៅក្នុងឱកាសសម្ពោធជាផ្លូវការយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤- ២០១៨ សម្ដេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ឱ្យដឹងថា ការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយកាលពី ឆ្នាំ២០១៣ កន្លងទៅនេះ ការវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជាបានកើនឡើងដល់ ១២២០ លានដុល្លារអាមេរិក ។

➲ ថ្ងៃទី ១៨ កុម្ភៈ នៅក្នុងកិច្ចប្រជុំនៃក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានមានប្រសាសន៍ថា ឯកឧត្តមនឹងធ្វើការពិនិត្យឡើងវិញបន្ថែមទៀតលើបញ្ហាដែលជាឧបសគ្គដល់ការនាំចេញចំពោះវិស័យឯកជន ដើម្បីធានាឱ្យបានថាផលិតកម្មកែច្នៃសម្រាប់នាំចេញរបស់កម្ពុជា អាចលក់ទៅទីផ្សារបរទេសកាន់តែច្រើនឡើងបន្ថែមទៀត ។

➲ ថ្ងៃទី ១៨ កុម្ភៈ នៅក្នុងជំនួបរវាងក្រុមការងារខាងគណបក្សប្រជាជនកម្ពុជា ដែលដឹកនាំដោយឯកឧត្តម **ប្រាក់ សុខា** និងក្រុមការងារខាងគណបក្សសង្គ្រោះជាតិ ដឹកនាំដោយលោក ស៊ុន ឆ័យ ទទួលបានលទ្ធផល ដោយឈានទៅព្រមព្រៀងបង្កើតគណៈកម្ម-ការចម្រុះរួមមួយដើម្បីរៀបចំក្របខណ្ឌកំណែទម្រង់ការបោះឆ្នោតនាពេលខាងមុខ ។

➲ ថ្ងៃទី ២០ កុម្ភៈ ក្នុងឱកាសបិទសន្និបាតបូកសរុបការងារឆ្នាំ ២០១៣ និងទិសដៅការងារឆ្នាំ ២០១៤ របស់ក្រសួងមហាផ្ទៃ សម្ដេចតេជោ **ហ៊ុន សែន** បានអំពាវនាវឱ្យក្រសួង និងស្ថាប័ននានាត្រូវរួមគ្នាសម្រេចឱ្យបានទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗក្នុងឆ្នាំ ២០១៤ នេះ ។

➲ ថ្ងៃទី ២២ កុម្ភៈ ក្នុងសន្និសីទកាសែតរួមគ្នា បន្ទាប់ពីកិច្ចប្រជុំដោយបិទទ្វារនៅទីស្ដីការក្រសួងរួចមក ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** បានឱ្យដឹងថា ឯក-ឧត្តមបានបញ្ជាក់ទៅកាន់រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី លោកជំទាវ **ជូលី ប៊ីសប់** ( Julie Bishop ) នៅក្នុងកិច្ចប្រជុំនោះថារាជរដ្ឋាភិបាលកម្ពុជាបាន កំពុង និងនឹងធ្វើទៅថ្ងៃខាងមុខគឺស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់របស់កម្ពុជាទាំងអស់ ។

➲ ថ្ងៃទី ២៤ កុម្ភៈ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនៅវិមានសន្តិភាព សម្ដេចតេជោ **ហ៊ុន សែន** បានកោតសរសើរចំពោះការខិតខំប្រឹងប្រែងបំពេញការងាររបស់ក្រុមប្រឹក្សាជាតិ កម្ពុជាដើម្បីស្ត្រីក្នុងរយៈពេល ជាច្រើនឆ្នាំកន្លងមកនេះ ។ សម្ដេចបានជំរុញឱ្យក្រុមប្រឹក្សានេះបន្តអនុវត្តទីការងាររបស់ខ្លួនឱ្យបានកាន់តែខ្លាំងក្លាថែមទៀតដើម្បីឱ្យសម្រេចបានជោគជ័យនូវផែនការសកម្មភាពការងារសំខាន់ៗរបស់ខ្លួនក្នុងឆ្នាំ ២០១៤ និងឆ្នាំជាបន្តបន្ទាប់ទៀត ។

➲ ថ្ងៃទី ២៥ កុម្ភៈ សម្ដេចតេជោ **ហ៊ុន សែន** បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធស្ថានីយអគ្គិសនី ដើរដោយធ្យូងថ្មមានកម្លាំង ១០០ មេហ្គាវ៉ាត់ ស្ថិតនៅឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដែលជាការវិនិយោគរបស់ក្រុមហ៊ុនមកពីប្រទេសម៉ាឡេស៊ីមានតម្លៃសរុបចំនួន ១៩៥,៤ លានដុល្លារ ។/

# លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

### ចំណូលពន្ធដារខែមករា :

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្ហាញថា នៅក្នុងខែមករា ឆ្នាំ២០១៤កន្លងទៅនេះពន្ធដារប្រមូលបានចំណូលពន្ធបង់ចូលថវិកាចំនួន ២៦៥,៦៩ ពាន់លានរៀល ឬប្រមាណ ៦៤,៤ លានដុល្លារអាមេរិក ។ ចំណូលនេះបើប្រៀបធៀបនឹងចំណូលពន្ធដារខែមករាឆ្នាំ ២០១៣ គឺមានការកើនឡើងប្រមាណ ១៤,៦% ។

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងដើមឆ្នាំ ២០១៤ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើង មានដូចជាពន្ធលើប្រាក់បៀវត្សរ៍មានការកើនឡើងប្រមាណ២៤.៨% ពន្ធលើប្រាក់ចំណេញកើនឡើងប្រមាណ ១៨,៣% អាករលើតម្លៃបន្ថែមកើនឡើងប្រមាណ ៣១,១% និងអាករពិសេសកើនឡើងប្រមាណ ១១% ។

ដោយឡែកបើពិនិត្យតាមវិស័យក៏ឃើញថា ចំណូលក្នុងឆ្នាំ ២០១៤ មានការកើនឡើងស្ទើរគ្រប់សកម្មភាព ក្នុងនោះផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២៧,៨% ផ្នែកនីហរ័ណអាហារ័ណកើនឡើងប្រមាណ ៤២,៥% ស្ថាបត្យកម្ម និងសំណង់កើនឡើងប្រមាណ ៤៩,២% ផ្នែកផលិតសម្លៀកបំពាក់កើនឡើង ៣៥% ផ្នែកដឹកជញ្ជូន និងទេសចរណ៍កើនឡើង ២១,៨% អាកាសយានដ្ឋាន និងកំពង់ផែកើនឡើងប្រមាណ ១៣៨,៨% សណ្ឋាគារ និងផ្ទះសំណាក់កើនឡើងប្រមាណ ២៥,៣% និងផ្នែកថ្នាំជក់កើនឡើង ២០៨,៣% ។

### ធនាគារជាតិ :

ធនាគារជាតិនៃកម្ពុជាបានបញ្ជាក់ថា នៅក្នុងឆ្នាំ ២០១៣ សេដ្ឋកិច្ចកម្ពុជា មានអត្រាកំណើនចំនួន ៧,៦% ។ ផលិតផលក្នុងស្រុកសរុបជាមធ្យមសម្រាប់ប្រជាជនម្នាក់ៗបានកើនពី ៧៦០ ដុល្លារ ក្នុងឆ្នាំ ២០០៨ ដល់ ១ ០៣៦ ដុល្លារ នៅឆ្នាំ ២០១៣ ធ្វើឱ្យកម្ពុជានឹងចេញផុតពីប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលឆាប់ៗខាងមុខ ។ លទ្ធផលដ៏វិជ្ជមាននេះ គឺបានមកពីការកើនឡើងនៃការវិនិយោគនៅក្នុងប្រទេសដូចជា វិស័យកសិកម្ម ការនាំចេញសម្លៀកបំពាក់ សំណង់ និងវិស័យទេសចរណ៍ ។ អត្រានៃភាពក្រីក្រ បានកាត់បន្ថយនៅក្រោម ១៩% ដោយភាពក្រីក្រត្រូវបានកាត់បន្ថយជាង ១%ក្នុង ១ ឆ្នាំៗ ។

គួរកត់សម្គាល់ថា កម្ពុជាបាននិងកំពុងធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបន្តអនុវត្តកម្មវិធីកំណែទម្រង់សំខាន់នានា ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។

### វិស័យមីក្រូហិរញ្ញវត្ថុឆ្នាំ២០១៣ :

ធនាគារជាតិនៃកម្ពុជាបានបញ្ជាក់ថា គិតត្រឹមដំណាច់ឆ្នាំ ២០១៣ កន្លងទៅនេះ ទ្រព្យសកម្មសរុបក្នុងវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងប្រមាណ ៤៧,៨% ពីចំនួន ៣ ៨៩០ ពាន់លានរៀល( ប្រមាណ ៩៦២ លានដុល្លារអាមេរិក) ក្នុងឆ្នាំ ២០១២ ដល់ ៥ ៧៥០ ពាន់លានរៀល ក្នុងឆ្នាំ ២០១៣ ។ ឥណទានបានកើនឡើង ៤៣,៦% គឺពីចំនួន ៣ ២៥៣ ពាន់លានរៀល ដល់ ៤ ៦៩២ ពាន់លានរៀល ។ ក្នុងរយៈពេលដូចគ្នានេះដែរ ប្រាក់បញ្ញើកើនឡើង ៦០,២% គឺពីចំនួន ៩០៥ ពាន់លានរៀល ដល់ ១ ៤៥៧ ពាន់លានរៀល និងអ្នកដាក់ប្រាក់បញ្ញើមានចំនួន ៨២០ ១៦០ នាក់ ។ ចំណែកឯអនុបាតឥណទានមិនដំណើរការធៀបនឹងឥណទានសរុបក្នុងវិស័យនេះមានតែ ០,៧%ប៉ុណ្ណោះ ។

បន្ថែមលើការចូលរួមចំណែកក្នុងការផ្ដល់សេវាហិរញ្ញវត្ថុដល់ប្រជាជនក្រីក្រ វិស័យមីក្រូហិរញ្ញវត្ថុក៏បានផ្ដល់ឱកាសការងារដល់សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សាផងដែរ ។ វិស័យមីក្រូហិរញ្ញវត្ថុទទួលបាន នូវការជឿទុកចិត្តកាន់តែច្រើនឡើងពីសាធារណជននិងវិនិយោគិនទាំងក្នុងនិងក្រៅប្រទេស ។ វិស័យមីក្រូហិរញ្ញវត្ថុ កម្ពុជាបានបន្តអភិវឌ្ឍទាំងចំនួនគ្រឹះស្ថាន ទំហំឥណទានប្រភេទប្រតិបត្តិការ និងផលិតផលថ្មីៗ ។

គួររំលឹកថាក្នុងឆ្នាំ២០១៣កន្លងទៅនេះ ប្រព័ន្ធធនាគារនៅកម្ពុជាមានធនាគារពាណិជ្ជចំនួន ៣៥ ធនាគារឯកទេសចំនួន ៩ ការិយាល័យតំណាងធនាគារបរទេសចំនួន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣៨ ( គ្រឹះស្ថានចំនួន ៧ ) ( ទទួលការអនុញ្ញាតឱ្យទទួលប្រាក់បញ្ញើពីសាធារណជន) ប្រតិបត្តិការឥណទានជនបទ ដែលបានចុះបញ្ជីនៅធនាគារជាតិចំនួន ៣៣ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន ២ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ ( ខេមបូឌា) ចំនួន ២ និងតតិយភាគីចំនួន ៣ ។

### ព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជាដោយ IMF

អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានផ្សព្វផ្សាយជាផ្លូវការនូវរបាយការណ៍របស់ខ្លួនកាលពីដើមខែកុម្ភៈ ឆ្នាំ ២០១៤ នេះ ដោយបញ្ជាក់ថា នៅក្នុងឆ្នាំ ២០១៤ នេះ កម្ពុជានឹងទទួលបានកំណើនសេដ្ឋកិច្ចប្រមាណ ៧,២% ពោលគឺប្រសើរជាងការព្យាករណ៍កាលពីឆ្នាំ ២០១៣ កន្លងទៅ ។ មូលហេតុនៃការព្យាករណ៍ដ៏វិជ្ជមាននេះ គឺដោយសារតែកំណើននៃការនាំចេញ ការរីកចម្រើននៃពិពិធកម្មទីផ្សារនាំចេញ ការកើនឡើងនៃការវិនិយោគទុននៃវិស័យសំណង់វិស័យកសិកម្ម និងកំណើនទេសចរណ៍ជាដើម ។

កាលពីឆ្នាំ ២០១៣ អង្គការនេះបានទស្សន៍ទាយថា កម្ពុជាទទួលបានកំណើនត្រឹមតែ ៧% តែប៉ុណ្ណោះ ។ រីឯអតិផរណាវិញ ក៏មានសញ្ញាថយចុះបន្តិចបន្តួច ។ នៅក្នុងឆ្នាំ ២០១៣ អត្រាភាគរយនៃអតិផរណា គឺមាន ប្រមាណ ៤,១% តែនៅក្នុងឆ្នាំ ២០១៤ គឺ នឹងថយចុះមកនៅត្រឹមតែ ៣% តែប៉ុណ្ណោះ ។

IMF ដដែលបានព្យាករណ៍ទៀតថា នៅក្នុងឆ្នាំ ២០១៤ នេះ កម្ពុជានឹងទទួលបានការនាំចេញមានតម្លៃសរុប ប្រមាណ ៨ ពាន់លានដុល្លារអាមេរិក ខណៈដែលឆ្នាំ ២០១៣ ស្ថាប័ននេះបានអះអាងថាមានការនាំចេញប្រមាណ៦,៩ពាន់លានដុល្លារ ។ រីឯការនាំចូលវិញនៅក្នុងឆ្នាំ ២០១៤ នេះ ត្រូវបានព្យាករណ៍ថាមានទំហំប្រមាណ ១១,១៣ ពាន់លានដុល្លារ ខណៈកាលពីឆ្នាំ ២០១៣ មានតម្លៃប្រមាណ ៩,៧ ពាន់លានដុល្លារ ។

### ការនាំចេញសម្លៀកបំពាក់ និងស្បែកជើង :

យោងតាមរបាយការណ៍ពីក្រសួងពាណិជ្ជកម្មបង្ហាញថា ប្រទេសកម្ពុជាបាននាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើង ក្នុងឆ្នាំ ២០១៣ មានទំហំទឹកប្រាក់ចំនួន ៥,៥៣ ពាន់លានដុល្លារអាមេរិក កើនឡើង ២០% បើធៀបនឹងកាលនាំចេញឆ្នាំ ២០១២ ដែលមានទំហំទឹកប្រាក់ចំនួន ៤,៦១ ពាន់លានដុល្លារអាមេរិក ។

ប្រទេសកម្ពុជាបាននាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើងភាគច្រើនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប ។ នៅក្នុងឆ្នាំ ២០១៣ ការនាំចេញសម្លៀកបំពាក់ និងស្បែកជើងពីកម្ពុជាទៅសហរដ្ឋអាមេរិកមានទំហំទឹកប្រាក់ចំនួន ២,១២ ពាន់លានដុល្លារអាមេរិក កើនឡើង ៧,៦១% ខណៈសហគមន៍អឺរ៉ុបក្នុងទំហំទឹកប្រាក់ចំនួន ២ ពាន់លានដុល្លារអាមេរិក កើនឡើង ២៨% និង ១,៤១ ពាន់លានដុល្លារអាមេរិក ត្រូវបាននាំចេញទៅបណ្ដាប្រទេសផ្សេងៗក្នុងតំបន់ និងពិភពលោក ដែលកើនឡើង ៣១,៧៧% បើប្រៀបធៀបជាមួយកាលពីឆ្នាំ ២០១២ ។

### ពាណិជ្ជកម្មកម្ពុជា ជប៉ុន ឆ្នាំ ២០១៣ :

អង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុនបានបញ្ជាក់ថា ពាណិជ្ជកម្មទ្វេភាគីកម្ពុជា ជប៉ុន ក្នុងឆ្នាំ ២០១៣ មានតម្លៃប្រមាណ ៧៩៦,៧ លានដុល្លារ គឺមានការកើនឡើង ២៤% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពី ឆ្នាំ ២០១២ ដែលមាន

៦៤១ លានដុល្លារ ។

តម្លៃទំនិញដែលកម្ពុជានាំចេញទៅកាន់ប្រទេសជប៉ុន មានតម្លៃ ៥៨៦ លាន-ដុល្លារ ពោលគឺកើនឡើងប្រមាណ ៤០៦ លានដុល្លារ ស្មើនឹង ៤៤% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១២ ។ ទំនិញដែលកម្ពុជា នាំចេញទៅកាន់ប្រទេសជប៉ុន រួមមាន ស្បែកជើង សម្លៀកបំពាក់ និងគ្រឿងបង្គុំអេឡិចត្រូនិក ។ ចំណែកទំនិញជប៉ុននាំចូលមកកាន់កម្ពុជាវិញ រួមមាន គ្រឿងម៉ាស៊ីនសម្រាប់ដំណើរការរោងចក្រ រថយន្ត កប៉ាល់ និងទូក ជាដើម ។

**ពាណិជ្ជកម្មកម្ពុជា ថៃឆ្នាំ ២០១៣ :**

ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ថា ទំហំពាណិជ្ជកម្មរវាងកម្ពុជាជាមួយនឹងប្រទេសថៃនាឆ្នាំ២០១៣ មានទំហំរហូតដល់ ៤,៥ ពាន់លានដុល្លារ គឺបានកើនឡើងប្រមាណ ១២% បើធៀបនឹងឆ្នាំ ២០១២ ។ នៅក្នុងទំហំទឹកប្រាក់នេះកម្ពុជានាំចេញទៅថៃគឺមានតម្លៃត្រឹមតែ ៣៥១ លានដុល្លារ ពោលមានការកើនឡើងប្រមាណ៤១% ខណៈដែលថៃនាំចេញមកកាន់ប្រទេសកម្ពុជាមានទំហំ៤,១៥ពាន់លានដុល្លារ ដោយកើនឡើងប្រមាណ ១០% ។

គិតមកដល់ពេលនេះ នៅក្នុងចំណោមប្រទេសជិតខាងកម្ពុជាទាំងបីទំហំពា-ណិជ្ជកម្មជាមួយប្រទេសថៃ ឈរនៅលំដាប់ទីមួយ វៀតណាមទីពីរ និងឡាវនៅលំដាប់ក្រោយគេ ។

ទំនិញដែលកម្ពុជានាំចូលពីប្រទេសជិតខាង ( ថៃ និងវៀតណាម) មានដូចជាគ្រឿងសំណង់ ប្រេងឥន្ធនៈ ហ្គាស គ្រឿងឧបភោគបរិភោគ ភេសជ្ជៈ អេឡិចត្រូនិចគ្រឿងអគ្គីសនីខណៈដែលកម្ពុជានាំចេញទៅប្រទេសទាំងនេះវិញជាផលិតផលកសិកម្ម ។

**វិស័យកៅស៊ូ :**

យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ បានឱ្យដឹងថា ផ្ទៃដីដាំដំណាំកៅស៊ូនៅឆ្នាំ២០១៣នៅទូទាំងប្រទេសមានប្រមាណ៣២៥ ៩០៥ ហ.ត កើន ១៦,៣៦% ធៀបនិងឆ្នាំ ២០១២ ដែលមានផ្ទៃដីដាំដុះកៅស៊ូសរុបមាន ២៨០ ៣៥៥ ហ.ត ។ ផ្ទៃដីដាំដុះជាការវិនិយោគឯកជនមានចំនួន ១៧% ជាលក្ខណៈគ្រួសារមានចំនួន ៤១% ស្មើនឹង ១៣៥ ៤៤៦ហិកតា កំពុងផ្តល់ជ័រកៅស៊ូ និង ៤២% ស្មើនឹង( ១៣៥ ៤៤៦ ហ.ត) ទៀតជាដីសម្បទានសេដ្ឋកិច្ចផ្តល់ដោយរដ្ឋាភិបាលដល់ក្រុមហ៊ុនវិនិយោគបរទេស ។

តាមការរំពឹងទុកផ្ទៃដីដំណាំកៅស៊ូនៅកម្ពុជានឹងកើនឡើងរហូតដល់ ៤៥០ ០០០ ហិកតា នៅក្នុងឆ្នាំ២០២០ ជាមួយនឹងក្តីសង្ឃឹមថានឹងទទួលទិន្នផលប្រមាណ ៤០ ទៅ ៥០ម៉ឺនតោននៅក្នុងមួយឆ្នាំ ។

គួរបញ្ជាក់ដែរថា កាលពីឆ្នាំ២០១៣ កន្លងទៅ ដោយដើមកៅស៊ូភាគច្រើនទើបតែដាំជាកៅស៊ូខ្ចីនោះ កម្ពុជាទើបតែប្រមូលផលបានត្រឹមតែ ៩០ ០០០ តោន ប៉ុណ្ណោះ ។

នៅក្នុងឆ្នាំ ២០១៣ នេះដែរ កម្ពុជាមានរោងចក្រសិប្បកម្មកែច្នៃកៅស៊ូចំនួន ៦០ ក្នុងនោះ មានរោងចក្រកែច្នៃជ័រកៅស៊ូចំនួន ២៣ កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកចំនួន ៣៣ និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន ៤ ។

កាលពីឆ្នាំ ២០១៣ កន្លងទៅនេះដែរ កម្ពុជាបាននាំចេញកៅស៊ូពាក់កណ្តាលកែច្នៃប្រមាណ ៧៤ ២០០ តោន គឺកើនឡើងប្រមាណ ៣៤% បើធៀបនឹងឆ្នាំ ២០១២ ដែលមានចំនួនប្រមាណ ៥៥ ៣៨៤ តោន ។ ជាមួយនេះ បានផ្តល់ប្រាក់ចំណូលប្រមាណ ១៧០ លានដុល្លារ ពោលគឺមានការកើនឡើងប្រមាណ ៦% បើធៀបនឹងឆ្នាំ ២០១២ ដែលការនាំចេញមានចំនួនត្រឹម ១៦០ លានដុល្លារ ។ ទីផ្សារនាំចេញកៅស៊ូកម្ពុជាគឺប្រទេសចិន កូរ៉េខាងត្បូង សិង្ហបុរី ម៉ាឡេស៊ី និងបណ្តាប្រទេសមួយចំនួនទៀតនៅអឺរ៉ុប ។

សូមបញ្ជាក់ថា តម្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិប្រែប្រួលជាបន្តបន្ទាប់ ។ កាលពីឆ្នាំ ២០១៣ កៅស៊ូស្ងួតមានតម្លៃ ៣ ២៩០ ដុល្លារ ក្នុងមួយតោន តែដល់ពេលថ្មីៗនេះ ( ខែកុម្ភៈ) បានធ្លាក់មកនៅប្រមាណ ២ ២០០ ដុល្លារ តែប៉ុណ្ណោះ ។

**អគ្គិសនីឆ្នាំ ២០១៣ :**

អាជ្ញាធរអគ្គិសនីកម្ពុជាបញ្ជាក់នៅក្នុងរបាយការណ៍របស់ខ្លួនថាក្នុងឆ្នាំ ២០១៣ កន្លងទៅនេះ ថាមពលអគ្គិសនីប្រើប្រាស់នៅទូទាំងប្រទេសបានកើនឡើង ២២% ពី ៣,៥២៧ លានគីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១២ ដល់ ៤,២៩៧ លានគីឡូ-វ៉ាត់ម៉ោង នៅឆ្នាំ ២០១៣ ។ អនុភាពប្រភពអគ្គិសនីដែលកម្ពុជាមានបានកើនឡើងដល់ទៅ ៦៦,៧០% លើសពីឆ្នាំមុន គឺពី ៨២២ ម៉េហ្គាវ៉ាត់ នៅឆ្នាំ ២០១២ ឡើងដល់ ១ ៣៧០ ម៉េហ្គាវ៉ាត់ នៅឆ្នាំ ២០១៣ ធ្វើឱ្យប្រភពអគ្គិសនីដែលកម្ពុជាមានអាចគ្របដណ្តប់បានទាំងស្រុងលើសេចក្តីត្រូវការប្រើប្រាស់ទាំងអស់បាន ។ នេះគឺជាលើកទីមួយដែលក្នុងរយៈពេល ៣០ឆ្នាំកន្លងទៅនេះ ដែលការអភិវឌ្ឍប្រភពអគ្គិសនីរបស់រាជរដ្ឋាភិបាលបានកើនឡើងទាន់កំណើននៃសេចក្តីត្រូវការអគ្គិសនីទូទាំងប្រទេស ។ តាមស្ថានភាពនៃការសាងសង់រោងចក្រអគ្គិសនីក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងវិនិយោគដែលបានចុះហត្ថលេខារួចហើយនេះ យើងរំពឹងថាចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៧ នឹងមិនមានបញ្ហាខ្វះប្រភពអគ្គិសនីទេ ។

នៅក្នុងឆ្នាំ ២០១៣ នេះដែរ បានដាក់ឱ្យដំណើរការអនុស្ថានីយ និងបណ្តាញបញ្ជូនថ្មីពីរកន្លែងទៀត គឺអនុស្ថានីយ និងបណ្តាញតភ្ជាប់ពីភ្នំពេញទៅខេត្តកំពង់-ចាម អនុស្ថានីយ និងបណ្តាញបញ្ជូនតភ្ជាប់ពីខេត្តកំពត ទៅខេត្តព្រះសីហនុ ។ បណ្តាញជាតិបច្ចុប្បន្នប្រវែង ១ ៣០៤ គីឡូម៉ែត្រ និងអនុស្ថានីយ ១៧ កន្លែង គ្របដណ្តប់លើខេត្ត ក្រុង ចំនួន ១៣ និងកំពុងបន្តពង្រីកបណ្តាញជាតិពីខេត្តកំពង់ចាមទៅខេត្តក្រចេះ ស្ទឹងត្រែង និងពង្រីកបន្ថែមពីភ្នំពេញ ទៅខេត្តព្រះសីហនុដោយផ្ទាល់មួយខ្សែទៀតដែលសរុបមានប្រវែង ៤៣៨ គីឡូម៉ែត្រ និងអនុស្ថានីយថ្មីបីកន្លែងទៀត ។

នៅក្នុងឆ្នាំ ២០១៣ អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាប័ណ្ណឱ្យអ្នកចែកចាយអគ្គិសនីកម្ពុជា ចំនួន ៣១៧ អាជ្ញាប័ណ្ណ ដែលត្រូវធ្វើការចែកចាយគ្របដណ្តប់លើ១១២១៨ភូមិស្មើនឹង៧៩,៧១% នៃភូមិទូទាំងប្រទេស ។តែអ្នកកាន់អាជ្ញាប័ណ្ណទើបធ្វើការអភិវឌ្ឍបណ្តាញចែកចាយគ្របដណ្តប់លើ ៧ ១៨៧ ភូមិ ស្មើ ៥១,០៧% នៃ ១១ ២១៨ ភូមិ និងភ្ជាប់ចរន្តឱ្យប្រជាពលរដ្ឋប្រើប្រាស់បាន ១ ១២៥ ៦៧៩ កន្លែង ស្មើប្រមាណ ២២៦០ ០០០ ខ្នងផ្ទះ បានន័យថាមានគេហដ្ឋានជិត ៥០% ហើយដែលបានទទួលការផ្តល់សេវាអគ្គិសនីតាមរយៈបណ្តាញដែលបានអភិវឌ្ឍ ។

**ទេសចរណ៍ឆ្នាំ ២០១៣ :**

ទេសចរអន្តរជាតិមកទស្សនាកម្ពុជា រយៈពេល ១២ ខែ ឆ្នាំ ២០១៣នេះ មាន ៤ ២១០ ១៦៥នាក់ កើន ១៧,៥% ធៀបនឹងឆ្នាំ ២០១២ ។ ទីផ្សារទេសចរណ៍សំខាន់ៗមកកម្ពុជាឆ្នាំ ២០១៣ មាន វៀតណាម ៨៥៤ ១០៤នាក់ ចិន ៤៦៣ ១២៣ នាក់ កូរ៉េ ៤៣៥ ០០៩ នាក់ ឡាវ ៤១៤ ៥៣១ នាក់ ថៃ ២២១ ២៥៩ នាក់ ជប៉ុន ២០៦ ៩៣២ នាក់ អាមេរិក ១៨៤ ៩៦៤ នាក់ អូស្ត្រាលី ១៣២ ០២៨ នាក់ រុស្ស៊ី ១៣១ ៦៧៥ នាក់ បារាំង ១៣១ ៤៨៦ នាក់ ។ តាមចំនួននេះយើងអាចទទួលបានចំណូលជូនជាតិប្រមាណ ២ ៥៤៧ លានដុល្លារ ក្នុងកំណើន ១៥,៥% ។

ទេសចរកម្ពុជាចេញទៅក្រៅប្រទេសឆ្នាំ ២០១៣ មានចំនួន ៨៧១ ៦៤៦ នាក់ កើន ១០% ។

រដ្ឋមន្ត្រីក្រសួងទេសចរណ៍បានមានប្រសាសន៍ថា នៅឆ្នាំ ២០១៣ ភ្ញៀវទេសចរពីប្រទេសអូស្ត្រាលីមកកាន់ព្រះរាជាណាចក្រកម្ពុជាបានកើនឡើងជាង ១២ម៉ឺននាក់ ប្រទេសទាំងពីររំពឹងថានឹងកើនឡើងច្រើនជាងឆ្នាំមុន បន្ទាប់ពីបង្កើតឱ្យមានជើងហោះហើរដោយផ្ទាល់ ។

គួរបញ្ជាក់ថា ក្រៅពីគម្រោងបង្កើតជើងហោះហើរដោយផ្ទាល់ជាមួយប្រទេសអូស្ត្រាលី កម្ពុជាក៏គ្រោងនឹងបង្កើតជើងហោះហើរផ្ទាល់ជាមួយនឹងប្រទេសរុស្ស៊ី មជ្ឈិមបូពា ( អារ៉ាប់) និងបណ្តាប្រទេសមួយចំនួននៅអាហ្វ្រិកផងដែរ ។/

# ផលនេសាទឆ្នាំ ២០១៣ កើនលើសពីឆ្នាំមុន ជាង ១៥ %

ឆ្នាំ ២០១៣ ដែលទើបកន្លងផុតទៅថ្មីៗនេះ កម្ពុជាទទួលផលត្រីទាំងទឹកសាប និងទឹកប្រៃ សរុបលើសពីឆ្នាំមុនជាង ១៥% ដោយសារទឹកទន្លេហក់ឡើងខ្ពស់ ហើយប្រជាកសិករនិយមចិញ្ចឹមត្រីច្រើននៅតាមស្រះធម្មជាតិ និងនៅក្នុងស្រែ រួមទាំងការខិតខំទប់ស្កាត់ បង្រ្កាបបទល្មើសនេសាទ និងការព្រលែងកូនត្រីជាដើម ។

តាមរបាយការណ៍របស់រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានឱ្យដឹងថា បរិមាណផលត្រីប្រចាំឆ្នាំ ២០១៣ បានកើនឡើងជាងឆ្នាំមុនរហូតដល់ជាង ១០០ ពាន់តោន ។ ចំនួននេះមានការកើនឡើងក្នុងអាត្រា ១៥% ក្នុងនោះផលត្រីទឹកសាបមានចំនួនជាង ៥៨០ ពាន់តោន ត្រីទឹកប្រៃមានចំនួន ១០០ ពាន់តោន និងត្រីចិញ្ចឹមមានចំនួន ៨០ ពាន់តោន ។ នៅឆ្នាំ ២០១២ ត្រីទឹកសាបមានចំនួនតែ ៥០៩ ពាន់តោន ត្រីទឹកប្រៃមានចំនួន ៩៥ ពាន់តោន និងត្រីចិញ្ចឹមមានចំនួនជាង ២០ ពាន់តោន ។ តួលេខនេះបានបង្ហាញអត្រាកំណើនយ៉ាងខ្ពស់នៃផលត្រីចិញ្ចឹម ។

អ្នកជំនាញជលផលបានឱ្យដឹងថា ការកើនឡើងបរិមាណផលត្រីទឹកសាបដ៏ច្រើននេះ ដោយសារតែទឹកទន្លេឡើងធំ ធ្វើឱ្យត្រីអាចចរាចរទៅមកបានយ៉ាងស្រួលក្នុងការស្វែងរកចំណីហើយក៏ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់មន្រ្តីរាជរដ្ឋាភិបាលក្នុងការអនុវត្តច្បាប់ចុះបង្រ្កាបបទល្មើសនេសាទ និងលែងកូនត្រីពូជជាច្រើនលានក្បាលផងដែរ ។ ម្យ៉ាងទៀត ប្រជាកសិករកាន់តែមានចំនួនច្រើនងាកមកចិញ្ចឹមត្រីតាមលក្ខណៈគ្រួសារ និងលក្ខណៈអាជីវកម្ម ដើម្បីចូលរួមបំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ ។



ផលនេសាទនៅបឹងទន្លេសាប



ប្រជានេសាទប្រមូលផលនេសាទនៅបឹងទន្លេសាប

ចំពោះទិន្នផលបង្កងធម្មជាតិ បានចាប់ផ្តើមកើនឡើងវិញបន្ទាប់ពីបានធ្លាក់ចុះទាបបំផុតនៅឆ្នាំ ២០០៧ ។ ឯកឧត្តម **ណៅ ធួក** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលជលផលបានឱ្យដឹងកាលពីថ្ងៃទី ២៩ មករា ឆ្នាំ ២០១៤ ថា ទិន្នផលបង្កងធម្មជាតិចាប់ផ្តើមកើនឡើងវិញបន្ទាប់ពីបានធ្លាក់ចុះទាបបំផុតនៅឆ្នាំ ២០០៧ ។ ទិន្នផលបង្កងកើនឡើងវិញនេះបន្ទាប់ពីរដ្ឋបាលជលផលបានលែងកូនបង្កងចូលបឹងធម្មជាតិក្នុងមួយឆ្នាំៗមានចំនួនរាប់លានក្បាលរួចមក ។ កូនបង្កងដែលបានលែងចូលបឹងធម្មជាតិកន្លងទៅវាមិនបាននៅរស់ទាំងអស់ទេ គឺនៅសល់ប្រហែលជាបីភាគរយ ។ ប្រភពដដែលបានឱ្យដឹងទៀតថា ទិន្នផលបង្កងនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ៨០ ក្នុងមួយឆ្នាំអាចចាប់បានពីពីរទៅបីរយតោន តែដល់ឆ្នាំ ២០០៧ ចាប់មិនដល់ ១០ តោនទេ ។ ទិន្នផលថយចុះនេះដោយសារមានការនេសាទខុសច្បាប់ច្រើន និងបាត់បង់ជម្រក ។ ពេលនេះ រដ្ឋបាលជលផលបាន និងកំពុងចាត់វិធានការការពារជម្រកបង្កងនៅតំបន់អភិរក្សក្នុងខេត្តតាកែវ ។ ព្រមជាមួយគ្នានេះ ក៏បានចាត់មន្រ្តីជំនាញសិក្សារកលទ្ធភាពបង្កើតតំបន់អភិរក្ស





*សកម្មភាពចុះបង្ក្រាបឧបករណ៍នេសាទខុសច្បាប់*

បង្កងនៅក្នុងខេត្តព្រៃវែង និងហាមការនេសាទបង្កងជាលក្ខណៈគ្រួសារ ចាប់ពីខែកក្កដា ដល់ខែកញ្ញា ក្នុងពេលបង្កងនៅតូចៗ ។ ឯកឧត្តម **ណៅ ធួក** បានបញ្ជាក់ទៀតថាទិន្នផលបង្កងមានការកើនឡើងនៅឆ្នាំនេះ បានធ្វើឱ្យម្ចាស់ជំនួយដល់វិស័យជលផលចាប់អារម្មណ៍ និងមានគំនិតចង់ជួយលុយបន្ថែមសម្រាប់ការងារភ្ញាស់បង្កងឱ្យបានដល់រាប់រយលានក្បាលក្នុងមួយឆ្នាំៗ សម្រាប់លែងចូលបឹងធម្មជាតិ។ ឆ្នាំកន្លងទៅរដ្ឋបាលជលផលមានថវិកាសម្រាប់ភ្ញាស់ត្រី និងបង្កងតិចតួចប៉ុណ្ណោះ ។ រដ្ឋបាលជលផលត្រូវការថវិកាសម្រាប់ភ្ញាស់ត្រី និងបង្កងក្នុងមួយឆ្នាំពី ៣ ទៅ ៥ លានដុល្លារ សម្រាប់លែងចូលបឹងធម្មជាតិ និងតំបន់ទំនាបលិចទឹកដែលមានផ្ទៃក្រឡាប្រមាណជា ៣ លានហ.ត។ ទន្ទឹមនេះ រដ្ឋបាលជលផលត្រូវការថវិកាបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងវិធានការទប់ស្កាត់បទល្មើសនេសាទឱ្យកាន់តែមានប្រសិទ្ធ-ភាព។

ឯកឧត្តម **ណៅ ធួក** បានបញ្ជាក់ថារដ្ឋបាលជលផលត្រូវការថវិ-កាប្រមាណ ១០ ពាន់លានរៀល ស្មើនឹង ២ លាន ៥ សែនដុល្លារក្នុងមួយឆ្នាំៗសម្រាប់យកមកការពារធនធានជលផលដែលជាទ្រព្យមហា-សាលរបស់កម្ពុជា។ ចំពោះផលដែលយើងនឹងទទួលបានមកវិញគឺជាង



*ផលនេសាទនៅបឹងទន្លេសាប*

១ពាន់លានដុល្លារ ដូច្នេះការចំណាយ គឺមិនបាន ១% នៃផលដែលយើងទទួលបាននោះទេ។ ឯកឧត្តមបានបន្តថា នាពេលបច្ចុប្បន្នថវិកាក្នុង ១ ថ្ងៃ សម្រាប់ការបង្ក្រាបបទល្មើសនេសាទមានប្រហែលជា ៧ ម៉ឺនរៀលតែប៉ុណ្ណោះក្នុងមួយខេត្ត។ រដ្ឋបាលជលផលត្រូវការ ២ ទៅ ៣ លានរៀល ក្នុង ១ ថ្ងៃ ហើយកាលពីអាជ្ញាធរទន្លេសាបចុះបង្ក្រាបនៅឯបឹងទន្លេសាបកាលពីឆ្នាំ២០១១ គឺចំណាយក្នុងមួយ ថ្ងៃ ៨ លានរៀល ។

ឯកឧត្តមបានបញ្ជាក់ថា រយៈពេលកន្លងមក ថវិកាសំខាន់បំផុតគឺទទួលបានពីរាជរដ្ឋាភិបាល។ នៅឆ្នាំ ២០១២ រដ្ឋបាលជលផលទទួលបាន ២ ពាន់លានរៀល និងឆ្នាំ ២០១៣ ទទួលបាន ២ ពាន់ ២ រយលានរៀល។ ដោយឡែកក្នុងឆ្នាំ ២០១៤ រដ្ឋបាលជលផលស្នើសុំថវិកាកើនដល់ ៣ ពាន់លានរៀល។ ក្រៅពីទទួលបានថវិកាពីរដ្ឋាភិបាល រដ្ឋបាលជលផលក៏ទទួលបានថវិកាពីអង្គការដៃគូអភិវឌ្ឍន៍មួយចំនួនដែលបានផ្ដល់ថវិកាពី ២០០លាន រៀល ទៅ ៤០០ លានរៀល ក្នុងមួយឆ្នាំ។

ចំពោះការបង្ក្រាបបទល្មើសនេសាទក្នុងឆ្នាំ ២០១៣ រដ្ឋបាលជល-ផលបង្ក្រាបបទល្មើសនេសាទបាន ៣ ៨០២ ករណី ដោយបំផ្លាញចោលឧបករណ៍ស្បៃមុង និងអួនក្រឡាញឹកបានជាង ១ លានម៉ែត្រ មងពាក់នៅកន្លែងអភិរក្សចំនួន ៣៥ ម៉ឺនម៉ែត្រ ឧបករណ៍សម្រាប់ឆក់ត្រីជាង ១ ពាន់គ្រឿង ស្បៃមុងជាង ១៥ ពាន់មាត់ និងសម្ភារៈជាច្រើនទៀតក្នុងនោះបានព្រលែងត្រីជិត ១ រយតោន ចូលក្នុងទន្លេ និងបឹង។

សរុបមកការកើនឡើងនៃផលត្រីក្នុងឆ្នាំ២០១៣គឺអាស្រ័យដោយកំណែទម្រង់របស់រាជរដ្ឋាភិបាលដែលបានលុបឡូត៍នេសាទទឹកសាប ហើយផ្ដល់ឱ្យប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ និងបង្កើតកន្លែងអភិរក្ស ការព្រលែងកូនត្រីចូលក្នុងដែនទឹកធម្មជាតិ ការជំរុញខ្លាំងនូវវារីវប្បកម្ម ព្រមទាំងការប្រឹងប្រែងទប់ស្កាត់បទល្មើសនេសាទ។ ទន្ទឹមនេះវិស័យជលផលនៅតែប្រឈមនឹងបញ្ហាជាច្រើនទៀតដែលត្រូវដោះស្រាយ ជាអាទិ៍ បទល្មើសនេសាទនៅតែបន្តកើតមានយ៉ាងច្រើន ជាពិសេសការប្រើប្រាស់ឧបករណ៍ហាមឃាត់ដែលនឹងបំផ្លាញពូជត្រីក្នុងដែនទឹកធម្មជាតិ ថវិកានៅមានបរិមាណតិចសម្រាប់អភិវឌ្ឍ និងអភិរក្សវិស័យជលផល ទន្ទឹមនេះទឹកទន្លេព្រែកបឹងបួរក៏កាន់តែរាក់ទៅ ការបំផ្លាញជម្រកត្រីពងនៅតែមានបន្ត ឯចំនួនប្រជាជនកាន់តែកើនឡើង ។ ក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការកាន់តែច្រើនឡើង ទាំងតម្រូវការក្នុងស្រុក និងការនាំចេញ ព្រមទាំងបង្កើនកិច្ចការពារធនធានជលផលប្រកបដោយនិរន្តរភាពរដ្ឋបាលជលផលកំពុងជំរុញអនុវត្តនូវផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើវិស័យជលផល រយៈពេល ១០ ឆ្នាំ សំដៅសម្រេចផែនការផលិតត្រីឱ្យបាន ១ លាន ២ សែនតោន នៅឆ្នាំ ២០១៩។/

# ការរីកចម្រើននៃវិស័យសំណង់នៅកម្ពុជា

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានឱ្យដឹងថាវិស័យសំណង់នៅកម្ពុជាបច្ចុប្បន្នមានការរីកចម្រើនយ៉ាងខ្លាំងលើគ្រប់កម្រិត ទាំងសំណង់ទំនើបខ្ពស់ៗ ទាំងសំណង់កម្រិតមធ្យម និងសំណង់កម្រិតទាប ។ ក្នុងរយៈពេល ៩ ខែដើមឆ្នាំ ២០១៣ ការវិនិយោគលើវិស័យសំណង់មាន ២.២៧២ លានដុល្លារសហរដ្ឋអាមេរិក នៅក្នុងគម្រោងសរុបចំនួន ១ ២៤២ គម្រោង បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២កន្លងទៅ មានការកើនឡើង ២៤% ដែលការវិនិយោគពេញមួយឆ្នាំ២០១២ មាន ២ ១១០ លានដុល្លារសហរដ្ឋអាមេរិក ។

រហូតមកទល់នឹងពេលនេះ មានក្រុមហ៊ុនធ្វើអាជីវកម្មសំណង់ដែលបានចុះបញ្ជីនៅក្រសួងដែលមានសុពលភាពចំនួន ៥៧១ ក្រុមហ៊ុន ហើយក្រុមហ៊ុនទាំងនោះបានរួមចំណែកយ៉ាងសកម្មជាមួយនឹងអ្នកវិនិយោគឧស្សាហកម្មសំណង់ក្នុងស្រុក និងក្រៅប្រទេស ។ ក្រុមហ៊ុនដែលមកពីបរទេសគឺមានដូចជា ចិន កូរ៉េខាងត្បូង ម៉ាឡេស៊ី សឹង្ហបូរី ថៃ វៀតណាម អាល្លឺម៉ង់ និងបារាំង ជាដើម ។

ដោយឡែកយោងរបាយការណ៍របស់រាជធានីភ្នំពេញបានបង្ហាញដែរថា ក្នុងរយៈពេលជាង ១០ ឆ្នាំចុងក្រោយនេះ វិស័យសំណង់មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងនោះមានអគារខ្ពស់ៗបូរីនិងទីក្រុងរណបយ៉ាងច្រើនត្រូវបានសាងសង់រួច និងកំពុងសាងសង់ ។ គិតត្រឹមឆ្នាំ ២០១៣ អគារខ្ពស់ៗមានជាង ៣៨០ អគារ ដោយក្នុងនោះអគារមានកម្ពស់ចាប់ពី ៥ ជាន់ ទៅ ៩ ជាន់ មានចំនួន ៣១០ អគារ អគារមានកម្ពស់ចាប់ពី ១០ ជាន់ ទៅ ១៩ ជាន់ មានចំនួន ៦៣ អគារ អគារមានកម្ពស់ចាប់ពី២០ជាន់ទៅ២៩ជាន់ មានចំនួន៣ អគារ អគារមានកម្ពស់ចាប់ពី៣០ជាន់ទៅ៣៩ជាន់ មានចំនួន៥អគារ អគារមានកម្ពស់ចាប់ពី ៤០ ជាន់ឡើងទៅ មានចំនួន ១អគារ និងបូរីមានចំនួនទាំងអស់ ៧២ បូរី ។

គម្រោងដែលបានទទួលអនុញ្ញាតឱ្យសាងសង់នៅក្នុងឆ្នាំ ២០១៣ កន្លងមកនេះ មានដូចជាគម្រោងសាងសង់អគារពាណិជ្ជកម្ម អគារកាស៊ីណូ សំណង់លំនៅស្ថានស្នាក់នៅ រោងចក្រ ឧស្សាហកម្មរ៉ែលោហៈ អគារសណ្ឋាគារ រោងចក្រផលិតបារី រមណីយដ្ឋាន វិទ្យាស្ថាន ស្ថានីយប្រេងឥន្ធនៈ រោងចក្រផលិតខ្សែគ្រឿង អេឡិចត្រូនិក អគារអាផាតមិន អគារភូមិគ្រឹះ ផ្សារ ឃ្លាំង អគារកីឡា អគាររោងចក្រកាត់ដេរ ។ល។

តាមរបាយការណ៍ដែលបង្ហាញដោយក្រុមហ៊ុនអចលនទ្រព្យ វីត្រាស (VTrust) បានឱ្យដឹងថាចំនួនអាផាតមិន (apartment) ថ្មីៗក្នុងទីក្រុងភ្នំពេញបានកើនដល់ ១៧៥ អគារ នៅក្នុងត្រីមាសទី ៤ ឆ្នាំ



*ការដ្ឋានសំណង់អគារដែលកំពុងសាងសង់នៅតាមដងវិថីព្រះមុនីវ៉ង្ស*

២០១៣ដែលបានផ្តល់ជាបន្ទប់សរុបប្រមាណ ៣.៤០០ បន្ទប់ ។ របាយការណ៍ក៏បានបញ្ជាក់ថា អគារអាផាតមិនថ្មីៗ ទាំងនោះ ភាគច្រើនមានទីតាំងនៅតំបន់បឹងកេងកងទី ១ ខណ្ឌ ៧ មករា ខណ្ឌទួលគោក ខណ្ឌដូនពេញ និងខណ្ឌចំការមន ។ តាមការកត់សម្គាល់របស់ក្រុមហ៊ុន វីត្រាស កាលពីដើមឆ្នាំ ២០១៣ ចំនួនប៉ាន់ស្មាននៃអគារអាផាតមិនថ្មីនឹងមានចំនួន ៤២ អគារក្នុងឆ្នាំ ២០១៤ បន្ថែមលើការផ្គត់ផ្គង់ ដែលមានស្រាប់ចំនួន ១៥០ អគារ ។

ជាមួយគ្នានេះដែរ នៅក្នុងឆមាសទី ២ នៃឆ្នាំ ២០១៣ ក្រុមហ៊ុន Anna Cam ដែលជាក្រុមហ៊ុនផ្តល់ សេវាអចលនទ្រព្យដ៏ល្បីឈ្មោះនៅរាជធានីភ្នំពេញជូនដល់វិនិយោគិនជប៉ុនបានរៀបចំទស្សនកិច្ចរបស់អ្នកវិនិយោគរាប់សិបនាក់មកពីប្រទេសជប៉ុន ដែលភាគច្រើនបានទិញខុនដូនៅក្នុងរាជធានីភ្នំពេញ ជាពិសេសខុនដូរបស់ដឺខាសល រ៉ូយ៉ាល់ (De Castle Royal) នៅក្នុងសង្កាត់បឹងកេងកងទី ១ ។

តាមការប៉ាន់ស្មានដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ វិស័យសំណង់ ដែលគ្របដណ្តប់ក្នុងរាជធានីភ្នំពេញ នៅក្នុងឆ្នាំ ២០១៣ មានតម្លៃផ្លូវការចំនួន ១ ៥១៨ លានដុល្លារអាមេរិក គឺកើនលើសជាង ៥០% បើធៀបទៅនឹងឆ្នាំ២០១២ ។

លោក ជា ស្រ៊ុន ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់និងសុរិយោដីរាជធានីភ្នំពេញបានឱ្យ ដឹងថា ចំណូលពន្ធប្រថាប់ត្រាដែលមន្ទីររាជធានីភ្នំពេញទទួលបានកាលពីឆ្នាំ ២០១៣ ចំនួន ១៤៣ ០៩៧ ៦១៥ ០០០ រៀល ធៀបនឹងចំណូលពន្ធប្រថាប់ត្រាឆ្នាំ ២០១២ បានចំនួន ១២៨ ០៩៧ ០០០ ០០០រៀល កើនឡើងចំនួន ១១,៧១ % ។

ជាមួយគ្នានេះ ឯកឧត្តម **ខ្វាង ស៊ុផាន់** អភិបាលរងរាជធានីភ្នំពេញក៏បានឱ្យដឹងដែរថា រយៈពេល ១០ ឆ្នាំចុងក្រោយនេះ រាជធានីភ្នំពេញទទួលបានការអភិវឌ្ឍយ៉ាងលឿន ។ ប្រជាពលរដ្ឋបានកើន




ការដ្ឋានសំណង់អគារខ្ពស់ៗដែលកំពុងសាងសង់ជាបន្តបន្ទាប់នៅរាជធានីភ្នំពេញ




៣,១៥% ក្នុងមួយឆ្នាំ ។ រាជធានីភ្នំពេញត្រូវបានពង្រីកផ្ទៃដីក្រុង ដើម្បីគ្រប់គ្រងប្រជាពលរដ្ឋ ១,៥ លាននាក់ ជាមួយនឹងដង់ស៊ីតេ ប្រមាណ ៤ ០០០ នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា ។ នៅឆ្នាំ ២០២០ រាជធានីភ្នំពេញនឹងមានប្លង់គោលជាយុទ្ធសាស្ត្រតម្រង់ទិសសម្រាប់ការអភិវឌ្ឍនគរូបនីយកម្ម និងសេដ្ឋកិច្ច ប្រកបដោយនិរន្តភាពធានាដល់ការប្រើប្រាស់ដីធ្លី និងសក្តានុពលដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព ធានាសន្តិសុខស្បៀងសោភ័ណភាព និងគុណភាពបរិស្ថាន ។

អ្នកជំនាញនៅក្នុងវិស័យនេះបានវាយតម្លៃថា ការរីកចម្រើននៃវិស័យឧស្សាហកម្មសំណង់នៅកម្ពុជា កំពុងបង្កើតការងារយ៉ាងច្រើនដល់ប្រជាជនព្រមទាំងបានជួយជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសឱ្យកាន់តែមានភាពល្អប្រសើរទៀតផង ។ វិស័យសំណង់កំពុងត្រូវការកម្មករច្រើនទាំងអ្នកមានជំនាញនិងគ្មានជំនាញដូចជាអ្នកបច្ចេកទេសទឹក អគ្គិសនី ជាងកំបោរ សន្តិសុខ កម្មករអនាម័យ និងអ្នកគ្រប់គ្រង ។ នៅពេលដែលប្រជាជនមានប្រាក់ចំណូលកើនឡើងនឹងធ្វើឱ្យមានលំហូរទុនទៅក្នុងវិស័យសេដ្ឋកិច្ច ដែលនឹងជួយជំរុញឱ្យសេដ្ឋកិច្ចកាន់តែមានការរីកចម្រើន ។

បច្ចុប្បន្ននេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងសហការជាមួយស្ថាប័នសមភាគីនៃបណ្តាប្រទេសមួយចំនួន ដូចជាសិង្ហបុរី និងសាធារណរដ្ឋកូរ៉េជាដើម ដើម្បីកសាងច្បាប់សំណង់មួយឱ្យឆ្លើយតបនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យនេះនៅកម្ពុជា ដែលក្នុងនោះក៏នឹងមានការចែងអំពីការចែករំលែកមុខងារទទួលខុសត្រូវខាងបច្ចេកទេសដល់វិស័យឯកជនផងដែរ ។ នេះគឺជាការខិតខំអនុវត្តការងារបន្ថែមទៀតរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើយ៉ាងណាឱ្យវិស័យសំណង់មានការកើនឡើងថែមទៀត ស្របទៅតាមអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់វិស័យមួយនេះឱ្យឃើញពីភាពរស់រវើកនៃសកម្មភាពសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជន ។/



# ទេសចរណ៍កម្ពុជាឆ្នាំ ២០១៣ ស្រូបបានប្រាក់ចំណូលជាង ២.៥០០ លានដុល្លារ

## ✵ ឆ្នាំ ២០១៤ កម្ពុជាអាចនឹងទទួលទេសចរអន្តរជាតិបាន ៤,៧ លាននាក់





ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទស្សនាប្រាង្គប្រាសាទនានាក្នុងខេត្តសៀមរាប

ខណៈចំណូលដែលបានមកពីវិស័យនាំចេញសម្លៀកបំពាក់របស់កម្ពុជាមានទំហំទឹកប្រាក់ជាង ៥.០០០ លានដុល្លារអាមេរិកនោះវិស័យទេសចរណ៍នាឆ្នាំ ២០១៣ កន្លងទៅនេះ ក៏បានស្រូបយកចំណូលជាង ២.៥០០ លានដុល្លារ ជាមួយនឹងចំនួនទេសចរអន្តរជាតិចំនួន ៤២១០១៦៥ នាក់។ ក្នុងចំណោមភ្ញៀវទេសចរសំខាន់ៗចំនួន ១០ ប្រទេស ដែលមកទស្សនាកម្ពុជានោះ ទេសចរនៃប្រទេសវៀតណាមបានឈរនៅលំដាប់ទី ១ ។ ចំណែកទេសចរចិននៅលំដាប់ទី ២ និងកូរ៉េនៅលំដាប់ទី ៣។

យោងតាមរបាយការណ៍សង្ខេបប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍បានបង្ហាញឱ្យឃើញថា ឆ្នាំ ២០១៣ កន្លងទៅនេះ ចំនួនភ្ញៀវទេសចរអន្តរជាតិចូលមកទស្សនាកម្ពុជាមានចំនួន ៤.២១០.១៦៥ នាក់។ ចំនួននេះមានកើនឡើង ១៧,៥% បើធៀបនឹងឆ្នាំ ២០១២។ ភ្ញៀវទេសចរអន្តរជាតិដែលបានមកកំសាន្តនៅកម្ពុជាទាំងអស់នោះបានចូលតាមផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក។

ការចូលតាមផ្លូវអាកាសមានចំនួន ២.០១៧.៦៥៨ នាក់ស្មើនឹង ៤៧,៩%នៃចំនួនសរុប គឺបានកើនឡើង ១៧,២% បើធៀបនឹងឆ្នាំ ២០១២។ ក្នុងចំនួននេះ គឺចូលតាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញចំនួន ៨៣៦.៣៧៧ នាក់ស្មើនឹងចំនួន ១៩,៩% នៃចំនួនសរុបកើនឡើង ១៦,៧% និងអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាបចំនួន ១.១៨១.២៨១ នាក់ ស្មើ ២៨,១%នៃចំនួនសរុបកើនឡើង ១៧,៥%។ការចូលតាមផ្លូវគោកមានចំនួន២.១១៧.៤៥៤នាក់ស្មើនឹងចំនួន ៥០,៣% នៃចំនួនសរុបកើន ១៨,៦% និងចូលតាមផ្លូវទឹកចំនួន ៧៥.០៥៣ នាក់ ស្មើនឹង ១,៨% នៃចំនួនសរុបគឺថយចុះ ១,៩%។



ភ្ញៀវទេសចរជាតិ និងអន្តរជាតិ កំសាន្តសប្បាយតាមឆ្នេរសមុទ្រ ខេត្តព្រះសីហនុ

នៅក្នុងសកម្មភាពទាក់ទាញទេសចរណ៍ក្នុងឆ្នាំ ២០១៣ នេះដែរ ទីផ្សារទេសចរណ៍សំខាន់ៗដែលមកទស្សនាកម្ពុជាមានចំនួន ១០។ ក្នុងនោះទី១.គឺទេសចរវៀតណាមមានចំនួន ៨៥៤.១០៤ នាក់ ស្មើនឹង ២០,៣% នៃចំនួនសរុបពោលមានការកើនឡើងចំនួន ១១,៩% បើធៀបនឹងឆ្នាំ ២០១២។ ទី២. ទេសចរចិនមានចំនួន ៤៦៣.១២៣ នាក់ស្មើនឹង ១១% នៃចំនួនសរុបកើនឡើង ៣៨,៧%។ ទី៣.ទេសចរកូរ៉េចំនួន ៤៣៥.០០៩ នាក់ ស្មើនឹង ១០,៣% នៃចំនួនសរុបកើនឡើង ៥,៧%។ ទី៤. ទេសចរឡាវចំនួនសរុប ៤១៤.៥៣១ នាក់ ស្មើនឹងចំនួន ៩,៨% នៃចំនួនសរុបកើនឡើង ៦៣,២%។ ទី៥. ទេសចរថៃចំនួន ២២១.២៥៩ នាក់ ស្មើនឹងចំនួន ៥,៣% នៃចំនួនសរុប កើនឡើង ៩,៨%។ទី៦.ទេសចរជប៉ុនចំនួន ២០៦.៩៣២ នាក់ ស្មើនឹងចំនួន ៤,៩% នៃចំនួនសរុបកើនឡើងចំនួន ១៥,៤%។ ទី៧.ទេសចរអាមេរិកចំនួន ១៨៤.៩៦៤ នាក់ ស្មើនឹង ៤,៤% នៃចំនួនសរុបកើនឡើង៦,៩%។ទី៨. ទេសចរអូស្ត្រាលីចំនួន ១៣២.០២៨ នាក់ ស្មើនឹងចំនួន ៣,១% នៃចំនួនសរុបកើនឡើង ១២,១%។ ទី៩.ទេសចរ រុស្ស៊ីចំនួនសរុប ១៣១.៦៧៥ ស្មើនឹងចំនួន ៣,១%នៃចំនួនសរុប កើនឡើង ៣២% និងទី១០.ទេសចរបារាំងចំនួន ១៣១.៤៨៦ នាក់ ស្មើនឹងចំនួន ៣,១% នៃចំនួនសរុបកើនឡើង ៨,៥%។



*ភ្ញៀវទេសចរជាតិ និងអន្តរជាតិ កំសាន្តនៅរមណីយដ្ឋានធម្មជាតិ ទឹកជ្រោះភ្នំគូលែន ខេត្តសៀមរាប*



*ភ្ញៀវទេសចរជាតិ និងអន្តរជាតិ កំសាន្តនៅរមណីយដ្ឋានធម្មជាតិ ទឹកជ្រោះប៊ូស្រា ខេត្តមណ្ឌលគិរី*



*ភ្ញៀវទេសចរជាតិ និងអន្តរជាតិ កំសាន្តនៅរមណីយដ្ឋានធម្មជាតិ ព្រៃកោងកាង ខេត្តកោះកុង*

ក្រសួងទេសចរណ៍ក៏បានបញ្ជាក់ផងដែរអំពីប្រភពទីផ្សារទេស-ចរណ៍សំខាន់ៗមកទស្សនាកម្ពុជាឆ្នាំ ២០១៣ ធៀបនឹងឆ្នាំ ២០១២ ក្នុងនោះទី១.មកពីតំបន់អាស៊ីប៉ាស៊ីហ្វិកមានចំនួន ៣.២៣១.៨៩២ នាក់ ស្មើនឹងចំនួន ៧៦,៨% នៃចំនួនសរុបគឺកើនឡើង ១៩,២% ( មកពីតំបន់អាស៊ានមានចំនួន ១.៨៣១.៥០៧ នាក់ ស្មើនឹង ៤៣,៥% នៃចំនួន សរុបកើនឡើង ២១%) ។ ទី២.មកពីតំបន់អឺរ៉ុបមានចំនួន ៧៩៨.១៥៧ នាក់ ស្មើនឹង ១៦,៦% នៃចំនួនសរុប កើនឡើង ១៤,២% ។ ទី៣.មកពីតំបន់អាមេរិកចំនួន២៦៣.១៧៥នាក់ស្មើនឹង៦,៣% នៃចំនួនសរុបកើនឡើង ៧,៧% ។

គួរគត់សម្គាល់ថា ភ្ញៀវទេសចរអន្តរជាតិដែលបានមកទស្សនាកម្ពុជា បានទៅទស្សនាតំបន់អាទិភាពមួយចំនួន ក្នុងនោះតំបន់ខេត្តសៀមរាបមានច្រើនជាងគេ ។ តំបន់សៀមរាបអង្គរទទួលបានភ្ញៀវទេសចរចំនួន ២.២៣៧.២៨៦ នាក់ស្មើនឹងចំនួន ៤៦,៩% នៃចំនួនសរុបគឺបានកើនឡើងចំនួន ៨,៤% ធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំមុន ។ តំបន់រាជធានីភ្នំពេញទទួលបានចំនួន ១.៩៧២.៨៧៩ នាក់ កើនឡើង ២៩,៧% ។ តំបន់ឆ្នេរសមុទ្រ ទទួលបានចំនួន ៤៩៦.៨៨០ កើនឡើង ៧៧% ។ តំបន់អេកូទេសចរណ៍ភូមិភាគឦសានទទួលបានចំនួន ៥៩.៧៧២ នាក់កើនឡើង ១២% និងតំបន់ប្រាសាទព្រះវិហារខេត្តព្រះវិហារទទួលបានចំនួន ២៤.៥៥០ នាក់ កើនឡើង ២៧,៩% ។ គួរបញ្ជាក់ថា នៅតំបន់ប្រាសាទព្រះវិហារនេះដែរទេសចរជាតិចំនួន ៤៦.៧៥៧ នាក់ បានទៅទស្សនាទីនោះ ។ តួលេខនេះបានបង្ហាញថា មានការថយចុះចំនួន ៣,៣% បើធៀបនឹងឆ្នាំ ២០១២ ។

ក្រសួងទេសចរណ៍បានបញ្ជាក់ថា តាមការសិក្សានិងវាយតម្លៃរបស់អ្នកសេដ្ឋកិច្ចទេសចរណ៍បានឱ្យដឹងថា ជាមួយនឹងចំនួនទេសចរណ៍អន្តរជាតិចំនួន ៤.២១០.១៦៥ នាក់ នៅឆ្នាំ ២០១៣ នោះ វិស័យទេសចរណ៍បាននាំមកនូវប្រាក់ចំណូលជូនជាតិប្រមាណ ២.៥៤៧ លានដុល្លារអាមេរិក ពោលគឺមានកំណើន ១៥,៥% ។ ក្រសួងទេសចរណ៍ ក៏បានព្យាករណ៍ថា នៅឆ្នាំ ២០១៤ នេះ កម្ពុជានឹងទទួលបាននូវទេសចរអន្តរជាតិយ៉ាងហោចណាស់ចំនួន ៤,៧ លាននាក់ ខណៈដែលកម្ពុជាកំពុងតែធ្វើការកែលម្អលើសេវាទាំងឡាយដែលបម្រើឱ្យវិស័យទេសចរណ៍ និងមានយុទ្ធនាការទាក់ទាញជាច្រើនថែមទៀតនៅក្នុងវិស័យនេះ ជាមួយនឹងដំណើរការបង្កើនជើងហោះហើរត្រង់ពីប្រទេសមួយចំនួនថែមទៀតដែលអាចកើតឡើងនៅក្នុងឆ្នាំនេះ ។

ដោយឡែកទន្ទឹមនឹងចំនួនទេសចរអន្តរជាតិចូលមកទស្សនាព្រះ-រាជាណាចក្រកម្ពុជាកាន់តែកើនឡើងនៅឆ្នាំ ២០១៣ នោះ ចំនួនប្រជាពលរដ្ឋកម្ពុជាចេញទៅទស្សនានៅក្រៅប្រទេសក៏មានការកើន ឡើងដូចគ្នានេះដែរ ។ ប្រជាជនកម្ពុជាចំនួន ៨៧១.៦៤៦ នាក់ បានចេញទៅកំសាន្តនៅក្រៅប្រទេសពោល គឺកើនឡើង ១០% បើធៀបនឹងឆ្នាំ ២០១២ ។ កំណើននេះបានឆ្លុះបញ្ចាំងអំពីកម្រិតជីវភាពរបស់ប្រជា-ពលរដ្ឋកម្ពុជាដែលកាន់តែមានលក្ខណៈប្រសើរឡើងៗថែមទៀត ។/



*រមណីយដ្ឋានធម្មជាតិកាំពិ ក្នុងខេត្តក្រចេះ*

# មហោស្រពខ្លែងខ្មែរលើកទី ១៧



*ឯកឧត្តម **សំរ៉ាំង  កំសាន្ត** ផ្ដល់ពានរង្វាន់ដល់ជ័យលាភី*

នៅព្រឹកថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០១៤ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានប្រារព្ធបើកមហោស្រពខ្លែងខ្មែរលើកទី១៧ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដែលប្រព្រឹត្តទៅនៅលើទីវាលនៃមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ ។

ក្នុងឱកាសបើកមហោស្រពនាពេលនោះ ឯកឧត្តម **សំរ៉ាំង  កំសាន្ត** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានមានប្រសាសន៍ថា ការបង្ហោះខ្លែងមិនគ្រាន់តែបង្ហាញឱ្យមានភាពសប្បាយរីករាយប៉ុណ្ណោះទេ តែវាជាការផ្ទេរចំណេះដឹងទំនៀមទម្លាប់ប្រពៃណីដល់កូនចៅខ្មែរជំនាន់ក្រោយៗឱ្យបានស្គាល់បានយល់ដឹង និងកាន់តែស្រឡាញ់វប្បធម៌ជាតិ ដើម្បីបន្តប្រតិបត្តិធ្វើឱ្យអត្តសញ្ញាណជាតិដែលបុព្វបុរសខ្មែរបានប្រារព្ធតាំងពី៤០០ ឆ្នាំមុន គ.ស មកនោះ (គឺតាំងពីគ្រាដែលខ្មែរយើងពុំទាន់ទទួលអារ្យធម៌ឥណ្ឌា) ឱ្យគង់វង្សស្ថិតស្ថេរជានិរន្តរ៍តទៅ ។

លោក ហ៊ឹម វិបុលផល ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ និងជាប្រធានគណៈកម្មការរៀបចំមហោស្រពខ្លែងខ្មែរបានបញ្ជាក់ជូនភ្ញៀវជាតិ និងអន្តរជាតិអំពីគោលបំណងនៃមហោស្រពនេះ គឺសំដៅពង្រីក និងផ្សព្វផ្សាយវប្បធម៌លើផ្នែកខ្លែងខ្មែរលើឆាកអន្តរជាតិ ប្រើប្រាស់សក្ដានុពលវប្បធម៌ខ្មែរជាគ្រឹះជំរុញកំណើនវិស័យទេសចរណ៍ និងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ប្រែក្លាយព្រះរាជាណាចក្រកម្ពុជា ជាមជ្ឈមណ្ឌលផ្សព្វផ្សាយវប្បធម៌ខ្មែរ និងអប់រំកូនចៅខ្មែរជំនាន់ក្រោយឱ្យទទួលយក និងថែរក្សាទំនៀមទម្លាប់ប្រពៃណីនៃការបង្ហើរខ្លែងខ្មែរតទៅអនាគត ។

គួររំឭកថា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានប្រារព្ធបើកមហោស្រពខ្លែងខ្មែរក្នុងក្របខ័ណ្ឌទូទាំងប្រទេសបានចំនួន ១៦ លើករួចមកហើយ ។នៅលើកទី ១៧ នេះ មានប្រតិភូខ្លែងខ្មែរមកចូលរួមចំនួន ១៨ រាជធានីខេត្ត និងបេក្ខជនស្ទៃវិនចំនួន ៣០ នាក់ ។

នៅក្នុងការប្រកួតនេះ ក្រោមការពិនិត្យយ៉ាងសុក្រឹតពីគណៈមេប្រយោគខ្លែងខ្មែរ ដែលទទួលពានរង្វាន់លេខ ១ បានទៅលើខ្លែងមកពីខេត្តកណ្ដាល ពានរង្វាន់លេខ ២ បានទៅលើខ្លែងមកពីខេត្តស្ទឹងត្រែង និងពានរង្វាន់លេខ ៣ បានទៅលើខ្លែងមកពីខេត្តកំពង់ឆ្នាំង ។

រីឯលទ្ធផលខ្លែងរបស់បេក្ខជនស្ទៃវិនគឺ ៈ

-រង្វាន់លេខ ១ បានទៅលើខ្លែង លោក រឿង ដារ៉ូ ប្រភេទខ្លែងរទេះភ្លើង ។

-រង្វាន់លេខ ២ បានទៅលើខ្លែង លោក



*ជ័យលាភីខ្លែងចំណាត់ថ្នាក់លេខ ១ ខេត្តកណ្ដាល*



*ជ័យលាភីខ្លែងចំណាត់ថ្នាក់លេខ ២ ខេត្តស្ទឹងត្រែង*



ជ័យលាភីខ្លែងចំណាត់ថ្នាក់លេខ ៣ ខេត្តកំពង់ឆ្នាំង



ប្រតិភូរាជធានី ខេត្ត ចូលរួមក្នុងមហោស្រពខ្លែង

ពោធិវិរៈប្រភេទខ្លែងប្រឡៅ ។

-រង្វាន់លេខ ៣ បានទៅលើខ្លែង លោក លីវុទ្ធី ប្រភេទខ្លែងមាន់ថៃ ។

ជ័យលាភីមកពីរាជធានីខេត្តដែលបានចំណាត់ថ្នាក់លេខ ១ ទទួលបានពានប្រាក់មួយ ប័ណ្ណសរសើរមួយសន្លឹក និងទឹកប្រាក់ ៤០០ ០០០រៀលចំណាត់ថ្នាក់លេខ២ទទួលប័ណ្ណសរសើរមួយសន្លឹកនិងទឹកប្រាក់៣០០០០០រៀល ចំណាត់ថ្នាក់លេខ ៣ ទទួលប័ណ្ណសរសើរមួយសន្លឹក និងប្រាក់ ២០០ ០០០ រៀល ។

ជ័យលាភីបេក្ខជនស្វែរិនចំណាត់ថ្នាក់លេខ១ទទួលបានពានប្រាក់មួយប័ណ្ណសរសើរមួយសន្លឹក និងជាមួយទឹកប្រាក់ ៣០០ ០០០ រៀល ជ័យលាភីលេខ ២ ទទួលប័ណ្ណសរសើរមួយសន្លឹក ទឹកប្រាក់ ២០០ ០០០ រៀល និង ជ័យលាភីលេខ៣ ទទួលប័ណ្ណសរសើរមួយសន្លឹក ទឹកប្រាក់ ១៥០ ០០០ រៀល ។

សូមបញ្ជាក់ថា ចំពោះខ្លែងដែលប្រកួតក្នុងក្របខណ្ឌរាជធានី ខេត្ត គឺជាប្រភេទខ្លែងព្នងខ្នាតធំដូចគ្នា ។ ចំពោះខ្លែងរបស់បេក្ខជនស្វែរិនដែលចូលរួមប្រកួតគឺជាប្រភេទខ្លែងច្នៃប្រឌិតដោយសេរី ។

គួររំឭកថាចំពោះការប្រកួតខ្លែងជាអន្តរ-ជាតិយើងបានរៀបចំមហោស្រពចំនួន ៣ លើក ៖

-លើកទី ១ ឆ្នាំ ២០០៤ នៅភ្នំពេញមានខ្លែងអន្តរជាតិចូលរួមចំនួន ៥ ប្រទេស ។

-លើកទី២ ឆ្នាំ២០០៦ នៅខេត្តសៀមរាប មានខ្លែងអន្តរជាតិចូលរួមចំនួន១៧ប្រទេស ។

-លើកទី ៣ ឆ្នាំ ២០១០ នៅខេត្តកោះកុង មានខ្លែងអន្តរជាតិចូលរួមចំនួន ៩ ប្រទេស ។



ជ័យលាភីខ្លែងចំណាត់ថ្នាក់លេខ ១ បេក្ខជនស្វ័យរិន ដែលបានចូលរួមក្នុងមហោស្រពខ្លែង

**សកម្មភាពប្រកួតខ្លែងជាអន្តរជាតិ ៖**

ខ្លែងខ្មែរបានចូលរួមបង្ហោះក្នុងមហោស្រពអន្តរជាតិចំនួន ៦៥ លើក ក្នុងនោះនៅប្រទេសបារាំង ១៣ លើក ប្រទេស អ៊ីតាលី ៨ លើក ប្រទេសម៉ាឡេស៊ី ១៦ លើក ប្រទេសអង់គ្លេស ៣ លើក ប្រទេសឥណ្ឌូនេស៊ី ៣ លើក ប្រទេសឥណ្ឌា ៦ លើក ប្រទេសវៀតណាម៥ លើក ប្រទេសជប៉ុន ២ លើក ប្រទេសចិន ៤ លើក ប្រទេសព្រុយណេ ១ លើក ប្រទេស កូរ៉េខាងត្បូង ១ លើក ប្រទេសថៃ ១ លើក ប្រទេសសឹង្ហបូរី ២ លើក ។

ព្រឹត្តិការណ៍ដែលគួរកត់សម្គាល់គឺក្នុងការចូលរួមប្រកួតជាអន្តរជាតិឆ្នាំ ២០០៧ ខ្លែងខ្មែរបានទទួលចំណាត់ថ្នាក់កម្រិតពិភពលោកលេខ ៣ (មេដាយសំរិទ្ធ) ឆ្នាំ ២០០៨ ខ្លែងខ្មែរបានទទួលពានរង្វាន់លេខ៣ផ្នែកគំនូរទេពអប្សរនៅលើខ្លែងនៅប្រទេសឥណ្ឌានៅឆ្នាំ ២០០៨ នោះដែរ ខ្លែងខ្មែរបានទទួលរង្វាន់ពិសេសលើផ្នែកតូរ្យតន្ត្រីភ្ជាប់ជាមួយខ្លែងនៅទីក្រុងយ៉ែបប្រទេសបារាំង ។ លទ្ធផលទាំងនោះ គឺជាកិត្តិយសសម្រាប់ព្រះរាជាណាចក្រកម្ពុជា ។/

# ទាំងអស់គ្នាត្រូវតស៊ូពន្យឺតការកើនឡើងកម្ដៅលើផែនដី

នៅពេលបានស្ដាប់សុន្ទរកថារបស់លោកប្រធានាធិបតីអាមេរិក *បារ៉ាក់ អូបាម៉ា* ហាក់ដូចជាងាយស្រួលណាស់ដើម្បីធ្វើសេចក្ដីសន្និដ្ឋានថា យើងកំពុងធ្វើដំណើរយឺត ប៉ុន្តែពិតជាទទួលបានជោគជ័យនៅក្នុងសង្គ្រាម "ការផ្លាស់ប្ដូរអាកាសធាតុ Climate Change" ។ នយោបាយស្ដីអំពីថាមពលរបស់យើងកំពុងបង្កើតឡើងនូវការងារយ៉ាងច្រើនហើយកំពុងនាំទៅរកការធ្វើឱ្យផែនដីមួយស្អាត និងមានសុវត្ថិភាព ។

លោកប្រធានាធិបតីបាននិយាយថា "រយៈពេល ៨ ឆ្នាំកន្លងមកនេះ សហរដ្ឋអាមេរិកបានកាត់បន្ថយបានយ៉ាងច្រើន ភាពកខ្វក់នៃកាបូន Cabon គឺបានច្រើនជាងប្រទេសនានានៅលើផែនដី" ។ មែនហើយគឺជាការពិតដែលថា នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះបានកាត់បន្ថយបានយ៉ាងច្រើនភាពកខ្វក់កាបូន ហើយយើងសូមអរគុណចំពោះកិច្ចប្រឹងប្រែងនេះ។ ការបញ្ចេញសាយភាយកាបូនទៅក្នុងសហរដ្ឋអាមេរិកមានការថយចុះ (ទោះបីជាមានកំណើន ២% ក្នុងឆ្នាំ ២០១៣ ក៏ដោយ) ។ប៉ុន្តែ ប្រធានាធិបតីអាមេរិកនៅតែអាចប្រកាសថា យើងមិនបានតម្រង់ឆ្ពោះទៅកាន់"ផែនដីស្អាត និងមានសុវត្ថិភាព" នោះទេ ផ្ទុយទៅវិញ យើងកំពុងបាញ់ឆ្ពោះទៅកាន់ភាពកខ្វក់ដែលធ្វើឱ្យពិភពលោកមានគ្រោះថ្នាក់កាន់តែច្រើនឡើងៗ ។

វឌ្ឍនកម្មថ្មីៗជាបន្តបន្ទាប់បានបង្ហាញឡើងថា យើងកំពុងតែបាត់បង់មូលដ្ឋាននៅក្នុងការតស៊ូដើម្បីពន្យឺតការឡើងកម្ដៅរបស់ផែនដី ។ បញ្ហានេះមិនមែនដោយសារកង្វះនៃកិច្ចប្រឹងប្រែងនោះទេ ។ នៅជុំវិញពិភពលោក អង្គការនានា សហគមន៍នានា និងមនុស្សម្នាក់ៗកំពុងធ្វើការពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់ និងបង្កើននូវការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ មានការកើនឡើងយ៉ាងខ្លាំងអំពីការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ (ដើម្បីដាក់បំផ្ទុះរ៉ែថ្ម) ការខួងដីយកប្រេងដែលនាំទៅដល់ការកើនឡើងយ៉ាងច្រើននូវផលិតកម្មឥន្ធនៈហ្វូស៊ីល ជាពិសេសនៅទ្វីបអាមេរិកខាងជើង។ បញ្ហានេះហើយដែលបានបន្សល់ទុកនូវភាពកខ្វក់ក្នុងបរិយាកាសក្នុងពេលផលិតកម្មឧស្ម័ន និងប្រេងនៅក្នុងពិភពលោកឡើងដល់កំពូល ។

នៅពេលដែលឧស្ម័ននិងប្រេងមានភាពកាន់តែសម្បូរឡើងៗ ហើយអាចលៃលកទាញយកបាននោះ ក្រុមហ៊ុនថាមពលធំៗមានផែនការពឹងផ្អែកលើប្រេងច្រើនជាងប្រភពថាមពលកកើតឡើងវិញ ដើម្បីបំពេញតម្រូវការខ្លួននាពេលអនាគត ។ យោងតាមការប៉ាន់ស្មានថ្មីៗចេញពីក្រសួងថាមពលអាមេរិកបានឱ្យដឹងថា ការប្រើប្រាស់ឥន្ធនៈហ្វូស៊ីលត្រូវបានគេរំពឹងថានឹងមានការកើនឡើងដ៏គួរឱ្យភ្ញាក់ផ្អើលប្រមាណ ៤០% នៅឆ្នាំ ២០៣៥ ។

ថាមពលពិភពលោកដែលបានមកពីឥន្ធនៈហ្វូស៊ីលនឹងថយចុះសន្សឹមៗពី ៨៤% មកកាន់ ៧៩% ប៉ុន្តែហ្វូស៊ីលនៅគ្របដណ្ដប់នៅលើទីផ្សារថាមពលពិភពលោកសម្រាប់រយៈពេលប៉ុន្មានទសវត្សខាងមុខ ។ យោងតាមគម្រោងការទាំងនេះ ថាមពលកកើតឡើងវិញនឹងបន្តការពារបានមួយផ្នែកនៃការប្រែប្រួលអាកាសធាតុ ។ប្រសិនបើការលើកឡើងខាងលើបង្ហាញថាពិតជាត្រឹមត្រូវមែននោះ វាអាចជាលទ្ធផលមួយគួរឱ្យជឿទុកចិត្តបានគឺការសាយភាយកាបូនកាន់តែកើនឡើងនាំទៅដល់ការកើនឡើងកម្ដៅនៅលើផែនដី និងធ្វើឱ្យអន្តរាយដល់បរិយាកាសផែនដីដែលសព្វថ្ងៃស្ទើរ តែមិនអាចប៉ាន់ប្រមាណបាននោះ ។

នៅក្នុងពិភពលោករបស់យើងការប្រើប្រាស់ថាមពលកាបូនមានរៀងរាល់នាទី រៀងរាល់ថ្ងៃដែលអាស្រ័យលើការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ ក្រុមហ៊ុននីមួយៗ ស្ថាប័ននីមួយៗ និងរដ្ឋាភិបាលនីមួយៗ ។ ការស្រូបទាញនេះនឹងនាំទៅដល់ភាពជោគជ័យនៅក្នុងការតស៊ូរបស់ពិភពលោកដើម្បីពន្យឺតការប្រែប្រួលអាកាសធាតុ ហើយដែលបានឆ្លុះបញ្ចាំងនៅក្នុងវឌ្ឍនកម្មបីថ្មីៗនេះ ដែលប្រកាសដោយ BP (British Petroleum) ។



*កំណើននៃភាពត្រជាក់កាន់តែខ្លាំងឡើងៗបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ*

## BP ប្រកាសអំពីភាពជោគជ័យនៃថាមពលកកើតឡើងវិញ

ជារៀងរាល់ឆ្នាំក្រុមហ៊ុនថាមពលខ្នាតយក្សរបស់អង់គ្លេស BP តែងតែចេញនូវ "ទស្សនវិស័យស្ដីពីថាមពល" សម្រាប់បណ្ដាឆ្នាំខាងមុខ និងបានវិភាគអំពីនិន្នាការអនាគតនៃការផលិត ការប្រើប្រាស់ថាមពលនៅក្នុងពិភពលោក ។



*ផ្សែងខ្មួលខ្មាញ់ចេញពីបំពង់ផ្សែងរបស់រោងចក្រឧស្សាហកម្មនានា ធ្វើឱ្យមានការប្រែប្រួលអាកាសធាតុនៅលើភពផែនដី*

របាយការណ៍ឆ្នាំ២០១៤ ក្រុមហ៊ុនBP បានព្យាករណ៍អំពីថាមពលរហូតដល់ឆ្នាំ២០៣៥និងបានចេញផ្សាយជាសាធារណៈកាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤។ នៅក្នុងសន្និសីទកាសែតមន្ត្រីរបស់ក្រុមហ៊ុន BP លោក Bob Dudley បាននិយាយថា ក្រុមហ៊ុនមានសុទិដ្ឋិនិយមអំពីទីផ្សារអនាគតសម្រាប់ការផលិតថាមពលរបស់ក្រុមហ៊ុន ការធានាចំពោះអតិថិជន ចំពោះការផ្គត់ផ្គង់ឥន្ធនៈហ្វូស៊ីលក្នុងពិភពលោក នៅតែមានចំនួនច្រើនសម្រាប់ប៉ុន្មានឆ្នាំខាងមុខ។

មន្ត្រីរបស់ក្រុមហ៊ុន BP បានសួរទៅអ្នកកាសែតវិញថា តើយើងពេញចិត្តឬទេចំពោះតម្រូវការថាមពលនៅក្នុងពិភពលោក (ថាមពលឥន្ធនៈ) ចេះតែកើនឡើងនោះ ? លោកបានទទួលស្គាល់ថាមិនពេញចិត្តទេ ពីព្រោះការកើនឡើងនៃការប្រើប្រាស់ឥន្ធនៈ គឺជាការកើនឡើងនៃការសាយភាយកាបូនដែលនឹងកើនឡើង ២៩% នៅឆ្នាំ ២០៣៥ ជា តួលេខដែលយើងបានប៉ាន់ស្មាននៅក្នុង"ទស្សនវិស័យស្តី អំពីថាមពល"។

## ការកាត់បន្ថយរបស់សហភាពអឺរ៉ុប

រដ្ឋជាសមាជិកសហភាពអឺរ៉ុបជាយូរមកហើយ បានបំពេញតួនាទីជាមេដឹកនាំនៅក្នុងការតស៊ូដើម្បីកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់ និងការពិនិត្យល្បឿននៃការផ្លាស់ប្តូរអាកាសធាតុ ។ នៅក្រោមផែនការ ២០-២០-២០ របស់ខ្លួនដែលអនុម័តយល់ព្រមកាលពីខែធ្នូ ឆ្នាំ ២០០៨ ប្រទេសជាសមាជិក EU បានសន្យាកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់ឱ្យបាន ២០%នៅឆ្នាំ ២០២០ បង្កើនសមត្ថភាពថាមពល ២០% និងសម្រេចឱ្យបាន ២០% នៃក្តីសង្ឃឹមលើការប្រើប្រាស់ថាមពលកកើតឡើងវិញសម្រាប់តម្រូវការថាមពលសរុប ។ មិនទាន់មានតំបន់ណាផ្សេងហ៊ានធ្វើការប្តេជ្ញាចិត្តបែបសមាជិក EU នៅឡើយទេ ជាពិសេសអាមេរិក និងចិនជាប្រទេសដែលប្រើថាមពលច្រើនជាងគេ។

ឥឡូវនេះសហភាពអឺរ៉ុបកំពុងរៀបចំខ្លួនទប់និងពន្យឺតល្បឿននៃការកើនឡើងកម្តៅលើផែនដី។ នេះមិនមែនជាការអនុវត្តផែនការ ២០-២០-២០ ដែលត្រូវធ្វើឱ្យបាន សម្រេច នោះទេប៉ុន្តែជាគោលដៅដែលត្រូវអនុវត្ត ។សកម្មជនបរិយាកាស និងសហគ្រិនឧស្ម័នបៃតង កំពុងអំពាវនាវឱ្យបង្កើតមហិច្ឆតាសម្រេចគោលដៅឆ្នាំ ២០៣០ និងឆ្នាំខាងមុខទៀត។ មានក្រុមហ៊ុនផលិត និងក្រុមហ៊ុនថាមពលជាច្រើនកំពុងជំរុញឱ្យពន្យឺតការកើនឡើងកម្តៅលើផែនដី ដោយបានប្រកាសថាក្តីសង្ឃឹមកាន់តែច្រើនឡើងទៅលើថាមពលកកើតឡើងវិញកំពុងតែរុញច្រានឱ្យតម្លៃថាមពលកើនឡើងហើយ និងធ្វើឱ្យថយចុះនូវការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច ។ វាបានបង្ហាញឱ្យឃើញថា ម្ចាស់ឧស្សាហកម្ម នឹងបានចំណេញជាមូលដ្ឋានចំពោះការចំណាយសម្រាប់សកម្មភាពបរិយាកាស ។

## ការប្រឆាំងចំពោះការស្ថាបនាបំពង់របស់ក្រុមហ៊ុន Keystone XL

គ្រប់គ្នាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ចំពោះសកម្មជនបរិយាកាសនៅសហរដ្ឋអាមេរិក ដែលដឹកនាំដោយអ្នកនិពន្ធនិងជាសកម្មជនបរិស្ថានលោកBill McKibben និងក្រុមសកម្មជនដែលបានជួយបង្កើតអង្គការចំនួន ៣៥០ អង្គការ បានទទួលជោគជ័យ នៅក្នុងការពន្យារពេលនៃការអនុម័តយល់ព្រមរបស់រដ្ឋាភិបាលចំពោះបំពង់ Key-stoneXL ជាង ២ ឆ្នាំកន្លងមក។ បំពង់នោះបើស្ថាបនាចប់នឹងអាចបង្ហូរប្រេងបាន ៨៣០.០០០ បារ៉ែលក្នុងមួយថ្ងៃចេញពី Athabasca ដែលមានចម្ងាយ ១៧០០ ម៉ៃល៍ នៅឯសមុទ្ររបស់សហរដ្ឋអាមេរិកជាមួយកាណាដា។

## ការកាត់បន្ថយការសាយភាយកាបូន

ឧបសគ្គទាំងបីនៅក្នុងការតស៊ូជាប្រវត្តិសាស្ត្រនាពេលថ្មីៗនេះ ដើម្បីទប់ស្កាត់ឥទ្ធិពលដ៏អាក្រក់បំផុតនៃការផ្លាស់ប្តូរអាកាសធាតុបានប្រាប់យើងឱ្យដឹងអំពីដំណោះស្រាយដ៏អស្ចារ្យនៅក្នុងធម្មជាតិ និងលក្ខណៈភូមិសាស្ត្រនៃសមរភូមិ។ ការផ្លាស់ប្តូរអាកាសធាតុមិនបានបង្កើតឱ្យមានបាតុភូតឧត្តុនិយមនោះទេ វាគឺជាលទ្ធផលដែលកើតចេញពីបរិមាណឥន្ធនៈកាបូនយ៉ាងច្រើនដែលបានព្រួសចេញនូវសំណល់ឧស្ម័នចូលទៅក្នុងលំហអាកាស។ ដរាបណារដ្ឋាភិបាលនានា ក្រុមហ៊ុន សាជីវកម្មនានា និងអ្នកប្រើប្រាស់អាកាសធាតុនឹងត្រូវបរាជ័យនោះជាលទ្ធផលចុងក្រោយនឹងប្រែក្លាយទៅជាជាតិកំបោរដែលមាននៅពាសពេញលំហអាកាស។

មធ្យោបាយតែមួយគត់ដែលអាចទប់ស្កាត់បានឥទ្ធិពលនៃការប្រែក្លាយអាកាសធាតុ គឺមិនត្រូវប្រើប្រាស់កាបូនជាប្រភពថាមពល ។ បញ្ហានេះអាចសម្រេចទៅបានតាមរយៈការចាត់ទុកអ្នកផលិតឥន្ធនៈកាបូនថាជាសត្រូវចំពោះសុខភាពមនុស្សដែលត្រូវការកាត់បន្ថយជាបណ្តើរៗកុំឱ្យមានការផលិត និងការប្រើប្រាស់ថាមពលកាបូននៅលើផែនដីយើងនេះ។/

# ក្រូចថ្លុងអាចជួយព្យាបាលជំងឺទឹកនោមផ្អែម



*ផ្លែក្រូចថ្លុងអាចជួយលើកកម្ពស់សុខភាពមនុស្ស*

ផ្លែក្រូចថ្លុងមានរាងមូលមានទំហំធំជាងផ្លែក្រូចពោធិសាត់មានសំបកក្រាស់ ហើយ មានពណ៌ប្រែប្រួលទៅតាមតំបន់ដាំដុះខុសៗគ្នា។ គេសង្កេតឃើញដើមក្រូចថ្លុងមានដាំច្រើននៅតំបន់ជ្រោយឥណ្ឌូចិនយើងនេះ។ បច្ចុប្បន្នផ្លែក្រូចផ្លុងកំពុងពេញនិយមនៅទីផ្សារក្នុងរាជធានីភ្នំពេញ ដោយគេលក់ជាផ្លែ និងខ្លះទៀតគៀបយកទឹកដាក់ក្នុងដបលក់សម្រាប់ធ្វើជាភេសជ្ជៈ។

នៅក្នុងផ្លែក្រូចថ្លុងគេពិនិត្យឃើញសមាសធាតុគីមីជាច្រើនដូចជា ជាតិប្រេង ជាតិប៉េចទីន PECTINE ជាតិគ្លុយកូស៊ីត GLUCOSIDE ឈ្មោះណារាំងស៊ីន NARINGINE ។ ការសិក្សាបានរកឃើញថា ការទទួលទានក្រូចថ្លុងអាចជាជំនួយដល់ការព្យាបាលជំងឺទឹកនោមផ្អែមបាន។

ក្រុមអ្នកវិទ្យាសាស្ត្របានរកឃើញថា សារជាតិ NARINGINE ជាសារធាតុអាំងទីអុកស៊ីដង់ ដែលធ្វើឱ្យផ្លែក្រូចថ្លុងមានរសជាតិជូរនោះអាចបំពេញមុខ ងារដូចគ្នា និងថ្នាំ-ព្យាបាលដែលបច្ចុប្បន្ន ក្រុមគ្រូពេទ្យគេបានប្រើដើម្បីព្យាបាលជំងឺទឹកនោមផ្អែមប្រភេទពីរ នោះ។

ជំងឺទឹកនោមផ្អែមកើតឡើងនៅពេលដែលរាងកាយមិនអាចផលិតអាំង-ស៊ុយលីនអរម៉ូនឱ្យបានគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងកម្រិតជាតិស្ករឱ្យបានត្រឹមត្រូវ ។សារជាតិNARING-INE ជួយបង្កើនប្រតិកម្មរបស់រាងកាយទៅនឹងអាំងស៊ុយលីន ហើយវាក៏ជួយឱ្យអ្នកជំងឺរក្សាបានទម្ងន់ប្រកបដោយសុខភាព ដែលជាផ្នែកដ៏សំខាន់នៃការព្យាបាលជំងឺទឹកនោមផ្អែម។ បន្ទាប់ពីការទទួលទានអាហារមានជាតិស្ករច្រើន ដោយធ្វើឱ្យថ្លើម បង្កើតនូវអាស៊ីដខ្លាញ់ ឬលីពីតសម្រាប់រក្សាទុករយៈពេលយូរ។ ការឡើងទម្ងន់ធ្វើឱ្យអ្នកជំងឺទឹកនោមផ្អែម ប្រឈមសុខភាព និងកាត់បន្ថយប្រសិទ្ធភាពរបស់អាំងស៊ុយលីន។ ក្រុមអ្នកវិទ្យាសាស្ត្របានរកឃើញទៀតថា សារធាតុ NARINGINE ធ្វើឱ្យថ្លើមបំផ្លាញជាតិខ្លាញ់ជំនួសការរក្សាទុក។

ក្រុមស្រាវជ្រាវឱ្យដឹងទៀតថា សារធាតុ NARINGINE នៅមានប្រសិទ្ធភាពដូចថ្នាំកាត់បន្ថយជាតិលីពីតឈ្មោះ FENOFIBRATE និងឈ្មោះ ROSIGLITAZONE ដែលត្រូវបានប្រើដើម្បីជួយទប់ស្កាត់ជំងឺទឹកនោមផ្អែមប្រភេទពីរ។ ម្យ៉ាងទៀតតាមការផ្សាយរបស់មជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្រ និងឱសថបូរាណរបស់ក្រសួងសុខាភិបាលបានឱ្យដឹងថា គេអាចយកស្លឹកក្រូចថ្លុងស្រស់ដាំជាមួយស្លឹករុក្ខជាតិដទៃទៀតដែលមានជាតិក្រអូបសម្រាប់ឆ្អុងក្នុងការព្យាបាលជំងឺផ្តា-សាយ ឈឺក្បាល។ គេអាចម្រាញ់យកជាតិប្រេងពីសម្បកផ្លែក្រូចសម្រាប់ព្យាបាលជំងឺមិនរំលាយអាហារ ឈឺពោះ ក្អួត ហើយគេក៏អាចចម្រាញ់នូវជាតិអាស៊ីតស៊ីទ្រិកធម្មតាពីផ្លែក្រូចថ្លុងសម្រាប់ធ្វើជាថ្នាំព្យាបាលជំងឺនោមក្តៅ ជំងឺខ្វះជីវជាតិសេផងដែរ។/




*ទឹកក្រូចថ្លុងដែលច្របាច់ដោយប្រដាប់កៀប ត្រូវបានដាក់លក់ជាច្រើនកន្លែង*



# ឃុំអូរស្វាយ ៖ ទឹកដីអតីតសមរភូមិចុងក្រោយនាពេលបច្ចុប្បន្ន

*ជាឃុំមួយស្ថិតនៅពាយ័ព្យទីរួមស្រុកត្រពាំងប្រាសាទជាង ៦ គ.ម ឬ នៅទិសខាងកើតនៃទីរួមខេត្តឧត្ដរមានជ័យ ១៣០ គ.ម នៅបណ្ដោយផ្លូវកៅស៊ូវិស្វកម្ម ឬផ្លូវជាតិលេខ ៦៧B នោះ ឃុំនេះបច្ចុប្បន្នបាន និងកំពុងប្រែមុខមាត់ថ្មីទាំងហេដ្ឋារចនាសម្ព័ន្ធនានា ក៏ដូចជាជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ អ្នកដែលធ្លាប់បានទៅឃើញឃុំនេះនាគ្រាដំបូងនៅអំឡុងឆ្នាំ ១៩៩៨ គឺមុនពេលធ្វើសមាហរណកម្ម ហើយបានឃើញឃុំនេះជាថ្មីនាពេលឥឡូវ គឺពិតជាពុំអាចទប់ចិត្តមិនសម្ដែងនូវការកោតសរសើរបានឡើយ ។ អូរស្វាយពេលនេះមិនដូច អូរស្វាយក្នុងសម័យសង្គ្រាមនោះឡើយ ។*



*លោក កេត សឿង*



*អគារសិក្សានៃអនុវិទ្យាល័យអូរស្វាយ*



*ផ្លូវជាតិលេខ ៦៧B ឆ្លងកាត់ឃុំអូរស្វាយ*

## ទឹកដីចេញពីសង្គ្រាមក្រោយគេ

ដូចភូមិឃុំនានាក្នុងស្រុកត្រពាំងប្រាសាទ និងស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យដែរ ឃុំអូរស្វាយជាអតីតតំបន់ដែលគ្រប់គ្រងដោយពួកឧទ្ទាមខ្មែរក្រហមដែលគេស្គាល់ភាគច្រើនថា "តាម៉ុក" ។ ប៉ុន្ដែដោយកៀកនឹងភ្នំដងរែក និងជាប់ជាមួយប្រទេសថៃផងទីនោះ គឺជាជម្រកចុងក្រោយនៃអង្គការចាត់តាំងទាំងនយោបាយ និងយោធារបស់ពួកខ្មែរក្រហម ។ មេដឹកនាំខ្មែរក្រហមសំខាន់ៗបានរស់នៅទីនោះ ដូចជា ប៉ុល ពត នួន ជា សុន សេន ខៀវ សំផន ។ល។ ដោយនយោបាយឈ្នះ ឈ្នះ របស់សម្ដេចតេជោ **ហ៊ុន សែន** និងរបស់គណបក្សប្រជាជនកម្ពុជា បានធ្វើឱ្យបងប្អូនខ្មែរក្រហមសមាហរណកម្មជាមួយរាជរដ្ឋាភិបាលចុងក្រោយគេក្នុងឆ្នាំ ១៩៩៩ គឺក្រោយចលនាផ្ដាច់ខ្លួនមានតាំងពីពាក់កណ្ដាលឆ្នាំ ១៩៩៦ និងក្រោយប៉ុលពតស្លាប់ និងក្រោយចាប់ខ្លួនតាម៉ុក ។

អូរស្វាយជាទឹកដីជាប់តំបន់ព្រៃភ្នំខ្ពង់រាប តែក៏មានដីស្រែច្រើនដែរ ។ ឃុំមានផ្ទៃដីធំបង្អស់ទី ២ បើប្រៀបធៀបនឹងឃុំទាំង ៦ ក្នុងស្រុកនេះ គឺផ្ទៃដីរួម ទំហំ ២៣ ២២១ ហ.ត ក្នុងនោះផ្ទៃដីបង្កបង្កើនផល ១៤ ៦៤០ ហ.ត (អាចធ្វើស្រែបាន ២ ៧៤៤ហ.ត) និងដីបឹងបួ ២១៥ ហ.ត ។ ឃុំមាន ៩ ភូមិ គឺភូមិតាសំ ភូមិសែនសំ ភូមិអូរល្ហុងភូមិឈើទាលជ្រុំភូមិពាមក្នុងភូមមិពពេលសែនជ័យ ភូមិអូរស្វាយ ភូមិទំនប់អភិវឌ្ឍន៍ និងភូមិទួលក្រួស ។ ព្រំប្រទល់ឃុំនេះ គឺខាងកើតទល់នឹងឃុំទំនប់ដាច់ និងឃុំបាក់អន្លង់ ខាងលិចទល់នឹងឃុំផ្អាវ និងឃុំត្រពាំងប្រាសាទ និងខាងជើងទល់នឹងជួរភ្នំដងរែកនៃព្រំដែនកម្ពុជា-ថៃ ។

## ប្រជាជនក្នុងសម័យសន្តិភាព និងអភិវឌ្ឍន៍

នៅទីនោះ ប្រជាជនភាគច្រើនជាបងប្អូនអតីតខ្មែរក្រហមធ្វើសមាហរណកម្ម និងមួយភាគតូចជាអ្នកចំណូលថ្មី ក្រោយបញ្ចប់សង្គ្រាម និងពេលសន្តិភាព អភិវឌ្ឍន៍ ។ ប្រជាជននៅមូលដ្ឋានចាស់ភាគច្រើនប្រកបរបរកសិកម្ម ខណៈដែលអ្នកចំណូលថ្មីភាគច្រើនគឺប្រកបរបរលក់ដូរនៅទីផ្សារ ។

លោក *កេត សឿង* ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាឃុំ និងជាមេឃុំអូរស្វាយមានប្រសាសន៍ថា សម័យសង្គ្រាមឃុំរបស់លោកប្រជាជនមានតិចតួចទេ ។ មានទីលំនៅមិនចល័តត្រឹមរាប់សិបគ្រួសារ និងផ្ទះឈើប្រក់ស្បូវខ្ទមត្រឹមរាប់សិបខ្នង និងផ្ទះឈើប្រក់ហ្វីប្រូស៊ីម៉ង់ត៍ ៤-៥ ផ្ទះប៉ុណ្ណោះ ។

លោកបានបន្តដោយរំឭកថា ឥឡូវនេះឃុំអូរស្វាយមានប្រជាជនរស់នៅចំនួន ១ ៧៦២ គ្រួសារ ស្មើនឹងមនុស្សរាយចំនួន ៨ ០៩៧ នាក់ (ស្រី ៣ ៨៣៣ នាក់) ក្នុងនោះ អាយុពី ១៨ ឆ្នាំឡើងមាន ៤ ៥៩១ នាក់ (ស្រី ២ ១៦៣ នាក់) ។ ក្នុងចំនួនប្រជាជនជាងមួយពាន់គ្រួសារនេះដែរ គឺចំនួនប្រមាណ ៣៤% ជាអ្នកចំណូលថ្មី ។ ដោយ



ច្បារដំណាំដែលគ្មានប្រើជីគីមីរបស់ប្រជាកសិករឃុំអូរស្វាយ

ប្រែក្លាយពីផ្ទះខ្ទមរខេករខាកនាសម័យសង្គ្រាម បច្ចុប្បន្នឃុំ មានផ្ទះឈើ លើឥដ្ឋ ក្រោមប្រក់ក្បឿង១២១៧ខ្នង ផ្ទះប្រក់ហ្វីប្រូស៊ីម៉ង់ត៍២៤៨ ខ្នង ផ្ទះប្រក់សង្កសី ១២៣ ខ្នង និងផ្ទះឈើប្រក់ស្បូវ និងស្លឹក ១៤៥ ខ្នង។ ពលរដ្ឋ និងមន្ត្រីមានរថយន្ត១៨គ្រឿង គោយន្ត ១១៤ គ្រឿង ម៉ាស៊ីនបោកស្រូវ សណ្ដែក ៨៧ គ្រឿង ម៉ូតូ ៩៤៨ គ្រឿង ។ ម៉ាស៊ីនកិនស្រូវ ៦៧កន្លែង ម៉ាស៊ីនសាកអាគុយ ៨ កន្លែង ត្រាក់ទ័រ ៥ គ្រឿង ម៉ាស៊ីនបូមទឹក ៣២ គ្រឿង ទូរទស្សន៍ ៨៧៨ គ្រឿង។

លោកមេឃុំបាននិយាយបន្តថា ជាបន្តបន្ទាប់រាជរដ្ឋាភិបាលជួយស្តារ និងអភិវឌ្ឍអតីតតំបន់ខ្មែរក្រហមទាំងអស់ ដែលក្នុងនោះមានទាំងឃុំអូរស្វាយផងដែរ ។សមិទ្ធផលដែលលេចចេញជារូបរាងឡើង គឺមានរង្វង់មូលមួយកន្លែងនៅភូមិអូរស្វាយ ផ្លូវជាតិលេខ ៦៧ B ដែលកសាងដោយកងវិស្វកម្មកាត់ឃុំ ៩ ៥០០ ម៉ែត្រ ផ្លូវដីក្រួសក្រហម ៦ ខ្សែប្រវែង ៥០ គ.ម ផ្លូវដីស ៥ ខ្សែ ប្រវែង ១៩ គ.ម។ ឃុំទទួលបានស្រះទឹក ៨ កន្លែងមានសាលារៀនពីមត្តេយ្យដល់អនុវិទ្យាល័យ ៥ ខ្នង (១ ខ្នងស្មើនឹង ៥ បន្ទប់) ក្នុងនោះមានអនុវិទ្យាល័យមួយកន្លែង ក្នុងនោះ ៣ ខ្នងជាអំណោយដ៏ថ្លៃថ្លារបស់សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាជំនួយអង្គការ ZOA មួយខ្នង និងមួយខ្នងទៀតជាជំនួយគ្រួសារយ៉េត (សប្បុរសជនន័រវេស)។ មានសិស្សសរុប ៦៣៤ នាក់ (ស្រី ៣០១ នាក់)។ឃុំមានវត្តពីរកន្លែង គឺនៅភូមិអូរស្វាយ និងភូមិអូរល្អមានកុដិ ២ ខ្នង មានព្រះសង្ឃ ១៩ អង្គគង់នៅមានសាលាឆាន់២ខ្នងសាលាឆទាន ២។ មានទំនប់ទឹក ៥ កន្លែង : ទី ១ ទំនប់អភិវឌ្ឍន៍ នៅភូមិទំនប់អភិវឌ្ឍន៍ធំជាងគេ គឺទំហំ ២ ០០០ ម៉ែត្រ គុណនឹង ១ ០៥០ ម៉ែត្រ ដែលធានាស្រោចស្រពស្រូវ៤៨ហ.តដំណាំរួមផ្សំនិងបន្លែ ១២ ហ.ត។ ទី ២ ទំនប់អូរស្វាយ១ និងទំនប់អូរស្វាយ ២ ។ ទី៣ ទំនប់សែនសំ ។ ទី៤ ទំនប់តាសំ និងទី ៥ ទំនប់ពាមក្នុង។ ទំនប់ទាំងអស់កសាងដោយអង្គការជនភៀសខ្លួនហូឡង់ (ZOA)។

## មិនភ្លេចគុណរដ្ឋជួយ

លោក *កេត សឿង* ប្រធានក្រុមប្រឹក្សាឃុំអូរស្វាយបានបញ្ជាក់ប្រាប់យើងថា "អាចមានភ័ព្វវាសនា និងរីកចម្រើនដូចសព្វថ្ងៃនេះ ដំបូងបំផុតគឺនយោបាយឈ្នះឈ្នះរបស់សម្តេចតេជោ **ហ៊ុន សែន** ដែលបានបញ្ចប់សង្គ្រាម ហើយថែរក្សាសន្តិភាព ស្ថិរភាព រក្សាបានជីវិតដី ទ្រព្យសម្បត្តិ និងមុខនាទី ។ បងប្អូនទទួលបានពីរាជរដ្ឋាភិបាលនូវការស្តារ និងអភិវឌ្ឍន៍លើគ្រប់វិស័យ"។

លោកបានរំឭកថារដ្ឋាភិបាលបានសម្បទានដីសង្គមកិច្ចដំបូងគឺ ប្រជាជនមួយគ្រួសារៗ ទទួលបានដីលំនៅស្ថានទំហំ ៣០ ម៉ែត្រ គុណនឹង ១០០ ម៉ែត្រ ដីបង្កបង្កើនផលតាមសមាជិកគ្រួសារ គឺ ខ្លះ ២ ហ.ត ៤ ហ.ត ដល់ ៥ ហ.ត។

លោកបន្តថា "ថ្នាក់លើ និងមូលដ្ឋានបានដឹកនាំ និងអនុវត្តដោយជំរុញលើកកម្ពស់ជីវភាពប្រជាជនដោយធ្វើស្រែចម្ការ ចិញ្ចឹមសត្វ។ គឺធ្វើម៉េចឱ្យប្រជាជនបានហូបគ្រប់គ្រាន់ បន្ទាប់មកទើបគិតពីគម្រោងលំនៅស្ថាន ផ្លូវ អណ្ដូង ស្រះទឹក សាលារៀន និងមណ្ឌលសុខភាព"។

ផ្អែកលើសម្រង់វាយតម្លៃអត្រាភាពក្រីក្រក្រោយសមាហរណកម្មជាង២ ឆ្នាំ ឃើញពលរដ្ឋរស់នៅក្រោមបន្ទាត់ក្រីក្រជាង ៧០% ឥឡូវនៅសល់ត្រឹម ១៥%។

លោកបានបន្ថែមថា ផ្នែកជំនាញនានា និងអាជ្ញាធរព្រមទាំងដៃគូអភិវឌ្ឍន៍បានជួយរៀបចំសហគមន៍អភិវឌ្ឍន៍។ ក្នុងនោះពលរដ្ឋក្រីក្រនឹងត្រូវផ្តល់ផ្ទះមួយខ្នងប្រក់សង្កសីទំហំ៥ម៉ែត្រគុណនឹង ៦ ម៉ែត្រ។

ក្រោយសមាហរណកម្មមានអង្គការ សមាគមអភិវឌ្ឍន៍មួយចំនួនបានចូលទៅជួយឃុំអូរស្វាយ ដូចជា អង្គការស្បៀងអាហារពិភពលោក (WFP) ជួយជាស្បៀងពលកម្ម ។ អង្គការកាកបាទក្រហមបារាំងជួយជាពូជដំណាំបន្លែ និងសត្វចិញ្ចឹម។ អង្គការយូនីសេហ្វ (UNICEF) ឧបត្ថម្ភជាស្បៀងសម្រាប់កុមារ ស្ត្រី អគ្រានុកូលដ្ឋាន និងអប់រំ។ អង្គការជនភៀសខ្លួនហូឡង់ (ZOA) ជួយច្រើនជាងគេ មានកសាងទំនប់ អគារសិក្សា ពូជដំណាំនិងសត្វចិញ្ចឹម ផ្លូវ ជួយគោយន្ត១០០គ្រឿង ម៉ាស៊ីនបូមទឹក៣២គ្រឿង ផ្តល់លុយឥណទានសហគមន៍គឺមួយភូមិ ផ្តល់ ២០ លានរៀល។ អង្គការ OKENDEN ជួយជាពូជគោ មាន់ ទា ជ្រូក។ កាកបាទក្រហមកម្ពុជា ជួយផ្តល់ជាពូជដំណាំនិងអណ្ដូងទឹក។ អង្គការច្រា(CHRA) ជួយជាស្រះ អណ្ដូង បង្គន់ អនាម័យ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមការងារថ្នាក់កណ្តាលគណបក្សប្រជាជនកម្ពុជា ចុះជួយឃុំអូរស្វាយ ដឹកនាំដោយលោកឧត្តមសេនីយ៍ **ខ្វាន់ ស៊ាម** បានជួយសាលារៀន ២



លោកស្រី កើត រ៉ង



*សាលាឃុំអូរស្វាយ*

ខ្នង ក្នុងនាមសម្តេចតេជោនាយករដ្ឋមន្ត្រី ផ្លូវ និងពង្រឹងការងារនៅមូលដ្ឋាន ។ ពិសេសគឺកងវិស្វកម្មស្ថាបនាផ្លូវជាតិលេខ៦៧B ឆ្លងកាត់ឃុំនេះ ។

អ្នកស្រី *រ៉ង* ជំទប់ទី ១ ឃុំអូរស្វាយ ប្រាប់បន្ថែមថា "ការប្រែប្រួលមុខមាត់ថ្មីស្ទើរពុំអាចជឿបាននាពេលនេះ គឺដោយសាររាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយគណបក្សប្រជាជនកម្ពុជា មានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ អង្គការដៃគូអភិវឌ្ឍន៍នានា និងសប្បុរសជនបូកផ្សំនឹងការខិតខំរបស់អាជ្ញាធរមូលដ្ឋាននិងប្រជាជនផ្ទាល់" ។ ពលរដ្ឋពុំដែលភ្លេចហើយរឹតតែចងចាំនូវគុណដ៏វិសេសថ្លៃថ្លាទាំងអស់នេះ ។ ពលរដ្ឋពិតជាមានសំណាងដែលបានសល់ជីវិត ហើយបានរីកចម្រើនដូចសព្វថ្ងៃនេះ ។

ប្រជាពលរដ្ឋឈ្មោះ *ខៀវ វឿន* ភេទស្រី អាយុ ៥០ ឆ្នាំ ជាអតីតប្រជាជនរស់នៅតំបន់ខ្មែរក្រហម នាភូមិតាសំ ឃុំអូរស្វាយ បាននិយាយដោយទៅរកអតីតកាលថា នៅឆ្នាំ ១៩៩៩ ពេលដែលធ្វើសមាហរណកម្មគ្រួសារគាត់មានផ្ទះតូចមួយ គោញីមួយនឹមនិងជីវភាពដ៏អត្តខាត់ ។ប៉ុន្តែដោយបានការខិតខំខ្លួនឯង និងជំនួយពីរាជរដ្ឋាភិបាលដឹកនាំដោយសម្តេចតេជោ **ហ៊ុន សែន** អង្គការដៃគូអភិវឌ្ឍន៍នានា និងអាជ្ញាធរមូលដ្ឋាននោះឥឡូវគ្រួសារគាត់ដែលមានសមាជិក៦ នាក់ មានផ្ទះឈើលើថ្មក្រោមមួយខ្នងទំហំ ៨ ម៉ែត្រ គុណនឹង ១០ ម៉ែត្រ ម៉ូតូ ២ គ្រឿង គោយន្ត ២ គ្រឿង ។ នេះពុំរាប់បញ្ចូលនូវកូន ២ នាក់ដែលបានបែកផ្ទះផងទេ ។

បងស្រីបន្តថា "អ្នកអូរស្វាយ និងក្រុមគ្រួសារខ្ញុំពុំដែលនឹកស្មានថាបានរស់ឡើងវិញ និងរស់ក្នុងសន្តិភាពមានការលូតលាស់បែបនេះ ទេកាលពីសម័យសង្គ្រាម ។ តែអ្វីៗ ដែលពីមុនគ្មាន ឥឡូវមានទាំងអស់ ។ ការជឿជាក់លើគណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាល ពិតជាផ្តល់នូវអ្វីៗដែលយើងត្រូវការផងនិងយើងចង់បានផង" ។

## ធ្វើល្អបានល្អ ធ្វើត្រូវបានផលច្រើន

លោក *កេត សឿង* ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាឃុំអូរស្វាយមានប្រសាសន៍ថា ក្នុងឃុំមានស្នាក់ការគណបក្សប្រជាជនកម្ពុជាមួយកន្លែង ហើយមានរក្សាដីទុកធ្វើស្នាក់ការតាមភូមិទៀតបើចាំបាច់ ។ មាន ៩ សាខាបក្ស ២០៩ ក្រុមបក្ស សមាជិក ២ ៦៦៩ នាក់ ។ លទ្ធផលបោះឆ្នោតក្រុមប្រឹក្សាឃុំឆ្នាំ ២០១២ គណបក្សប្រជាជនកម្ពុជា ទទួលសំឡេងគាំទ្រ ២ ២៧៧ សំឡេងបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ ទទួលសំឡេងគាំទ្រ ២ ២៨៥ សំឡេង ។ ពោលគឺអាសនៈទាំងអស់នៃក្រុមប្រឹក្សាឃុំ កាន់កាប់ដោយសមាជិកគណបក្សប្រជាជនកម្ពុជាតាំងពីអាណត្តិទី១ មកទល់បច្ចុប្បន្ន ។ពោលគឺគណបក្សប្រជាជនកម្ពុជាឈ្នះដាច់រហូត ។

លោកបានបន្ថែមថាពលរដ្ឋជឿជាក់លើគណបក្សប្រជាជនកម្ពុជា ដោយសារកម្មវិធីនយោបាយ និងគោលនយោបាយរបស់គណបក្ស និងថ្នាក់ដឹកនាំរហូតដល់សមាជិកគណបក្សត្រឹមត្រូវច្បាស់លាស់ និងជាទីសង្ឃឹមបានគ្រប់កាលៈទេសៈ ។ ប្រជាជនស្មោះត្រង់គាំទ្រគ្មានងាករេ ។ លទ្ធផលល្អលើគ្រប់វិស័យ និងត្រឹមត្រូវធ្វើឱ្យប្រជាជនគោរព ស្រឡាញ់ អាណិត ជឿទុកចិត្ត ហើយចូលរួមជាមួយ និងបោះឆ្នោតជូនគ្រប់ៗអាណត្តិនៃឃុំ និងនៃរដ្ឋសភា ។ មន្ត្រីគណបក្សប្រជាជនបានដោះស្រាយរាល់បញ្ហា ឬ ធុរៈរបស់ប្រជាជន មន្ត្រីរាជការ និងកងកម្លាំង ។ មន្ត្រីបក្សមានភាពស្និទ្ធស្នាលសាមញ្ញ ចុះជាប់ប្រចាំ និងចុះជួយជាប្រចាំ ដែលនាំឱ្យប្រជាជននៅមូលដ្ឋានមានភាពកក់ក្តៅ ។

លោកប្រធានគណបក្សបន្តថា ឃុំនេះទទួលបានការវាស់វែង និងធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីតាមបទបញ្ជា ០១ ប.ប បានជាង ១ ០០០ ហ.ត ។ ចំពោះទិសដៅបន្តឆ្នាំ ២០១៤-២០១៥ មន្ត្រីឃុំនឹងលើកផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម សង្គមកិច្ច សន្តិសុខ ដើម្បីកាត់បន្ថយភាពក្រីក្រ និងពង្រឹងភាពសុខុមរមនារបស់ប្រជាជន ស្របតាមកម្មវិធីនយោបាយគណបក្ស និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ទន្ទឹមនឹងនោះ លោកបានសំណូមពរសុំជួយបន្តនូវការដោះស្រាយគោលនយោបាយដីធ្លី ពិសេស ស្នើសុំវាស់វែង និងធ្វើប័ណ្ណកម្មសិទ្ធិដីកសិកម្ម ។ ស្នើជួសជុលផ្លូវខូចខាត និងស្ថាបនាបន្ថែមនូវផ្លូវក្រាលក្រួសក្រហម ។ ស្នើសង់អគារសិក្សាបន្ថែមនៅសាលាដែលខ្វះខាត ។ ស្នើសង់មណ្ឌលសុខភាពថ្មីមួយនៅក្បៀកព្រំដែនដែលមានកំណើនប្រជាជនថ្មី ។ សុំដៃគូអភិវឌ្ឍន៍ជួយបន្ត និងសុំកសាងអាង និងអណ្តូងទឹកបន្ថែម ។សុំភ្ជាប់បណ្តាញអគ្គិសនី និងសុំជួយអន្តរាគមន៍លើរក្សាស្ថិរភាពទីផ្សារកសិផលដែលជាប្រភពចំណូលធំរបស់កសិករនៃឃុំនេះក៏ដូចជាកសិករឃុំដទៃទៀត ។/



*លោកស្រី ខៀវ វឿន*

# ផលត្រីស្រុកយើង

- កត្តិកខ្យល់ធ្លាក់ពីឧត្តរ ផ្កាស្រូវពណិសរោយផ្ទៃទឹក
  ក្លិនក្រអូបសាយថ្ងៃយប់ព្រឹក ត្រីឆ្វាញ់ប្រចឹកឥតទំនេរ ។
- ស្រែថ្លុកត្រពាំងអូរបួបឹង ប្រឡាយព្រែកស្ទឹងអាងទន្លេ
  មានទឹកមានត្រីមិនខ្វះទេ តូចធំកូនមេរាប់រយមុខ ។
- ត្រូវការស្រស់ៗតាមចំណង់ ឬចង់ធ្វើម៉ាំផ្អកប្រហុក
  ប្រឡាក់វះងៀតឆ្អៀតឆ្អើរទុក បម្រុងទៅមុខយូរថ្ងៃខែ ។
- កំពតក្រពាត់ក្រពុលបាយ គ្រុំក្រុសសណ្ដាយក្រាយកាហែ
  រៀលលេញឆ្ពិនឆ្ពង់កៀតស្រង់កែ ស្លាតអណ្ដាតឆ្កែញោក់ស្លា ។
- កញ្ចូនជ័យផ្ទក់ត្រសក់ក្អែក អាចម៍កុកគល់ចេកកន្ទ្រប់ខ្លា
  ទ្រនេលសរសៃកែសស្បៃកា ក្រឡង់ប៉ាវ៉ាខ្លាឆ្កែលក្អី ។
- ក្រមមត្រឱនខ្ទាន់បង្កង ព្រោនបង្គាខ្យងស្លឹកឬស្សី
  ឆ្កោកឈ្វាតរាហូរាជដីរ កំផ្លៀវក្របីខ្សាន់អណ្ដែង ។
- កំពិស កំភ្លាញ កន្ធុយរា ចេកទុំគជ្រាក្បកច្រកែង
  បណ្ដូលអំពៅខ្ទួចខ្ទងវែង ដងដាវដងខ្មែងខ្មែងកាហោ ។
- ចង្វាននោងជន្លួញមាន់ ឆ្លាមខ្ទាន់នួនចាន់ក្អុកក្អិតក្អោរ
  ក្រិមក្រាញ់ប្រមាខ្យារ៉ស់ឆ្កោរ ចង្វាពោតពោលលកស ។
- ផ្សែាតសម្បោរហៀវស្រកាក្ដាម កន្ធរកំព្រាមកញ្ចុះថ្ម
  ប៉ាផាក់កាហាតស្លាតព្រាបស ព្រលូងព្រួលថ្មខ្ទឹងបេកា ។
- ត្រចៀកដំរីបង្គួយក្ដាម រៀលតុបអង្កាមចឹមព្រឹកប្រា
  ព្រួលកន្ត្រងប្រេងគ្រែងក្រឹមក្ដារ កញ្ជ្រូកផ្កាចារកំភ្លាញភ្លុក ។
- អណ្ដើកកន្ធាយកន្ធេះឡង់ កង្កែបអន្ទង់កន្ទាទូក
  ហ៊ីងខ្មៅខ្សែងលៀសគ្រុំកប់ភក់ ឆ្លូញឆ្លាំងផ្ទោងផ្ទក់ប៉ាស៊ីអ៊ី ។
- ស្រុកយើងសម្បូរសម្បត្តិត្រី ប្រជាប្រុសស្រីគ្រប់ទិសទី
  ពឹងអាស្រ័យផលជាអាលជ្ជី យើងត្រូវសាមគ្គីថែការពារ ។/

*ដោយ : ទឹម ណាំ*






## ត្រូវឆ្នោតរង្វាន់ធំ

ថ្ងៃមួយនាង ណែត បានចូលជួបលោកចៅក្រមស្នើសុំសំណូមពរ :

-សូមទោស នាងខ្ញុំមកម្ដងនេះ គឺសុំដកពាក្យបណ្ដឹងលែងលះវិញ។ សូមលោកចៅក្រមអនុគ្រោះផងចុះ ។

លោកចៅក្រមងក់ក្បាលញញឹម :

- ល្អណាស់ នេះជាប្រការដែលតុលាការចង់បានបំផុត ។ ពេលនេះប្រហែលជាអ្នកស្រីគិតឃើញយ៉ាងច្បាស់ថា គាត់ពិតជាប្ដីដ៏ល្អបំផុតហើយមែនទេ ?

- ចា៎ះ លោកចៅក្រមយល់ច្រឡំហើយ !

- អ្ហា៎ក បើអ៊ីចឹង តើមកពីហេតុផលយ៉ាងម៉េចវិញ ?

- ចា៎ះ តាមពិត គឺមកពីគាត់ ទើបតែត្រូវឆ្នោតរង្វាន់ធំតើ ! ។

## មួយចានម្នាក់

នៅតាមផ្លូវ យុវជនស្គមម្នាក់កំពុងដើរយ៉ាងល្វើយក៏ប្រទះលោកអ៊ំចំណាស់ដើរមកពីមុខ ទើបលើកដៃសំពះនិយាយ :

- សូមទោស លោកអ៊ំ ប្រហែលមានលុយកាក់ច្រើនគួរសមអាណិតមេត្តាដាក់ទានឱ្យខ្ញុំ ១.០០០ រៀលមក។ តាំងពីព្រឹករហូតថ្មើរនេះ ខ្ញុំមិនទាន់មានចំណីអ្វីបន្តិចដាក់ពោះសោះ ។

- អើ តាំងពីព្រឹកដល់ឥឡូវ អ៊ំក៏អត់ទាន់បានហូបអីដែរ!

- បើអ៊ីចឹងមែន សូមអ៊ំដាក់ទានឱ្យខ្ញុំ ២.០០០ រៀលមក ចាំខ្ញុំប៉ាវលោកអ៊ំហូបបបរមួយចានម្នាក់ជាមួយខ្ញុំ ។

## គ្រែនៅកន្លែងណា?

នាយ ជ្រក់ និងនាយ ជ្រឹង ស្រវឹងទន់ករៀងខ្លួននិយាយគ្នា

- រៀងរាល់លើកពេលត្រឡប់ពីផឹកទៅដល់ផ្ទះវិញ យប់ណាប្រពន្ធឡូឡាខ្លាំងពេក ខ្ញុំគេចទៅដេកនៅបន្ទប់ទទួលភ្ញៀវ ។

- អ្ហេស....ខ្ញុំខុសពីឯងស្រឡះ គឺថាយប់ណាប្រពន្ធរអ៊ូខ្លាំង ខ្ញុំឡើងដេកលើគ្រែ ។ ប៉ុន្តែបើយប់ណាប្រពន្ធអត់រអ៊ូសោះ យប់នោះខ្ញុំពិតជាដេកនៅដីហើយ ។

- អ្ហា៎ក ម៉េចអ៊ីចឹងទៅវិញ?

- ព្រោះបើគេរអ៊ូខ្លាំង ខ្ញុំស្ដាប់តាមសំឡេងគេ អាចរាវរកគ្រែឃើញ ។ដល់គេអត់មាត់កសោះធ្វើម៉េចដឹងថាគ្រែនៅកន្លែងណា ។

បោះពុម្ពដោយ រោងពុម្ព អរិយធម៌ ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៥៣

| | | | | | |
|---|---|---|---|---|---|
| ១- | ឯ.ឧ | **កែ** | **គឹមយ៉ាន** | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ២- | ឯ.ឧ | **ចម** | **ប្រសិទ្ធ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលោកជំទាវ | ២០០ ដុល្លារ |
| ៣- | ឯ.ឧ | **មិន** | **ឃិន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ខួន ឆួន** | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | **ត្រាំ** | **អ៊ីវតឹក** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | **ថោង** | **ខុន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | **លន់** | **លឹមថៃ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | **ជៀង** | **អំ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | **ស្បោង** | **សារ៉ាត** | ប្រធានគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | **ខុយ** | **សុខា** | អនុប្រធានគណៈកម្មាធិការគណបក្សខេត្តពោធិសាត់ | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | **អូស្មាន** | **ហាស្សាន់** | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | **សរ** | **ចំរុង** | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | **ផា** | **សុជាតិវង្ស** | ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | **ម៉ម** | **ប៊ុននាង** | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | **ប្រាក់** | **ចំរើន** | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | **គង់** | **វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | **អ៊ឹន** | **វីរជាតិ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | **យូ** | **តិរម្យ** | សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់ | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | | ១០០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | | ៥០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | | ៥០ ដុល្លារ |
| ២២- | ឯ.ឧ | **លឹម** | **គានហោ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ២០០.០០០ ៛ |
| ២៣- | ឯ.ឧ | **ឃឹម** | **សារិទ្ធ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៥០ដុល្លារ |
| ២៤- | ឯ.ឧ | **ម៉ម** | **ប៊ុនហេង** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៥- | ឯ.ឧ | **ថា** | **យ៉ាវ** | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ២៦- | ឯ.ឧ | **ជូ** | **យិនស៊ីម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៧- | ឯ.ឧ | **អ៊ឹក** | **ប្រាថ្នា** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ២០០.០០០ ៛ |
| ២៨- | ឯ.ឧ | **ប៉ាវ** | **ហមផាន** | អនុប្រធានគណៈកម្មាធិការគណបក្សខេត្តរតនគិរី | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | **សូ** | **ជុងហួរ** | ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | **ចាយ** | **បូរិន្ទ** | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ | **នរៈ** | **រតនៈវឌ្ឍនោ** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣២- | ឯ.ឧ | **ឃួន** | **វ៉ានីន** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣៣- | ឯ.ឧ | **ប៊ុន** | **លឹមហេង** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៣៤- | ឯ.ឧ | **សេង** | **ទៀង** | ជំនួយការផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ២០០.០០០៛ |
| ៣៥- | ឧកញ៉ា | **ម៉ក់** | **គឹមហុង** | ប្រធានអគ្គនាយកចំការកៅស៊ូជប់ | ២០០.០០០៛ |
| ៣៦- | ឯ.ឧ | **ម៉ៅ** | **ប៊ុនណារិន** | សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា | ១០០.០០០៛ |
| ៣៧- | ឯ.ឧ | **ម៉ែន** | **ស៊ុំផាន់** | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៣៨- | ឯ.ឧ | **សុន** | **គន្ធរ** | រដ្ឋមន្ត្រីប្រតិភូអមសម្តេចនាយករដ្ឋមន្ត្រី | ១០០.០០០៛ |
| ៣៩- | ឯ.ឧ | **ប៉ាន** | **ប៊ុនធឿន** | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៤០- | លោកជំទាវ | **ស៊ឹង** | **ស៊ុំយុត** | | ១០០.០០០៛ |
| ៤១- | ឯ.ឧ | **គឹម** | **ឆា** | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤២- | ឯ.ឧ | **គាំម** | **កុសល** | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៣- | ឯ.ឧ | **ប៊ិច** | **សុវណ្ណ** | | ១០០.០០០៛ |
| ៤៤- | ឯ.ឧបណ្ឌិត | **មាស** | **ប៉ូ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៤៥- | លោកជំទាវ | **ឆិត្យ** | **ច័ន្ទតារីន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | **ឆា** | **ច័ន្ទលីដា** | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៧- | ឯ.ឧ | **យិន** | **សុង** | ទីប្រឹក្សាឯកឧត្តម **ខួន ញឹល** អនុប្រធានទី ១ រដ្ឋសភា | ១០០.០០០៛ |
| ៤៨- | ឯ.ឧ | **ម៉ែន** | **វិបុល** | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៩- | លោក | **អោម** | **ចន** | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ | ១០០.០០០៛ |
| ៥០- | ឯ.ឧ | **ជួន** | **ថេវ៉ាវ៉ាត** | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន | ១០០.០០០៛ |
| ៥១- | ឯ.ឧ | **ម៉ៅ** | **ឡាំង** | ទីប្រឹក្សាឯកឧត្តម **ខួន ញឹល** អនុប្រធានទី ១ រដ្ឋសភា | ១០០.០០០៛ |
| ៥២- | ឯ.ឧ | **ឆាយ** | **ឫទ្ធិសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៥៣- | លោក | **សាំ** | **ពិសិដ្ឋ** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥៤- | ឯ.ឧ | **អ៊ុន** | **ឆាលី** | អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង | ១០០.០០០៛ |
| ៥៥- | លោក | **សុខ** | **វិសាលសម្បត្តិ** | អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំពៅ១ ស្រុកស៊ីធរកណ្តាល ប្រធានក្រុមហ៊ុនសម្បត្តិមហាសាល ... | ១០០.០០០៛ |
| ៥៦- | ឯ.ឧ | **សៀង** | **សុខឃុនឌី** | អគ្គនាយករងនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០.០០០៛ |
| ៥៧- | ឯ.ឧ | **សាយ** | **បូរ៉ន** | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ៥០.០០០៛ |
| ៥៨- | ឯ.ឧ | **សេង** | **គឹមសាន** | ជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** | ៥០.០០០៛ |
| ៥៩- | ឯ.ឧ | **ពត** | **ចាន់នី** | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |
| ៦០- | ឯ.ឧ | **ហេង** | **វណ្ណា** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦១- | លោក | **ជា** | **វុទ្ធី** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦២- | លោកជំទាវ | **សឿ** | **ច័ន្ទថា** | | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៥៣

| | | | | | |
|---|---|---|---|---|---|
| ៦៣- | លោក | ហួត | ពៅ | ប្រធាននាយកដ្ឋាននីតិវិធីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា | ៥០.០០០៛ |
| ៦៤- | កញ្ញា | ផាំង | និតហ្វើរី | មន្ត្រីក្រសួងទេសចរណ៍ | ៥០.០០០៛ |
| ៦៥- | លោក | ចៅ | ម៉េងថ្លៃន | អភិបាលក្រុងប៉ោយប៉ែត | ៥០.០០០៛ |
| ៦៦- | លោក | អ៊ុំ | រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៧- | លោក | កែវ | សែន | ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ | ៥០.០០០៛ |
| ៦៨- | លោក | សួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៩- | លោក | គាត | ហ៊ឹល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្តាល ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៧០- | លោក | ចាប | ឌីណា | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ | ៥០.០០០៛ |
| ៧១- | ឯ.ឧ | វេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០៛ |
| ៧២- | លោក | លី | សារី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧៣- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧៤- | គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម | | | | ៤០.០០០៛ |
| ៧៥- | ឯ.ឧ | ស៊ិន | ទុន្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៦- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧៧- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ | ៣០.០០០៛ |
| ៧៨- | លោក | ចាន់ | ស៊ុណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៩- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៨០- | លោក | នេព | វិសិដ្ឋ | អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ | ៣០.០០០៛ |
| ៨១- | ឯ.ឧ | ចុង | ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨២- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨៣- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨៤- | លោក | លឹម | វីរក្ស | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨៥- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨៦- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៨៧- | លោក | ឡឹក | សន | អនុប្រធានមន្ទីរគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ២០.០០០៛ |
| ៨៨- | លោក | ជា | គីមលីន | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ២០.០០០៛ |
| ៨៩- | កញ្ញា | កែវ | សុជាតា | មន្ត្រីជំនួយការគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ២០.០០០៛ |
| ៩០- | ឯ.ឧ | ទេស | ច័ន្ទគីរី | សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប | ២០.០០០៛ |
| ៩១- | លោក | ទូច | សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩២- | លោក | ហួង | ថ្មិន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | ២០.០០០៛ |
| ៩៣- | លោក | ម៉ី | វុឌ្ឍា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៩៤- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩៥- | លោក | អ៊ឹក | ទូច | ប្រជាជនភូមិអូររអិល ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន | ២០.០០០៛ |
| ៩៦- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ | ១៥.០០០៛ |
| ៩៧- | លោក | អ៊ុច | សារ៉ាន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ | ១៥.០០០៛ |
| ៩៨- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ៩៩- | ឯ.ឧ | ប៉ូញ | សច្ចៈ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០០- | លោក | ម៉ី | លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ១០.០០០៛ |
| ១០១- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០២- | លោក | ម៉ម | ប្ញូស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៣- | លោក | សៅ | សម្ពស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៤- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៥- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៦- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៧- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៨- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្តុះបណ្តាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៩- | លោក | ទិត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១១០- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១១១- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១២- | លោក | សូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៣- | លោក | ហួត | ឆាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៤- | លោក | ទឹម | វុឌ្ឍារី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៥- | លោក | ណុប | អៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៦- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៧- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៨- | លោក | ទូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៩- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២០- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២១- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២២- | លោក | ឡុង | ចន្ធា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៣- | លោក | ឡាច | តីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៤- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |




**និពន្ធនាយក ៖**

**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**

១. លោក ខៀវ ណារី

២. លោក អ៊ឹម សុន្ទរៈ

៣. លោក វង្ស សារ៉ុធ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

**លេខានិពន្ធ**

១. លោក ជុំ សម្បត្តិ

២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**

១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**

១. លោក សុផាត វីរៈមុនី

**វិចិត្រករ**

១. លោក ធា សារ៉ុធ

អាស័យដ្ឋាន ៖

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ ៖

០២៣ ២១៩ ០៦៥

**Address :**

**No 203 Preah**

**Norodom Bld.**

**Phnom Penh Cambodia**

**Tel : 023 219 065**


# មាតិកា
# Contents



*ទំនាក់ទំនងទ្វេភាគី កម្ពុជា-ឡាវ កាន់តែត្រូវបានពង្រឹង*

៣



***សម្តេចតេជោ* ៖ *ភាពជិតស្និទ្ធរវាងប្រជាពលរដ្ឋ និងអ្នកបម្រើប្រជាពលរដ្ឋ គឺកើតមានឡើងតាមរយៈ ការដែលយើងដាក់ខ្លួនជាខ្ញុំបម្រើ ពិតប្រាកដរបស់គាត់***

៥

**គ្របមុខ**

*ភ្ញៀវទេសចរជាតិ និងអន្តរជាតិទៅ ទស្សនាប្រាសាទតាព្រហ្ម ធ្វើដំណើរឆ្លងកាត់ខ្លោងទ្វារ ដែលកំពុងត្រូវបានជួសជុល*



*ពិធីប្រកាសបង្កើតគណៈកម្មាធិការ គណបក្សខេត្តត្បូងឃ្មុំ*

៩


*វិចារណកថា ៖ ពង្រឹងការអនុវត្តច្បាប់ រក្សាប្រក្រតីភាពនៃជីវភាពសង្គមលើគ្រប់ផ្នែក*........................ ១

*Editorial : Strengthen Rule of Law and Maintain Regular Social Life* ......................................

- *សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស* ................................ ១១
- *សរុបព្រឹត្តិការណ៍ ៖ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែ កុម្ភៈ* ........................................................ ១៤
- *លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច*........................................................................ ១៥
- *ផលនេសាទឆ្នាំ២០១៣ កើនលើសពីឆ្នាំមុនជាង ១៥ %* ........................................................ ១៧
- *ការរីកចម្រើននៃវិស័យសំណង់នៅកម្ពុជា* ........................................................................ ១៩
- *ទេសចរណ៍កម្ពុជាឆ្នាំ ២០១៣ ស្រូបបានប្រាក់ចំណូលជាង ២.៥០០ លានដុល្លារ* ......................... ២១
- *វប្បធម៌ ៖ មហោស្រពខ្លែងខ្មែរលើកទី ១៧* ........................................................................ ២៣
- *ចំណេះដឹងទូទៅ ៖ ទាំងអស់គ្នាត្រូវតស៊ូពន្យឺតការកើនឡើងកម្តៅលើផែនដី* ............................ ២៥
- *វិទ្យាសាស្ត្រ សុខភាព ៖ គ្រួចថ្លុងអាចជួយព្យាបាលជំងឺទឹកនោមផ្អែម* ..................................... ២៧
- *ទឹកដីមាតុភូមិ ៖ ឃុំអូរស្វាយ ទឹកដីអតីតសមរភូមិចុងក្រោយនាពេលបច្ចុប្បន្ន* ............................ ២៨
- *កំណាព្យ ៖ ផលត្រីស្រុកយើង* ........................................ *សំណើច* .................................... ៣១


ទស្សនាវដ្តី
ប្រជាជន
THE PRACHEACHUN MAGAZINE
ឆ្នាំទី១៣ លេខ ១៥៣ ខែកុម្ភៈ ឆ្នាំ ២០១៤



ស្ថានីយអគ្គិសនីដើរដោយធ្យូងថ្ម មានកម្លាំង ១០០ មេហ្គាវ៉ាត់
ស្ថិតក្នុងឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ (សម្ពោធថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៤)



ចែកជូនដោយឥតគិតថ្លៃ